**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ដំណោះស្រាយវិវាទដែនសមុទ្រ

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩


រៀបរៀងដោយ

និស្សិតឈ្មោះ **សាយ ខ៉ូវលីម**

សាស្ត្រាចារ្យណែនាំ

លោក **ពៅ សារឿន**



ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១០

ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយឥត ឧបមា។ ទន្ទឹមនឹងសេចក្ដីរីករាយនេះ ខ្ញុំបាទក៏មិនអាចបំភ្លេចបានដែរចំពោះគុណូបការៈរបស់បុគ្គល សំខាន់ៗមួយចំនួនដែលជួយជ្រោមជ្រែងឲ្យខ្ញុំបានសិក្សាចប់ចុងចប់ដើម និងជួយជ្រោមជ្រែងលើក ទឹកចិត្តដល់ខ្ញុំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះដោយជោគជ័យ។

ជាដំបូង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅអស់ពីក្ដីស្រលាញ់ និងក្ដីគោរពជូនចំពោះ លោកឪពុក **សេខ សាយ** និងអ្នកម្ដាយ **ខ៊ូវ មួយហ៊ុខ** ដែលបានផ្ដល់កំណើតឲ្យកូន និងខិតខំ ប្រឹងប្រែងដើម្បីកូនគ្រប់ពេលវេលា ដើម្បីប្រៀនប្រដៅអប់រំទូន្មានកូន និងផ្ដល់ឱកាសឲ្យកូនបាន សិក្សារៀនសូត្ររហូតដល់ពេលនេះ។

សូមថ្លែងអំណរគុណចំពោះលោកសាកលវិទ្យាធិការ **លុយ ចន្ណា** ជាសាកលវិទ្យាធិការនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមជាមួយនឹងលោកគ្រូ អ្នកគ្រូ ទាំង អស់ដែលជាបុគ្គលនៃសាកលវិទ្យាល័យ ដែលបានខិតខំប្រឹងប្រែងបង្កើតកម្មវិធីសិក្សាល្អៗសម្រាប់ និស្សិត និងជួយជ្រោមជ្រែងសម្របសម្រួលគ្រប់បែបយ៉ាងដល់និស្សិតគ្រប់រូបក៏ដូចជារូបខ្ញុំបាទក្នុង ការសរសេរសារណាបញ្ចប់ការសិក្សានេះ។

សូមថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ **ពៅ សារឿន** ដែលលោកបានចំណាយ ពេលវេលាដ៏មានតំលៃរបស់លោក ដើម្បីខិតខំប្រឹងប្រែងបង្ហាត់បង្រៀនផ្ដល់នូវចំណេះដឹងពិត ប្រាកដនិងថ្មីៗ ព្រមទាំងបានណែនាំដល់រូបខ្ញុំ ក្នុងការសរសេរសារណានេះចប់ដោយជោគជ័យ។

សូមថ្លែងអំណរគុណចំពោះ លោកឪពុកមា ម្ដាយមីងទាំងអស់ដែលបានជួយមើលថែខ្ញុំ ក៏ ដូចជាផ្ដល់ដំបូន្មានល្អៗមកដល់ខ្ញុំ ជាពិសេសលោកឪពុកមា **ហេខ បញ្ញាខឡ្យ** ដែលលោកបាន ចង្អុលបង្ហាញទិសឲ្យខ្ញុំមកសិក្សាជំនាញនីតិសាស្ត្រ។

ជាមួយគ្នានេះដែរ ខ្ញុំបាទក៏សូមថ្លែងអំណរគុណចំពោះមិត្តភក្ដិទាំងអស់ សិស្សច្បងព្រម ជាមួយនឹងសិស្សប្អូនដែលបានផ្ដល់ជាកំលាំងចិត្តដល់ខ្ញុំក្នុងការសរសេរសារណានេះផងដែរ។

ជាចុងបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូន លោកឪពុកអ្នកម្ដាយ លោកគ្រូអ្នកគ្រូ ឪពុកមាម្ដាយ មីង មិត្តភក្ដិទាំងអស់ ព្រមជាមួយនឹងសិស្សច្បងនិងសិស្សប្អូនទាំងអស់ ជួបតែសេចក្ដីសុខ សេចក្ដី ចម្រើន មានសុភមង្គលក្នុងក្រុមគ្រួសារ ប្រកបរបរទទួលទានកាន់តែល្អតលាស់ជារៀងដរាប៕

# អារម្ភកថា

ខ្ញុំយល់ថាប្រធានបទនៃសារណាបញ្ចប់ការសិក្សា "ដំណោះស្រាយវិវាទដែនសមុទ្រ" ជាប្រធានបទមួយដ៏ល្អនិងគួរឲ្យចាប់អារម្មណ៍ហើយស្របទៅតាមសម័យកាល ព្រោះថាបច្ចុប្បន្ននេះខ្ញុំឃើញថាវិវាទរវាងរដ្ឋនិងរដ្ឋ ភាគច្រើនកើតឡើងនៅលើដែនសមុទ្រដូចជា វិវាទរវាងប្រទេសចិននិងប្រទេសជប៉ុននៅលើតំបន់កោះស៊ិនកាគូ វិវាទរវាងប្រទេសចិននិងបណ្តាប្រទេសអាស៊ានក្នុងតំបន់សមុទ្រចិនខាងត្បូង។ល។ ខ្ញុំពិតជាចង់ដឹងណាស់ថាតើការដោះស្រាយវិវាទនៅលើដែនសមុទ្រមានដំណើរការបែបណាទៅ?

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវ និងបានទទួលការណែនាំនិងយោបល់ល្អៗពីសំណាក់លោកសាស្ត្រាចារ្យ**ពៅ សារឿន** រួចមកទាក់ទងនឹងដំណោះស្រាយលើវិវាទដែនសមុទ្រ ពិតជាធ្វើឲ្យខ្ញុំទទួលបាននូវចំណេះដឹងបន្ថែមទាក់ទងនឹងប្រព័ន្ធយុត្តាធិការ និងនីតិវិធីនៃការដោះស្រាយវិវាទនៅលើដែនសមុទ្រ ដែលពីមុនមកខ្ញុំមិនធ្លាប់បានដឹងឡើយថា ការដោះស្រាយវិវាទនៅលើដែនសមុទ្រមានលក្ខណៈបែបណានោះ។ ទាក់ទងនឹងការសិក្សាស្រាវជ្រាវនេះ ក៏ទាមទារឲ្យខ្ញុំចំណាយពេលវេលាដើម្បីស្វែងរកឯកសារនានាទាំងភាសាជាតិ និងភាសាបរទេស។ ឯកសារជាភាសាជាតិពុំសូវសំបូរបែបនោះទេ ប៉ុន្តែឯកសារជាភាសាបរទេសគឺសំបូរបែប ដែលជាហេតុមួយធ្វើឲ្យខ្ញុំមានការលំបាកក្នុងការបកប្រែពីភាសាបរទេសមកជាភាសាខ្មែរ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំជឿជាក់ថាការខិតខំរបស់ខ្ញុំចំពោះសារណាបញ្ចប់ការសិក្សាមួយនេះនឹងទទួលបានលទ្ធផលជាផ្លែផ្កា ហើយសង្ឃឹមយ៉ាងមុតមាំថា ស្នាដៃនេះនឹងអាចជាសារណាដំបូងដែលនិយាយពីការដោះស្រាយវិវាទនៅលើដែនសមុទ្រ និងអាចផ្តល់ផលប្រយោជន៍ដល់និស្សិតជំនាន់ក្រោយៗទៀតដែលចង់សិក្សាឬស្វែងយល់បន្ថែមពីបញ្ហាដែលកើតមានឡើងនិងប្រព័ន្ធនៃការដោះស្រាយវិវាទនៅលើសមុទ្រ។

តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំដឹងថាកំហុសនៅក្នុងសារណាបញ្ចប់ការសិក្សានេះប្រាកដជាកើតមានឡើងដោយប្រការណាមួយជាក់ជាមិនខាន។ អាស្រ័យហេតុនេះហើយ ខ្ញុំសូមអធ្យាស្រ័យទុកជាមុនផងដែរ ចំពោះកំហុសឆ្គងទាំងឡាយដែលបានកើតមានឡើងនៅក្នុងអត្ថបទសារណាមួយនេះ។ ហើយលើសពីនេះទៅទៀតនោះ ខ្ញុំរីករាយជានិច្ចចំពោះការចូលរួមផ្តល់ជាយោបល់ដើម្បីកែលំអ ឬ ស្ថាបនាស្នាដៃមួយនេះឲ្យកាន់តែប្រសើរឡើងនិងមានលក្ខណៈគ្រប់ជ្រុងជ្រោយជាងនេះ៕

# មាតិកា

**សេចក្តីផ្តើម**.......................................................................... ១
**ជំពូកទី១ ការកំណត់ព្រំដែនសមុទ្រ**.......................................................................... ២
**ផ្នែកទី១** ការកំណត់ព្រំដែនសមុទ្រសម័យបុរាណ.......................................................................... ២
**កថាខណ្ឌទី១** សន្ធិសញ្ញាថ័រដេស៊ីឡា(Treaty of Tordesillas).......................................................................... ៣
**កថាខណ្ឌទី២** ការកំណត់ដែនសមុទ្រតាមរយៈការបាញ់ចេញពីកាំភ្លើងធ្លោង...... ៤
**កថាខណ្ឌទី៣** សន្និសីទបង្កើតនីតិអន្តរជាតិឆ្នាំ១៩៣០.......................................................................... ៥
**កថាខណ្ឌទី៤** សេចក្តីប្រកាសហារី ទ្រូមែន(Harry Truman) ឆ្នាំ១៩៤៥...................... ៥
**ផ្នែកទី២** ការកំណត់ព្រំដែនសមុទ្រសម័យបច្ចុប្បន្ន.......................................................................... ៥
**កថាខណ្ឌទី១** បន្ទាត់មូលដ្ឋាន (Baselines).......................................................................... ៦
**កថាខណ្ឌទី២** ដែនទឹកផ្ទៃក្នុង (Internal Waters).......................................................................... ៦
**កថាខណ្ឌទី៣** សមុទ្រដែនដី (Territorial Sea).......................................................................... ៦
**កថាខណ្ឌទី៤** តំបន់តភ្ជាប់ (Contiguous Zone).......................................................................... ៧
**កថាខណ្ឌទី៥** តំបន់សេដ្ឋកិច្ចផ្តាច់មុខ (Exclusive Economic Zone “EEZ”).................... ៧
**កថាខណ្ឌទី៦** លំហសមុទ្រអន្តរជាតិ (High Seas).......................................................................... ៨
**កថាខណ្ឌទី៧** ខ្ពង់រាបបាតសមុទ្រ (Continental Self).......................................................................... ៨
**ជំពូកទី២ ការដោះស្រាយវិវាទដែនសមុទ្រ**.......................................................................... ១០
**ផ្នែកទី១** វិវាទដែនសមុទ្រ.......................................................................... ១០
**កថាខណ្ឌទី១** និយមន័យ.......................................................................... ១០
**កថាខណ្ឌទី២** កត្តាដែលនាំឲ្យមានវិវាទដែនសមុទ្រ.......................................................................... ១១
**កថាខណ្ឌទី៣** ផលវិបាកនៃវិវាទដែនសមុទ្រ.......................................................................... ១១
**ផ្នែកទី២** នីតិវិធីនៃការដោះស្រាយវិវាទដែនសមុទ្រ.......................................................................... ១២
**កថាខណ្ឌទី១** សមត្ថកិច្ចយុត្តាធិការដែនដី.......................................................................... ១៣
១.១. សមត្ថកិច្ចយុត្តាធិការរបស់រដ្ឋជាប់ឆ្នេរ.......................................................................... ១៣
១.១.១. សមត្ថកិច្ចរបស់រដ្ឋជាប់ឆ្នេរក្នុងការផ្តល់ទង់ជាតិឲ្យនាវា.............................. ១៣

១.១.២. សមត្ថកិច្ចក្នុងតំបន់សមុទ្ររបស់រដ្ឋជាប់ឆ្នេរ.......................................... ១៣
ក. យុត្តាធិការលើការការពារ.......................................................................... ១៣
ខ. យុត្តាធិការលើការតាក់តែងច្បាប់.................................................................. ១៤
គ. យុត្តាធិការចាប់បង្ខំ.................................................................................. ១៤
១.១.៣. សមត្ថកិច្ចរដ្ឋជាប់ឆ្នេរក្នុងការអនុញ្ញាតឲ្យអនុវត្តច្បាប់ដោយរដ្ឋកំពង់ផែ.. ១៤
១.២. សមត្ថកិច្ចរបស់នាវា.................................................................................. ១៥
**កថាខណ្ឌទី២** ការដោះស្រាយដោយការចរចាទ្វេភាគី.............................................. ១៥
**កថាខណ្ឌទី៣** ការដោះស្រាយដោយមានការចូលរួមពីភាគីទី៣.............................. ១៥
៣.១. ការផ្តល់កន្លែងចរចា (Good Offices)............................................................ ១៦
៣.២. ការផ្សះផ្សា (Conciliation)........................................................................... ១៦
៣.៣. ការសម្រុះសម្រួល (Mediation)...................................................................... ១៦
**កថាខណ្ឌទី៤** ការដោះស្រាយតាមរយៈប្រព័ន្ធតុលាការអន្តរជាតិ............................ ១៧
៤.១. សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (International Tribunal for the Law of the Sea “ITLOS”)........................................................................................................... ១៧
៤.១.១. អំពីស្ថាប័ន.............................................................................................. ១៧
៤.១.១.១. សមាសភាព............................................................................................ ១៧
ក. ចៅក្រម........................................................................................................ ១៧
ខ. ប្រធានចៅក្រម និងអនុប្រធានចៅក្រម (President and Vice-President)................ ១៨
៤.១.១.២. អង្គជំនុំជម្រះ........................................................................................ ១៨
ក. អង្គជំនុំជម្រះវិវាទបាតសមុទ្រ (The Seabed Disputes Chamber)............................ ១៩
ខ. អង្គជំនុំជម្រះនៃនីតិវិធីសង្ខេប (Chamber of Summary Procedure)............................ ១៩
គ. អង្គជំនុំជម្រះពិសេសផ្សេងៗទៀត (Other Special Chambers)................................ ១៩
៤.១.២. សមត្ថកិច្ចនៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ....................................... ១៩
៤.១.២.១. ការទទួលពាក្យបណ្តឹង.............................................................................. ១៩
៤.១.២.២.យុត្តាធិការសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ........................................២០

ក. យុត្តាធិការទាក់ទងនឹងវិវាទ (Contentious Jurisdiction)........................................ ២០
ខ. យុត្តាធិការទាក់ទងនឹងការបកស្រាយច្បាប់ (Advisory Jurisdiction)................. ២១
៤.១.៣. នីតិវិធីនៅសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ.................................... ២១
៤.២. តុលាការយុត្តិធម៌អន្តរជាតិ (International Court of Justice “ICJ”).................. ២២
៤.២.១. អំពីស្ថាប័ន......................................................................................... ២២
៤.២.១.១. សមាសភាព.................................................................................... ២៣
ក.ចៅក្រម.................................................................................................. ២៣
ខ. ប្រធាន និងអនុប្រធានចៅក្រម (President and Vice-President)............................ ២៤
៤.២.១.២. អង្គជំនុំជម្រះ.................................................................................. ២៤
៤.២.២.យុត្តាធិការ............................................................................................ ២៥
៤.២.២.១. យុត្តាធិការដោះស្រាយវិវាទ (Contentious Jurisdiction)............................ ២៥
៤.២.២.២. យុត្តាធិការបកស្រាយច្បាប់ (Advisory Jurisdiction)................................. ២៥
៤.២.៣. នីតិវិធី................................................................................................ ២៦
៤.៣. សាលាក្តីមជ្ឈត្តវិនិច្ឆ័យ (An Arbitral Tribunal) ................................................... ២៦
៤.៣.១. សមត្ថកិច្ចនៃសាលាក្តីមជ្ឈត្តវិនិច្ឆ័យ.......................................................... ២៧
៤.៣.២. កាតព្វកិច្ចនៃភាគីវិវាទ............................................................................ ២៧
៤.៤. សាលាក្តីមជ្ឈត្តវិនិច្ឆ័យពិសេស (A Special Arbitral Tribunal)............................ ២៧
៤.៤.១. សមត្ថកិច្ចនៃសាលាក្តីមជ្ឈត្តវិនិច្ឆ័យពិសេស............................................. ២៧
៤.៤.២. កាតព្វកិច្ចនៃភាគីវិវាទ............................................................................ ២៨
**ជំពូកទី៣ សមិទ្ធផលនៃការដោះស្រាយលើវិវាទដែនសមុទ្រ**.............................. ៣០
**ផ្នែកទី១** វិវាទទាក់ទងនឹងការកំណត់ព្រំដែននៅសមុទ្រខ្មៅរវាងប្រទេសរ៉ូម៉ានី(Romania) និងប្រទេសអ៊ុយក្រែន (Ukraine) ឆ្នាំ២០០៤................................................................... ៣០
**កថាខណ្ឌទី១** អង្គហេតុ.......................................................................... ៣០
**កថាខណ្ឌទី២** អង្គច្បាប់.......................................................................... ៣២
**កថាខណ្ឌទី៣** សេចក្តីសម្រេច.................................................................... ៣២

**ផ្នែកទី២** វិវាទដែនសមុទ្ររវាងប្រទេសNicaragua និងប្រទេស Colombia ឆ្នាំ២០១៣....... ៣៣
**កថាខណ្ឌទី១** អង្គហេតុ........ ៣៣
**កថាខណ្ឌទី២** អង្គច្បាប់........ ៣៣
**ផ្នែកទី៣** បញ្ហាប្រឈមនៃវិវាទសមុទ្រចិនខាងត្បូង........ ៣៤
**កថាខណ្ឌទី១** ភាគីនៃវិវាទ........ ៣៤
១.១. ប្រទេសចិន........ ៣៥
១.២. ប្រទេសចិន និង វៀតណាម........ ៣៥
១.៣. ប្រទេសចិន និង ហ្វីលីពីន........ ៣៧
១.៤. ប្រទេសចិន និង ម៉ាឡេស៊ី........ ៣៨
១.៥. ប្រទេសចិន និង ប្រ៊ុយណេ........ ៣៩
**កថាខណ្ឌទី២** មូលហេតុនៃវិវាទ........ ៣៩
**កថាខណ្ឌទី៣** ដំណោះស្រាយកន្លងមក........ ៤០
**សេចក្ដីសន្និដ្ឋាន**........ ៤២
**អនុសាសន៍**........ ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ភពផែនដីរបស់យើងបច្ចុប្បន្ន ទំហំនៃផ្ទៃទឹកសមុទ្រមានភាគរយច្រើនជាងដីគោក ហើយសមុទ្រត្រូវបានគេកំណត់ឈ្មោះតាមតំបន់នីមួយៗ ដែលធ្វើឲ្យយើងអាចរាប់ចំនួនតំបន់សមុទ្រទាំងនោះបាន។ នៅលើពិភពលោកយើងនេះមានមហាសមុទ្រធំៗចំនួន៤ដែលមានដូចជាមហាសមុទ្រអាត្លង់ទិក មហាសមុទ្រប៉ាស៊ីភិច មហាសមុទ្រឥណ្ឌា និងមហាសមុទ្រអង់តាកតិក។[1] ហើយព្រមទាំងមានសមុទ្រផ្សេងៗទៀតដូចជា សមុទ្រចិនខាងត្បូង សមុទ្រខ្មៅ សមុទ្រជប៉ុន។ល។ តាមរយៈសមុទ្រនេះហើយ ធ្វើឲ្យរដ្ឋនានានៅជុំវិញសាកលលោកអាចទាញផលប្រយោជន៍ជាច្រើនពីសមុទ្រដែលមានដូចជា រ៉ែក្រោមបាតសមុទ្រ ធនធានធម្មជាតិ សត្វនៅក្នុងសមុទ្រគ្រប់ប្រភេទ ហើយផ្តល់ជាផ្លូវគមនាគមន៍នៃនាវាទាំងឡាយជាដើម។ ទន្ទឹមគ្នាជាមួយនឹងផលប្រយោជន៍ដ៏ច្រើនមហាសាលទាំងនោះហើយ ក៏ជាហេតុនាំឲ្យមានវិវាទរវាងរដ្ឋ និងរដ្ឋកើតមានឡើងផងដែរ ដែលវិវាទទាំងនោះជាទូទៅទាក់ទងនឹងបញ្ហាផ្សេងៗជាច្រើនដែលមានដូចជា ការនេសាទ ការធ្វើនាវាចរណ៍ ការដាក់បំពង់ក្រោមបាតសមុទ្រ ការកំណត់ដែនសមុទ្រជាដើម។ ពិតជាពិបាកដោះស្រាយណាស់ បើសិនជាគ្មានច្បាប់ ឬលទ្ធិ ឬទំនៀមទំលាប់ឬក៏ការកំណត់ណាមួយនៅលើសមុទ្រនោះ។ តាំងពីបុរាណរហូតមកដល់បច្ចុប្បន្ន គេតែងតែបង្កើតឲ្យមានច្បាប់ ឬក្រម ឬក៏ទំនៀមទំលាប់នានានៅលើតំបន់សមុទ្រដើម្បីការពារផលប្រយោជន៍ក៏ដូចជាបង្ការ ឬក៏ដោះស្រាយនូវវិវាទនានាដែលបានកើតឡើង។ ដូច្នេះ តើនៅសម័យបុរាណគេកំណត់ព្រំដែនសមុទ្រដូចម្តេចទៅ? ហើយនៅសម័យបច្ចុប្បន្ននេះគេកំណត់ព្រំដែនសមុទ្រដូចម្តេចដែរ? តើការកំណត់ព្រំដែនសមុទ្រនោះមានចែងនៅទីណាដែរ? ចំណែកឯការដោះស្រាយវិវាទនៅលើដែនសមុទ្រវិញ តើនរណាជាអ្នកដែលមានសមត្ថកិច្ចក្នុងការដោះស្រាយ?

នៅក្នុងសារណានេះ យើងនឹងធ្វើការបកស្រាយពីការកំណត់ព្រំដែនសមុទ្រ និង សមត្ថកិច្ចយុត្តាធិការក្នុងការដោះស្រាយវិវាទដែនសមុទ្រ អមជាមួយគ្នានេះដែរ យើងនឹងធ្វើការបកស្រាយពីរឿងក្តីផងដែរ ហើយយើងបានធ្វើការបែងចែកជាបីជំពូកដូចខាងក្រោម៖

ជំពូកទី១ ការកំណត់ព្រំដែនសមុទ្រ

ជំពូកទី២ ការដោះស្រាយវិវាទដែនសមុទ្រ

ជំពូកទី៣ សមិទ្ធផលនៃការដោះស្រាយវិវាទដែនសមុទ្រ

[1] http://oceanservice.noaa.gov/facts/howmanyoceans.html (ចូលទស្សនាថ្ងៃទី៦ កក្កដា ២០១៤)។

# ជំពូកទី១
# ការកំណត់ព្រំដែនសមុទ្រ

សមុទ្រ គឺជាលំហទឹកល្វឹងល្វើយដែលមានរហូតដល់ទៅ ៧១%គ្របដណ្តប់លើភពផែនដី។ ជាច្រើនសតវត្សមុន លំហសមុទ្រមិនត្រូវបានគេបង្កើតឲ្យមានបទដ្ឋានគតិយុត្តណាមួយដើម្បីធ្វើការគ្រប់គ្រងឡើយ មានន័យថាពេលនោះលំហសមុទ្រគឺជាលំហមួយដែលមនុស្សគ្រប់រូបមានសេរីភាពក្នុងការនេសាទ ដឹកជញ្ជូនទំនិញ ស្វែងរកធនធានធម្មជាតិនានា។ល។ ប៉ុន្តែក្រោយៗមកលំហសមុទ្រត្រូវបានកំណត់ឲ្យប្រើប្រាស់ក្នុងទំហំតូចប៉ុណ្ណោះ មានន័យថារដ្ឋជាប់ឆ្នេរអាចប្រើប្រាស់តំបន់សមុទ្រក្នុងទំហំតែ៣ម៉ៃល៍ប៉ុណ្ណោះ។ លុះក្រោយៗមកទៀត ការប្រើប្រាស់លំហសមុទ្រក្នុងគោលបំណង ពង្រឹងសេដ្ឋកិច្ចជាតិរបស់ខ្លួនឲ្យកាន់តែមានការកើនឡើងគួរឲ្យកត់សំគាល់ ទើបធ្វើឲ្យបណ្តារដ្ឋទាំងនោះបានទាមទារឲ្យមានការពង្រីកទំហំសមុទ្រឲ្យធំជាងមុន ។ មកដល់សម័យក្រោយសង្គ្រាមលោកលើកទី២ ជម្លោះនៅលើសមុទ្រមានច្រើនជាងជម្លោះនៅលើដីគោក ដោយសារតែមានការទាមទារខ្លាំងឡើងៗលើការពង្រីកសមុទ្រដែនដី តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងខ្ពង់រាបបាតសមុទ្រ។

ដូចដែលបានរៀបរាប់ខាងលើ តើការកំណត់ដែនសមុទ្រពីសម័យដែលមិនទាន់មានអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) រហូតដល់សម័យដែលមានអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS)មានលក្ខណៈយ៉ាងដូចម្តេចខ្លះ?

ជាបន្តទៀត យើងនឹងធ្វើការបកស្រាយពីការកំណត់ដែនសមុទ្រ និង សិទ្ធិរបស់រដ្ឋនៅលើដែនសមុទ្រដូចតទៅៈ

ផ្នែកទី១ ការកំណត់ព្រំដែនសមុទ្រសម័យបុរាណ

ផ្នែកទី២ ការកំណត់ព្រំដែនសមុទ្រសម័យបច្ចុប្បន្ន

## ផ្នែកទី១ ការកំណត់ព្រំដែនសមុទ្រសម័យបុរាណ

ការកំណត់ព្រំដែនសមុទ្រសម័យបុរាណ ដែលលើកយកមកបង្ហាញនេះ គឺសំដៅលើការកំណត់ព្រំដែនសមុទ្រ ដែលមានមុនពេលការបង្កើតឲ្យមាន អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS)។ កាលពីបុរាណ យើងក៏សង្កេតឃើញមានក្រមសមុទ្រមួយចំនួនដូចជាច្បាប់សមុទ្ររ៉ូឌាន (Rhodian Sea Law) ច្បាប់នៃអូឡឺរ៉ន (Rules of Oleron)ច្បាប់ខនស្វូឡាតូឌែលម៉ារេ (Consolato del Mare) និង ខ្លះទៀតគឺអនុវត្តន៍ទៅតាមទំនៀមទំលាប់នៃការអនុវត្តជាអន្តរជាតិ។[2]

[2] Mark W. Janis, *An Introduction to International Law* [សេចក្តីផ្តើមនីតិអន្តរជាតិ] (US: Little, brown and company, 1993), 203-204។

ទោះបីជាមានច្បាប់ទាំងនេះក៏ពិតមែន ប៉ុន្តែយើងមិនដឹងថាការកំណត់ព្រំដែនសមុទ្រដោយយោងតាមច្បាប់ទាំងនេះមានលក្ខណៈបែបណានោះទេ។

អាស្រ័យហេតុនេះ យើងលើកយកតែការកំណត់ព្រំដែនសមុទ្រមួយចំនួនដែលមានលក្ខណៈច្បាស់លាស់មកបង្ហាញតែប៉ុណ្ណោះ ដែលការកំណត់ទាំងនោះមានដូចជា សន្ធិសញ្ញាថ័រដេស៊ីឡារបៀបកំណត់ដែនសមុទ្រតាមរយៈការបាញ់ចេញពីកាំភ្លើងធ្លោង សន្និសីទបង្កើតនីតិអន្តរជាតិឆ្នាំ១៩៣០ និង សេចក្តីប្រកាសហារី ទ្រូមែនឆ្នាំ ១៩៤៥ ។

**កថាខណ្ឌទី១ សន្ធិសញ្ញាថ័រដេស៊ីឡា (Treaty of Tordesillas)**

នៅមុនដំណាច់សតវត្សទី១៥ បណ្តាប្រទេសនៅអឺរ៉ុបបានចាប់ផ្តើមបញ្ជូនអ្នកស្រាវជ្រាវរបស់ពួកគេ ឲ្យសិក្សាស្រាវជ្រាវធ្វើផែនទីពិភពលោក ក៏ដូចជាផ្លូវនាវាចរណ៍ទៅកាន់ទ្វីបអាហ្វ្រិក ប្រទេសចិន ប្រទេសឥណ្ឌា ដែលពេលនោះការគ្រប់គ្រងទៅលើការធ្វើនាវាចរណ៍នៅលើដែនសមុទ្រពុំទាន់មាននៅឡើយទេ។[3] ប្រទេសពីរដែលនាំមុខគេក្នុងការដើរសមុទ្រគឺ ព្រះរាជាណាចក្រអេស្ប៉ាញ និង ប្រទេសព័រទុយហ្គាល់ ដែលប្រទេសទាំងពីរនេះបានធ្វើដំណើរទៅដល់ឆ្នេរសមុទ្រអាហ្វ្រិក ហើយថែមទាំងអាចធ្វើពាណិជ្ជកម្មរហូតដល់ប្រទេសឥណ្ឌាផងដែរ។ នៅពេលនោះដែរព្រះរាជា Pope Sixtus IV បានអះអាងថាប្រទេសអេស្ប៉ាញជាប្រទេសដែលគ្រប់គ្រងទៅលើកោះកាណារី (Canary Islands) និងតំបន់នៅក្បែរកោះនោះ។ ប្រទេសអេស្ប៉ាញក៏បានបញ្ជូនអ្នកស្រាវជ្រាវរបស់ខ្លួន គឺលោក Columbus ទៅកាន់តំបន់ខាងត្បូងនៃកោះកាណារី (Canary Islands)។[4]

លោក Christopher Columbusបានរកឃើញឥណ្ឌាខាងលិចនៅឆ្នាំ១៤៩២ ដែលគេហៅតំបន់នេះថា "**ពិភពថ្មី**" (the New World) ។[5] បន្ទាប់ពីលោក Columbus រកឃើញតំបន់ពិភពថ្មីនេះហើយ ទំនាស់ក៏កើតមានឡើងនៅលើតំបន់នេះ ព្រោះថាតំបន់នេះជាតំបន់ដែលមានអត្ថប្រយោជន៍ ហើយក៏ជាផ្លូវទឹកសំរាប់ធ្វើពាណិជ្ជកម្មទៅកាន់អាហ្វ្រិក(Africa) ប្រទេសឥណ្ឌា(India) ប្រទេសចិន(China) ដែលជាហេតុធ្វើឲ្យប្រទេសអេស្ប៉ាញ និងប្រទេសព័រទុយហ្គាល់ដណ្តើមគ្នា។[6] ការស្វែងរក

[3] Joseph Guvendiren, *Background Guide 2012 Treaty of Tordesillas* [*ការណែនាំពីប្រវត្តិនៃសន្ធិសញ្ញាថ័រដេស៊ីឡា*] (Five College Model United Nations, 2012), 1។

[4] Joseph Guvendiren, *Background Guide 2012 Treaty of Tordesillas* [*ការណែនាំពីប្រវត្តិនៃសន្ធិសញ្ញាថ័រដេស៊ីឡា*] (Five College Model United Nations, 2012), 1។

[5] Joseph Guvendiren, *Background Guide 2012 Treaty of Tordesillas* [*ការណែនាំពីប្រវត្តិនៃសន្ធិសញ្ញាថ័រដេស៊ីឡា*] (Five College Model United Nations, 2012), 1។

[6] Prof. Ivan Van Sertima, *They Came Before Columbus* [ពួកគេបានមកដល់មុនលោក Columbus], (1976), 20។

ឃើញនូវដែនដីថ្មី ប្រៀបបាននឹងការរកឃើញទ្រព្យសម្បត្តិដ៏មានសក្តានុភាពអស្ចារ្យបំផុតសំរាប់បណ្តាប្រជាជាតិអឺរ៉ុប។ ដូច្នេះហើយ ការដណ្តើមតំបន់ពិភពថ្មីបានក្លាយទៅជារឿងដ៏សំខាន់។

នៅសម័យនោះ សម្តេចប៉ូបជាជនដែលមានឥទ្ធិពលជាងគេនៅបណ្តាប្រទេសអឺរ៉ុបបានធ្វើអាជ្ញាកណ្តាលក្នុងការដោះស្រាយវិវាទរវាងប្រទេសអេស្ប៉ាញ និង ប្រទេសព័រទុយហ្គាល់ដោយសម្តេចបានបង្កើតឲ្យមានសន្ធិសញ្ញាថ័រដេស៊ីឡា។ សន្ធិសញ្ញាថ័រដេស៊ីឡា ត្រូវបានព្រមព្រៀងដោយប្រទេសអេស្ប៉ាញ និង ប្រទេសព័រទុយហ្គាល់ដែលជាមហាអំណាចនៅអឺរ៉ុបនាសម័យនោះ ហើយនិង អនុម័តនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៤៩៤ ដើម្បីធ្វើការកំណត់ និងគូសខ្សែបន្ទាត់ព្រំដែន។[7] ខ្សែបន្ទាត់នេះកំណត់ដោយសម្តេចប៉ូបអេឡិចហ្សិនដ័រទី៦ មានចំងាយ ៣៧០ leagues (១league គឺប្រហែល ៣ម៉ែល៍ ឬ ៤០០០ម៉ែត្រ) គិតចាប់ពីតំបន់ប្រជុំកោះខេបវែដ (Cape Verde Islands)។ ខ្សែបន្ទាត់ ត្រូវបានគូសនៅចំកណ្តាលមហាសមុទ្រអាត្លង់ទិក។ តំបន់ដែលស្ថិតនៅខាងលិចខ្សែបន្ទាត់ស្ថិតនៅក្រោមការត្រួតត្រារបស់ប្រទេសអេស្ប៉ាញ ចំណែកឯតំបន់ដែលស្ថិតនៅខាងកើតខ្សែបន្ទាត់វិញ ស្ថិតនៅក្រោមការត្រួតត្រារបស់ប្រទេសព័រទុយហ្គាល់។ សម្តេចប៉ូបអេឡិហ្សិនដ័រទី៦ ធ្វើការសម្រេចបែបនេះ ដោយសារតែមានបំណងមិនចង់ឲ្យប្រទេសទាំងពីរវាយច្បាំងគ្នា ព្រោះប្រទេសទាំងពីរកាន់សាសនាកាតូលិកដូចគ្នា។[8]

### កថាខណ្ឌទី២ ការកំណត់ដែនសមុទ្រតាមរយៈការបាញ់ចេញពីកាំភ្លើងធ្លោង

ការកំណត់ដែនសមុទ្រតាមរយៈការបាញ់ចេញពីកាណុងកាំភ្លើងធ្លោង គឺជាការកំណត់ដែនសមុទ្រនៅក្នុងតំបន់សមុទ្រដែនដី ហើយត្រូវបានគេប្រើប្រាស់ចាប់តាំងពីឆ្នាំ១៧៩៥។ ការប្រើប្រាស់កាំភ្លើងធ្លោងធ្វើជារង្វាស់សំរាប់កំណត់ដែនសមុទ្រនេះ បានក្លាយទៅជារូបមន្តដែលត្រូវបានគេទទួលយកជាសាកល និង ត្រូវបានអភិវឌ្ឍទៅជាដែនកំណត់ចម្ងាយ៣ម៉ែល៍។ ប៉ុន្តែក្រោយៗមកក៏មានប្រទេសខ្លះគេទាមទារសមុទ្រដែនដីចម្ងាយ៤ម៉ែល៍ ហើយប្រទេសខ្លះទៀតទាមទារចម្ងាយ៦ម៉ែល៍។ នៅឆ្នាំ១៩៥១ ការដឹកជញ្ជូនតាមនាវាពាណិជ្ជកម្មពិភពលោកចំនួន៨០%បានចុះបញ្ជីនៅប្រទេសដែលគោរពដែនកំណត់៣ម៉ែល៍ ហើយ១០%ចុះបញ្ជីនៅប្រទេសគោរពដែនកំណត់៤ម៉ែល៍។[9] នៅពេលដែលសហគមន៍អន្តរជាតិទទួលស្គាល់ថារដ្ឋជាប់ឆ្នេរមានសិទ្ធិទៅលើតំបន់សមុទ្រ

---

[7] Joseph Guvendiren, *Background Guide 2012 Treaty of Tordesillas* [សេចក្តីណែនាំពីប្រវត្តិនៃសន្ធិសញ្ញាថ័រដេស៊ីឡា] (Five College Model United Nations, 2012), 2។

[8] សាស្ត្រាចារ្យ សំរ៉ង វិទ្ធីរង្គ, *នីតិសមុទ្រ* (ភ្នំពេញ៖ រោងពុម្ពអង្គរ, ២០១០), ១៦។

[9] សាស្ត្រាចារ្យ សំរ៉ង វិទ្ធីរង្គ, *នីតិសមុទ្រ* (ភ្នំពេញ៖ រោងពុម្ពអង្គរ, ២០១០), ៣១។

ដែនដីដែលមានចម្ងាយ៣ម៉ៃល៍ ឬ ៤ម៉ៃល៍ ពេលនោះបញ្ហានានាដែលទាក់ទងនឹងសមុទ្រពុំមែនជាបញ្ហាចោទទៀតទេ។

**កថាខណ្ឌទី៣ សន្និសីទបង្កើតនីតិអន្តរជាតិឆ្នាំ ១៩៣០**

សន្និសីទបង្កើតនីតិអន្តរជាតិ (Conference for the Codification of International Law) បានធ្វើឡើងនៅទីក្រុងឡាអេ (The Hague) ក្នុងឆ្នាំ១៩៣០។ នៅក្នុងសន្និសីទនេះបានពិភាក្សានូវបញ្ហាជាច្រើន ដែលក្នុងចំណោមបញ្ហាទាំងនោះក៏មានទាក់ទងទៅនឹងនីតិសមុទ្រដែរ។ ការពិភាក្សាទាក់ទងទៅនឹងនីតិសមុទ្រមានដូចជា៖ សម្រេចកំណត់សមុទ្រដែនដីមានចម្ងាយ៣ម៉ៃល៍ ការទាមទាររបស់រដ្ឋមួយចំនួនលើការពង្រីកសមុទ្រដែនដី ការយល់ព្រមទទួលយកគោលការណ៍ដែលអាចប្រើប្រាស់យុត្តាធិការលើកិច្ចការគយ សុខាភិបាល និងសន្តិសុខនៅក្នុងតំបន់តភ្ជាប់ សំណើឲ្យមានតំបន់នេសាទផ្តាច់មុខ ទំហំធំ និងគោលគំនិតអំពីមរតករួម។ ការពិភាក្សាគ្នានៅក្នុងសន្និសីទមិនអាចដោះស្រាយបញ្ហាបានទាំងអស់នោះទេ ប៉ុន្តែបានកំណត់អត្តសញ្ញាណនិងនិយមន័យខ្លះៗដែរ។

**កថាខណ្ឌទី៤ សេចក្តីប្រកាសហារី ទ្រូម៉ែន (Harry Truman)ឆ្នាំ ១៩៤៥**

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៤៥ លោកប្រធានាធិបតី ហារី ទ្រូម៉ែន(Harry Truman)បានចេញសេចក្តីប្រកាសចំនួនពីរ។ សេចក្តីប្រកាសទីមួយ ទាក់ទងនឹងធនធានក្នុងតំបន់ខ្ពង់រាបបាតសមុទ្រ (Continental Shelf) និង សេចក្តីប្រកាសទីពីរ ស្តីពីការនេសាទនៅតំបន់លំហសមុទ្រ (High Sea)។

ក្នុងសេចក្តីប្រកាសទីមួយ សហរដ្ឋអាមេរិកទាមទារធនធានរ៉ែនៅតំបន់ខ្ពង់រាបបាតសមុទ្រ និងដីក្រោមខ្ពង់រាបបាតសមុទ្រលើសពី៣ម៉ៃល៍សមុទ្រ។[10] ក្នុងសេចក្តីប្រកាសនេះក៏បានអះអាងពីយុត្តាធិការរបស់សហរដ្ឋអាមេរិកលើធនធាននៅខ្ពង់រាបបាតសមុទ្រ និងដីក្រោមខ្ពង់រាបបាតសមុទ្រផងដែរ។ រីឯក្នុងសេចក្តីប្រកាសទីពីរវិញ សហរដ្ឋអាមេរិកបានដាក់បញ្ញត្តិលើការនេសាទនៅតំបន់លំហសមុទ្រ (High Sea) ដែលបន្តចេញពីឆ្នេររបស់ខ្លួន ប៉ុន្តែមិនដាក់បញ្ញត្តិទៅលើការធ្វើនាវាចរណ៍នៅតំបន់នោះទេ។

## ផ្នែកទី២ ការកំណត់ព្រំដែនសមុទ្រសម័យបច្ចុប្បន្ន

ការកំណត់ព្រំដែនសមុទ្រសម័យបច្ចុប្បន្ន ដែលលើកយកមកបកស្រាយនៅត្រង់ចំណុចនេះ គឺសំដៅទៅលើការកំណត់ព្រំដែនសមុទ្រដោយអនុលោមទៅតាម អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS III) ។ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS III) បានអនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ នៅទីក្រុងMontego Bay ប្រទេសJamaica ។ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS III) នេះបានកំណត់ដែនសមុទ្រដូចតទៅ៖

[10] http://oceanslaw.blogspot.com/2011/05/brief-outline-of-history-development-of.html (ចូលទស្សនាថ្ងៃទី៤កក្កដា២០១៤)។

**កថាខណ្ឌទី១ បន្ទាត់មូលដ្ឋាន (Baselines)**

ជាគោលការណ៍ដើម្បីកំណត់ដែនសមុទ្រ ចាំបាច់ណាស់ត្រូវតែគូសបន្ទាត់មូលដ្ឋាន។បន្ទាត់មូលដ្ឋាន គឺជាខ្សែបន្ទាត់ទឹកនាចតាមបណ្តោយឆ្នេរ ដែលគេបង្កើតឡើងសម្រាប់វាស់តំបន់សមុទ្រ។ បន្ទាត់មូលដ្ឋានបានបែងចែកជា២ប្រភេទ គឺ**បន្ទាត់មូលដ្ឋានធម្មតា** និង**បន្ទាត់មូលដ្ឋានត្រង់**។

បន្ទាត់មូលដ្ឋានធម្មតា ជាបន្ទាត់ខ្សែទឹកនាចតាមបណ្តោយឆ្នេរដោយមានបញ្ជាក់នៅក្នុងផែនទីមាត្រដ្ឋានខ្នាតធំហើយទទួលស្គាល់ជាផ្លូវការដោយរដ្ឋជាប់ឆ្នេរ។[11]

ចំណែកឯបន្ទាត់មូលដ្ឋានត្រង់វិញ គឺសំដៅទៅលើបន្ទាត់ដែលប្រើនៅពេលដែលឆ្នេរសមុទ្ររបស់រដ្ឋណាមួយ មានលក្ខណៈមិនត្រង់ស្មើ។ បន្ទាត់នេះ ត្រូវបានប្រើដើម្បីគូសភ្ជាប់ចំណុចនៅត្រង់មាត់ឆ្នេរ ឆ្នេរផតជ្រៅ កោះ រដ្ឋប្រជុំកោះ ដីដុះ ថ្មប៉ប្រះទឹក និងសមុទ្រ ព្រមទាំងឆកប្រវត្តិសាស្ត្រជាដើម។[12]

**កថាខណ្ឌទី២ ដែនទឹកផ្ទៃក្នុង (Internal Waters)**

ដែនទឹកផ្ទៃក្នុង គឺជាតំបន់សមុទ្រដែលស្ថិតនៅផ្នែកខាងឆ្នេរសមុទ្ររបស់រដ្ឋ ហើយត្រូវរាប់បញ្ចូលដូចជាកំពង់ផែ ឆក ពាម ដែសមុទ្រ។ល។ រដ្ឋជាប់ឆ្នេរមានសិទ្ធិ និងអធិបតេយ្យភាពពេញលេញក្នុងការគ្រប់គ្រងតំបន់នេះ។ នាវាបរទេសត្រូវសុំការអនុញ្ញាតពីរដ្ឋជាប់ឆ្នេរ មុននឹងឆ្លងកាត់តំបន់ដែនទឹកផ្ទៃក្នុង។ លើសពីនេះទៅទៀត រដ្ឋជាប់ឆ្នេរអាចប្រើប្រាស់នូវអំណាចយុត្តាធិការទាំងផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌទៅលើនាវាបរទេសទាំងឡាយណាដែលធ្វើនាវាចរណ៍ឆ្លងកាត់តំបន់ដែនទឹកផ្ទៃក្នុងនេះ។[13]

**កថាខណ្ឌទី៣ សមុទ្រដែនដី (Territorial Sea)**

សមុទ្រដែនដី ជាតំបន់សមុទ្រដែលវាស់ចេញពីបន្ទាត់មូលដ្ឋានឆ្ពោះទៅកាន់លំហសមុទ្រមានចម្ងាយ ១២ម៉ៃល៍សមុទ្រ (ស្មើនឹង ២២គីឡូម៉ែត្រ)។នៅក្នុងតំបន់នេះរដ្ឋជាប់ឆ្នេរមានអធិបតេយ្យភាពលើដែនទឹក លំហអាកាស បាតសមុទ្រ និងដីក្រោមបាតសមុទ្រ។ អាស្រ័យហេតុនេះហើយ រដ្ឋជាប់ឆ្នេរមានសិទ្ធិទាំងស្រុងក្នុងការធ្វើអាជីវកម្មនៅបាតសមុទ្រ និងក្នុងដីក្រោមបាតមុទ្រ។[14] ការធ្វើនាវាចរណ៍របស់នាវាបរទេសនៅក្នុងតំបន់សមុទ្រដែនដី គឺមានកំរិត ហើយការហោះនៅខាងលើសមុទ្រដែនដីត្រូវតែមានការអនុញ្ញាតពីរដ្ឋជាប់ឆ្នេរ។

[11] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ៥។

[12] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ៧។

[13] សាស្ត្រាចារ្យ សំរ៉ង វិទ្ធីរង្គ,*នីតិសមុទ្រ* (ភ្នំពេញ៖ រោងពុម្ពអង្គរ, ២០១០), ៨៧។

[14] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ២និង មាត្រា៣។

**កថាខណ្ឌទី៤ តំបន់តភ្ជាប់ (Contiguous Zone)**

តំបន់តភ្ជាប់ ជាតំបន់សមុទ្រដែលវាស់ចេញពីបន្ទាត់មូលដ្ឋានឆ្ពោះទៅកាន់លំហសមុទ្រមានចម្ងាយ២៤ម៉ែល៍សមុទ្រ។ នៅក្នុងតំបន់តភ្ជាប់នេះ រដ្ឋជាប់ឆ្នេរអាចការពារការបំពានច្បាប់ និងបទប្បញ្ញត្តិស្តីពីគយ សារពើពន្ធ អន្តោប្រវេសន៍ ឬសុខាភិបាលរបស់ខ្លួន។ ម្យ៉ាងវិញទៀត រដ្ឋជាប់ឆ្នេរក៏អាចធ្វើការដាក់ទោសទៅលើការបំពានច្បាប់ និងបទប្បញ្ញត្តិដែលកើតឡើងនៅក្នុងតំបន់នេះបានផងដែរ។[15]

នៅក្នុងតំបន់តភ្ជាប់នេះ រដ្ឋដទៃមានសិទ្ធិក្នុងការធ្វើនាវាចរណ៍[16] សិទ្ធិក្នុងការហោះពីលើ ប៉ុន្តែពុំមានសិទ្ធិក្នុងការនេសាទ ការទាញយករ៉ែនោះទេ។ ចំណែកឯសិទ្ធិក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ[17] ការដាក់ខ្សែកាប[18]វិញ រដ្ឋដទៃត្រូវតែមានការព្រមព្រៀងពីរដ្ឋជាប់ឆ្នេរ។

**កថាខណ្ឌទី៥ តំបន់សេដ្ឋកិច្ចផ្តាច់មុខ (Exclusive Economic Zone “EEZ”)**

តំបន់សេដ្ឋកិច្ចផ្តាច់មុខ ជាតំបន់សមុទ្រដែលវាស់ចេញពីបន្ទាត់មូលដ្ឋាន ហើយលាតសន្ធឹងទៅកាន់លំហសមុទ្រមានចម្ងាយ ២០០ម៉ែល៍សមុទ្រ (ស្មើនឹង ៣៧០គីឡូម៉ែត្រ)។ រដ្ឋជាប់ឆ្នេរមានសិទ្ធិពេញលេញក្នុងការរុករក ការធ្វើអាជីវកម្ម ការអភិរក្ស ការចាត់ចែងលើធនធានធម្មជាតិរួមមានទាំងធនធានធម្មជាតិមានជីវិត និងគ្មានជីវិតដែលស្ថិតនៅបាតសមុទ្រ និងដីក្រោមបាតសមុទ្រ។[19] រដ្ឋជាប់ឆ្នេរត្រូវគោរពសិទ្ធិ និង កាតព្វកិច្ចរបស់រដ្ឋដទៃផងដែរ នៅពេលដែលប្រើប្រាស់សិទ្ធិ និងបំពេញកាតព្វកិច្ចនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ។[20]

នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ រដ្ឋទាំងអស់ទោះជារដ្ឋជាប់ឆ្នេរក៏ដោយ ឬរដ្ឋមិនជាប់ឆ្នេរក៏ដោយ គឺមានសេរីភាពក្នុងការធ្វើនាវាចរណ៍ ហោះពីខាងលើ ដាក់ខ្សែកាប ដាក់បំពង់បង្ហូរក្រោមសមុទ្រ ព្រមទាំងការប្រើប្រាស់ផ្សេងទៀតដែលស្របតាមច្បាប់អន្តរជាតិពាក់ព័ន្ធនឹងសេរីភាពទាំងនេះ។[21]

[15] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ៣៣។

[16] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ៥៨, ៨៧, ១១៥។

[17] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ២៤៦។

[18] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ៧៩, ៨៨។

[19] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ៧៩, ៥៦.១។

[20] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ៧៩, ៥៦.២។

[21] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ៧៩, ៥៨.១។

**កថាខណ្ឌទី៦ លំហសមុទ្រអន្តរជាតិ (High Seas)**

លំហសមុទ្រអន្តរជាតិ ជាតំបន់សមុទ្រដែលមិនមែនជាកម្មសិទ្ធិរបស់រដ្ឋណាមួយឡើយ។ គ្រប់បណ្តាប្រទេសទាំងអស់នៅជុំវិញពិភពលោក មានសេរីភាពក្នុងការប្រើប្រាស់តំបន់លំហសមុទ្រអន្តរជាតិ ដែលមានដូចជា ការធ្វើនាវាចរណ៍ ការហោះពីលើ ការដាក់បំពង់បង្ហូរ ការដាក់ខ្សែកាប ការនេសាទ ការស្រាវជ្រាវវិទ្យាសាស្ត្រជាដើម។[22]

រដ្ឋទាំងអស់ត្រូវឈរលើគោលការណ៍ថែរក្សាសន្តិភាព ក្នុងការប្រើប្រាស់តំបន់លំហសមុទ្រអន្តរជាតិ ហើយការប្រើប្រាស់នូវកំលាំងយោធាត្រូវបានហាមឃាត់។

**កថាខណ្ឌទី៧ ខ្ពង់រាបបាតសមុទ្រ (Continental Shelf)**

ខ្ពង់រាបបាតសមុទ្រ ជាដីនៅបាតសមុទ្រដែលដុះបន្តចេញពីដែនដីគោក។ យោងទៅតាមអនុសញ្ញា Montégo Bay នៅឆ្នាំ១៩៨២ ស្តីពី ច្បាប់សមុទ្របានកំណត់តំបន់ខ្ពង់រាបបាតសមុទ្រ ថាតំបន់ខ្ពង់រាបបាតសមុទ្ររបស់បណ្តារដ្ឋជាប់ឆ្នេររួមមានៈ បាតសមុទ្រ និងដីក្រោមបាតសមុទ្រ ដែលស្ថិតនៅហួសពីតំបន់សមុទ្រដែនដីរបស់រដ្ឋជាប់ឆ្នេរ ដែលជាការពន្លយចេញនៃដែនដីគោករបស់រដ្ឋជាប់ឆ្នេរ ចុះទៅក្នុងទឹកសមុទ្រហួតដល់ជំរៅចោតខ្លាំងនៃបាតសមុទ្រ។

យោងទៅតាមអនុសញ្ញាទីក្រុងសឺណែវ (The Geneva Convention) បានកំណត់តំបន់ខ្ពង់រាបបាតសមុទ្រទៅលើធាតុសំខាន់ៗបីដូចជាៈ ស្ថានភាពតំបន់ដែលនៅជិត (Adjacency) ជំរៅ (Depth) ការធ្វើអាជីវកម្ម (Exploitability)។ នៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្រ រដ្ឋជាប់ឆ្នេរមិនអាចពង្រីកចម្ងាយឲ្យហួសដែនកំណត់ ២០០ម៉ៃល៍ពីខ្សែបន្ទាត់មូលដ្ឋាននោះទេ។[23] ករណីដែលគែមចុងបំផុតនៃខ្ពង់រាបបាតសមុទ្រមានប្រវែងលើសពី២០០ម៉ៃល៍សមុទ្រ រដ្ឋជាប់ឆ្នេរមិនអាចធ្វើការកំណត់ប្រវែងលើសពីចំងាយ ៣៥០ម៉ៃល៍សមុទ្របានឡើយ។

នៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្រ រដ្ឋជាប់ឆ្នេរមានសិទ្ធិប្រើប្រាស់នូវអធិបតេយ្យរបស់ខ្លួនដើម្បីរុករក និងធ្វើអាជីវកម្មលើធនធានធម្មជាតិរួមមាន ធនធានរ៉ែ និងធនធានមាន និង គ្មានជីវិតផ្សេងៗនៅបាតសមុទ្រ និងដីក្រោមបាតសមុទ្រ។[24] រដ្ឋដទៃមិនអាចបំពាន ឬជ្រៀតជ្រែកដោយមិនសមហេតុសមផលទៅលើនាវាចរណ៍ ឬសិទ្ធិផ្សេងទៀតរបស់រដ្ឋជាប់ឆ្នេរនោះទេ។[25]

---

[22] 河野真理子、森田章夫 និង 山本良、*国際法* [នីតិអន្តរជាតិ]、បោះពុម្ពលើកទី៤、有斐閣、2007 年、181។

[23] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ៧៦.២។

[24] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ៧៩, ៧៧។

[25] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ១៩៨២, មាត្រា ៧៩, ៧៨.២។

ជារួមមក យើងឃើញថាមុននឹងមានការកំណត់ព្រំដែនសមុទ្រដូចបច្ចុប្បន្ន គឺតាំងពីបុរាណមកក៏មានការកំណត់ព្រំដែនសមុទ្រដែរ។ ប៉ុន្តែគ្រាន់តែការកំណត់ព្រំដែននោះមិនមានតំលៃជាសកលដូចការកំណត់ព្រំដែនសមុទ្រសម័យបច្ចុប្បន្ន។ មានន័យថា ការកំណត់ព្រំដែនសមុទ្រសម័យបុរាណ គឺប្រទេសដែលទទួលស្គាល់មានចំនួនតិច មិនច្រើនដូចការកំណត់នាពេលបច្ចុប្បន្ននេះ។ ទោះជាមានច្បាប់ដែលកំណត់ពីព្រំដែនសមុទ្រក៏ពិតមែន ប៉ុន្តែបញ្ហាវិវាទនៅលើដែនសមុទ្រនៅតែកើតមានឡើងចៀសមិនរួចឡើយ។ ដូច្នេះ បន្ទាប់ពីយើងបានដឹងនូវការកំណត់ព្រំដែនសមុទ្ររួចហើយ ថាតើការដោះស្រាយវិវាទនៅលើដែនសមុទ្រមានលក្ខណៈបែបណាវិញ? នៅក្នុងជំពូកទី២ ខាងក្រោមនេះ យើងនឹងធ្វើការបកស្រាយពីនីតិវិធីនៃការដោះស្រាយវិវាទដែនសមុទ្រ។

# ជំពូកទី២
# ការដោះស្រាយវិវាទដែនសមុទ្រ

ទាក់ទងនឹងការដោះស្រាយវិវាទដែនសមុទ្រនេះ រដ្ឋដែលជាភាគីនៃវិវាទអាចធ្វើការជ្រើសរើសតាមវិធីណាមួយក៏បានដូចជាតាមការចរចាទ្វេភាគី មានការចូលរួមពីភាគីទីបី ឬក៏នាំវិវាទទៅដល់ស្ថាប័នតុលាការអន្តរជាតិណាមួយដែលមានសមត្ថកិច្ចឲ្យជួយដោះស្រាយ។

ក្នុងជំពូកនេះ យើងនឹងធ្វើការបកស្រាយទាក់ទងនឹងវិវាទដែនសមុទ្រដែលមានដូចខាងក្រោមនេះ៖

ផ្នែកទី១ វិវាទដែនសមុទ្រ

ផ្នែកទី២ នីតិវិធីនៃការដោះស្រាយវិវាទដែនសមុទ្រ

## ផ្នែកទី១ វិវាទដែនសមុទ្រ

ក្នុងផ្នែកនេះ យើងនឹងធ្វើការបកស្រាយពីវិវាទដែនសមុទ្រ ថាតើអ្វីទៅជាវិវាទដែនសមុទ្រ? ហើយវិវាទដែនសមុទ្រនេះ កើតឡើងដោយមូលហេតុអ្វីខ្លះ? នៅពេលដែលកើតមានឡើងនូវវិវាទដែនសមុទ្រ តើនាំឲ្យមានផលប៉ះពាល់អ្វីខ្លះ? សំនួរទាំងនេះនឹងមានចម្លើយដូចខាងក្រោមនេះ។

### កថាខណ្ឌទី១ និយមន័យ

តើអ្វីទៅជាវិវាទដែនសមុទ្រ?

ដើម្បីពន្យល់នូវអត្ថន័យនៃ **វិវាទដែនសមុទ្រ** យើងគួរបែងចែកពាក្យនេះចេញជាពីរគឺ ពាក្យ **វិវាទ** និងពាក្យ **ដែនសមុទ្រ**។

តាមន័យអក្សរសាស្ត្រ**វិវាទ**មានន័យថាជាជំណើរទាស់ទែងគ្នា ឬជំណើរឈ្លោះប្រកែកគ្នា។[26]

ចំណែកឯពាក្យ **ដែនសមុទ្រ** យើងអាចធ្វើការបែងចែកចេញជាពីរពាក្យទៀតគឺ ពាក្យ **ដែន** និងពាក្យ **សមុទ្រ**។ យោងទៅតាមអត្ថន័យអក្សរសាស្ត្រ ពាក្យ **ដែន** មានន័យថា រដ្ឋ ឬប្រទេស ឬអាណាខេត្តទាំងមូលដែលនៅក្នុងអំណាចការត្រួតត្រារបស់រាជការសម្រាប់ផែនដីនីមួយៗ។[27]រីឯពាក្យ **សមុទ្រ**វិញ តាមអត្ថន័យអក្សរសាស្ត្រត្រូវបានពន្យល់ថា ជាអន្លង់ទឹកធំធេងជ្រាលជ្រៅល្ហល្ហេវលន្លឹមបាត់ត្រើយដែលមានអំបិល ឬរសជាតិប្រៃស្មើភាគគ្នានឹងទឹក។[28]

ដូច្នេះ **វិវាទដែនសមុទ្រ** នៅត្រង់នេះចង់មានន័យថា គឺជាការទាស់ទែងគ្នារវាងរដ្ឋមួយជាមួយរដ្ឋមួយទៀត ដែលទាក់ទងទៅនឹងការគ្រប់គ្រងលំហាទឹកប្រៃល្វឹងល្វើយ ឬសមុទ្រ។

---

[26] សម្តេចសង្ឃរាជ ជួន ណាត, *វចនានុក្រមខ្មែរ ភាគទី១និង២* (ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧) , ១១៩៩។

[27] សម្តេចសង្ឃរាជ ជួន ណាត, *វចនានុក្រមខ្មែរ ភាគទី១និង២* (ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧) , ៣១៣។

[28] សម្តេចសង្ឃរាជ ជួន ណាត, *វចនានុក្រមខ្មែរ ភាគទី១និង២* (ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧) , ១២៨៥។

តាមន័យនីតិសាស្ត្រវិញ ដោយយោងតាមការផ្តល់និយមន័យដោយតុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍( Permanent Court of International Justice "PCIJ")**វិវាទ** គឺជាការមិនព្រមព្រៀងគ្នាលើទស្សនៈនៃច្បាប់ ឬ អង្គហេតុដែលជាជម្លោះនៃទស្សនៈច្បាប់ ឬ ផលប្រយោជន៍រវាងមនុស្សពីរនាក់។

**កថាខណ្ឌទី២ កត្តាដែលនាំឲ្យមានវិវាទដែនសមុទ្រ**

សមុទ្រ ជាលំហាទឹកដ៏ធំល្វឹងល្វើយដែលជាទីកន្លែងមួយសំបូរបែបទៅដោយធនធានធម្មជាតិជាច្រើនប្រភេទមានដូចជា ប្រេង ឧស្ម័នធម្មជាតិ ធនធានមាននិងគ្មានជីវិត ព្រមទាំងធនធានជាច្រើនទៀត។ ដោយសារតែមូលហេតុនេះហើយ ទើបធ្វើឲ្យបណ្តាប្រទេសទាំងអស់នៅលើពិភពលោក តែងតែប្រាថ្នាចង់បានធនធានទាំងនេះយកមកជាផលប្រយោជន៍របស់ខ្លួន ក្នុងការអភិវឌ្ឍវិស័យនានាដើម្បីធ្វើឲ្យប្រទេសរបស់ខ្លួនមានភាពជឿនលឿន។ ការស្វែងរកផលប្រយោជន៍នៅលើលំហាសមុទ្ររបស់បណ្តាប្រទេសទាំងនេះតែងតែមានការកើតឡើងនូវវិវាទជាហូរហែរ ដែលវិវាទទាំងនោះមានប្រភពនិងរូបភាពផ្សេងៗគ្នាដូចជា៖

- វិវាទទាក់ទងនឹងការកំណត់ដែនសមុទ្រ
- វិវាទទាក់ទងនឹងដែននេសាទ
- វិវាទទាក់ទងនឹងការរុករក និងការធ្វើអាជីវកម្ម
- ការសាកល្បងអាវុធនុយក្លេអ៊ែរ
- ការស្រាវជ្រាវវិទ្យាសាស្ត្រ
- ការធ្វើនាវាចរណ៍
- ការបំពុលបរិស្ថានសមុទ្រ។ល។

ជារួមមកកត្តាសំខាន់ៗចំនួន២ដែលនាំឲ្យមានវិវាទដែនសមុទ្រនោះគឺ ទី១ កត្តាអធិបតេយ្យភាព(Sovereignty) និងទី២ កត្តាសេដ្ឋកិច្ច (Economic)។

ដោយមើលឃើញពីមូលហេតុនៃវិវាទដែនសមុទ្ររួចហើយ យើងពិតជាចង់ដឹងណាស់ថានៅពេលដែលវិវាទដែនសមុទ្រកើតឡើង តើនឹងមានផលវិបាកអ្វីកើតឡើងស្របជាមួយគ្នានោះ? នៅក្នុងកថាខណ្ឌទី៣ខាងក្រោមនេះ នឹងធ្វើការបកស្រាយពីផលវិបាកនៃវិវាទដែនសមុទ្រ។

**កថាខណ្ឌទី៣ ផលវិបាកនៃវិវាទដែនសមុទ្រ**

គ្រប់វិវាទទាំងអស់រមែងតែមាននូវផលវិបាក ដែលនៅក្នុងផលវិបាកនេះយើងឃើញមានទាំងគុណសម្បត្តិ និងគុណវិបត្តិ។ ប៉ុន្តែជាទូទៅយើងសង្កេតឃើញថាគុណវិបត្តិនៃវិវាទ មានច្រើនជាងគុណសម្បត្តិ។ ការខូចខាតដែលបណ្តាលមកពីវិវាទគឺ អាស្រ័យទៅតាមទំហំ និងរយៈពេលនៃ

វិវាទ។ ប្រសិនបើវិវាទមានទំហំធំ ហើយមានរយៈពេលយូរ នោះផលវិបាកនៃវិវាទនោះក៏មានច្រើន ប៉ុន្តែបើវិវាទមានទំហំតូច ហើយមានរយៈពេលខ្លី ផលវិបាកនៃវិវាទក៏មានតិច។យ៉ាងណាមិញដូចជា នៅក្នុងសង្គ្រាមលោកទាំងពីរលើក គឺសង្គ្រាមលោកលើកទី១ (ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨) និង សង្គ្រាមលោកលើកទី២ (ពីឆ្នាំ១៩៣៩ ដល់ឆ្នាំ១៩៤៥) បានបណ្តាលឲ្យមានការខូចខាតជាច្រើន ទាំងជីវិតមនុស្ស សត្វ ថវិកា ហេដ្ឋារចនាសម្ព័ន្ធសង្គមនានា។ល។ បើយើងបែរមកចាប់អារម្មណ៍លើ វិវាទដែនសមុទ្រវិញ ក៏មិនខុសនឹងវិវាទផ្សេងៗទៀតដែរ។ ដូចដែលបានបង្ហាញនៅក្នុងកថាខណ្ឌទី ២ខាងលើរួចហើយអំពីមូលហេតុ ឬ កត្តាដែលនាំឲ្យកើតវិវាទដែនសមុទ្រដែលយើងឃើញថាមូល ហេតុដែលនាំឲ្យមានវិវាទដែនសមុទ្រមានប្រភព និងរូបភាពផ្សេងៗគ្នា។ ដូច្នេះផលវិបាកនៃវិវាទក៏ អាស្រ័យទៅតាមប្រភេទនៃវិវាទដែលកើតមានឡើងនោះ ប៉ុន្តែយើងអាចធ្វើការសន្មតបាន ចំពោះផលវិបាកនៃវិវាទដែនសមុទ្រដែលមានដូចជាៈ

- ប៉ះពាល់ដល់ទំនាក់ទំនងការទូត
- មានការប៉ះទង្គិចគ្នារវាងប្រជាជននិងប្រជាជន
- ប៉ះពាល់ដល់ការធ្វើនាវាចរណ៍
- ប៉ះពាល់ដល់ការរុករក និងធ្វើអាជីវកម្ម
- ប៉ះពាល់ដល់ការនេសាទ
- បំពុលបរិស្ថានសមុទ្រ។ល។

យើងបានដឹងរួចហើយអំពីមូលហេតុ និងផលវិបាកនៃវិវាទនៅលើដែនសមុទ្រ។ ដូច្នេះ តើការ ដោះស្រាយវិវាទនៅលើដែនសមុទ្រមានលក្ខណៈបែបណាវិញ? ក្នុងផ្នែកទី២ខាងក្រោមនេះ យើង នឹងបកស្រាយពីនីតិវិធីនៃការដោះស្រាយវិវាទដែនសមុទ្រ។

## ផ្នែកទី២ នីតិវិធីនៃការដោះស្រាយវិវាទដែនសមុទ្រ

យោងទៅលើមាត្រា២ កថាខណ្ឌទី៣ នៃធម្មនុញ្ញនៃអង្គការសហប្រជាជាតិ បានចែង ថាសមាជិកនៃអង្គការសហប្រជាជាតិត្រូវសម្រួលជម្លោះអន្តរជាតិដោយសន្តិវិធី ដោយសន្តិភាព និង រក្សាសន្តិសុខអន្តរជាតិ ព្រមទាំងថែរក្សាយុត្តិធម៌មិនឲ្យធ្លាក់ចុះក្នុងសេចក្តីអន្តរាយ។ ពោលគឺ រដ្ឋជា សមាជិកអង្គការសហប្រជាជាតិទាំងអស់ត្រូវដោះស្រាយជម្លោះអន្តរជាតិដោយសន្តិវិធី ហើយត្រូវ ធ្វើយ៉ាងណាក៏ដោយមិនត្រូវធ្វើឲ្យការដោះស្រាយជម្លោះនោះប៉ះពាល់ ឬមានគ្រោះថ្នាក់ដល់ សន្តិភាព សន្តិសុខ និងយុត្តិធម៌អន្តរជាតិឡើយ។

**កថាខណ្ឌទី១ សមត្ថកិច្ចយុត្តាធិការដែនដី**

សមត្ថកិច្ចយុត្តាធិការដែនដីដែលលើកយកមកបង្ហាញនៅត្រង់នេះ គឺចង់បង្ហាញអំពីសមត្ថកិច្ចយុត្តាធិការរបស់រដ្ឋជាប់ឆ្នេរ និង សមត្ថកិច្ចយុត្តាធិការរបស់នាវា។ តើរដ្ឋជាប់ឆ្នេរមានសមត្ថកិច្ចយ៉ាងដូចម្តេចខ្លះ? ហើយសមត្ថកិច្ចរបស់នាវាវិញមានអ្វីខ្លះ?

**១.១. សមត្ថកិច្ចយុត្តាធិការរបស់រដ្ឋជាប់ឆ្នេរ**

សមត្ថកិច្ចយុត្តាធិការរបស់រដ្ឋជាប់ឆ្នេរមានដូចជា សមត្ថកិច្ចរបស់រដ្ឋជាប់ឆ្នេរក្នុងការផ្តល់ទង់ជាតិទៅឲ្យនាវា សមត្ថកិច្ចក្នុងតំបន់សមុទ្ររបស់រដ្ឋជាប់ឆ្នេរ សមត្ថកិច្ចរដ្ឋជាប់ឆ្នេរក្នុងការអនុញ្ញាតឲ្យអនុវត្តច្បាប់ដោយរដ្ឋកំពង់ផែ។

**១.១.១. សមត្ថកិច្ចរបស់រដ្ឋជាប់ឆ្នេរក្នុងការផ្តល់ទង់ជាតិឲ្យនាវា**

រដ្ឋទាំងអស់អាចផ្តល់ទង់ជាតិទៅឲ្យនាវាបាន ដោយកំណត់លក្ខខណ្ឌក្នុងការផ្តល់ទង់ជាតិនាវាសម្រាប់ការចុះបញ្ជីនាវាក្នុងសមុទ្រដែនដីរបស់ខ្លួននិងសម្រាប់សិទ្ធិប្រើប្រាស់ទង់ជាតិរបស់ខ្លួន ។ រដ្ឋ និងនាវាត្រូវមានទំនាក់ទំនងពិតប្រាកដ។ លើសពីនេះទៅទៀតរដ្ឋទាំងអស់ត្រូវផ្តល់ឲ្យនាវាដែលខ្លួនផ្តល់សិទ្ធិប្រើប្រាស់ទង់ជាតិនូវឯកសារទាំងឡាយដើម្បីចូលជាធរមាន។[29] ម្យ៉ាងវិញទៀតគ្រប់រដ្ឋទាំងអស់ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពនូវយុត្តាធិការ និងការគ្រប់គ្រងរបស់ខ្លួនលើកិច្ចការរដ្ឋបាល បច្ចេកវិទ្យា និងសង្គម លើនាវាដែលប្រើប្រាស់ទង់ជាតិរបស់ខ្លួន។[30] បន្ថែមពីនេះទៅទៀតរដ្ឋទាំងអស់ត្រូវរក្សាបញ្ជីនាវាដោយមានឈ្មោះ និងភិនភាគរបស់នាវាដែលប្រើប្រាស់ទង់ជាតិរបស់ខ្លួន ព្រមទាំងត្រូវចាត់វិធានការចំពោះនាវាដែលប្រើប្រាស់ទង់ជាតិរបស់ខ្លួនជាចាំបាច់ ដើម្បីធានាបាននូវសុវត្ថិភាពនៅសមុទ្រ។[31]

**១.១.២. សមត្ថកិច្ចក្នុងតំបន់សមុទ្ររបស់រដ្ឋជាប់ឆ្នេរ**

សមត្ថកិច្ចក្នុងតំបន់សមុទ្ររបស់រដ្ឋជាប់ឆ្នេរដែលលើកយកមកបង្ហាញនេះ គឺសំដៅទៅលើយុត្តាធិការលើការការពារ យុត្តាធិការលើការតាក់តែងច្បាប់ និងយុត្តាធិការចាប់បង្ខំ។

**ក. យុត្តាធិការលើការការពារ**

យុត្តាធិការលើការការពារគឺ សំដៅទៅលើការបង្កើតបទប្បញ្ញត្តិដើម្បីការពារ។ ឧទាហរណ៍ៈ អនុលោមតាមអនុសញ្ញាអន្តរជាតិសម្រាប់ការទប់ស្កាត់ជាតិកខ្វក់ចេញពីនាវា (International Convention for the Prevention of Pollution from Ships, 1973 “MARPOL”) រដ្ឋជាប់ឆ្នេរអាច

[29] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ,ឆ្នាំ១៩៨២, មាត្រា ៩១កថាខណ្ឌទី២។

[30] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ឆ្នាំ ១៩៨២, មាត្រា ៩៤ កថាខណ្ឌទី១។

[31] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ឆ្នាំ ១៩៨២, មាត្រា ៩៤ កថាខណ្ឌទី៤។

អនុម័តច្បាប់ និងបទប្បញ្ញត្តិសម្រាប់ការការពារ កាត់បន្ថយ និងគ្រប់គ្រងជាតិកខ្វក់ចេញពីនាវានៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ខ្លួន។

**ខ. យុត្តាធិការលើការដាក់តែងច្បាប់**

រដ្ឋជាប់ឆ្នេរមានសមត្ថកិច្ចក្នុងការអនុម័ត និងប្រកាសឲ្យប្រើប្រាស់ច្បាប់សំខាន់ៗមួយចំនួននៅក្នុងតំបន់សមុទ្រដែលជាអធិបតេយ្យភាពនៃរដ្ឋរបស់ខ្លួន ដូចជាក្នុងតំបន់ដែនទឹកផ្ទៃក្នុង រដ្ឋជាប់ឆ្នេរមានសិទ្ធិ និងអធិបតេយ្យភាពពេញលេញនៅក្នុងតំបន់នេះ។ ចំណែកឯនៅក្នុងតំបន់សមុទ្រដែនដីវិញ រដ្ឋជាប់ឆ្នេរអាចកំណត់លក្ខខណ្ឌ ឬបញ្ញត្តិនានាសម្រាប់នាវាក្នុងការឆ្លងកាត់នៅតំបន់សមុទ្រដែនដីដើម្បីរក្សាសុវត្ថិភាពនៅពេលធ្វើនាវាចរណ៍ ការពារបរិស្ថានសមុទ្រ និងធនធានមានជីវិតនៅសមុទ្រជាដើម។ ចំពោះសមត្ថកិច្ចរបស់រដ្ឋជាប់ឆ្នេរនៅតំបន់តភ្ជាប់វិញ រដ្ឋជាប់ឆ្នេរអាចគ្រប់គ្រងជាចាំបាច់ដើម្បីការពារការបំពានច្បាប់និងបទប្បញ្ញត្តិស្ដីពីគយ សារពើពន្ធ អន្តោប្រវេសន៍ ឬសុខាភិបាលហើយក៏អាចដាក់ទោសទៅលើការបំពានច្បាប់ និងបញ្ញត្តិដែលកើតឡើងនៅក្នុងតំបន់នេះបានផងដែរ។

**គ. យុត្តាធិការចាប់បង្ខំ**

រដ្ឋជាប់ឆ្នេរមានយុត្តាធិការចាប់បង្ខំ ដោយធ្វើការដាក់ទណ្ឌកម្មទៅលើបទល្មើសទាំងឡាយណាដែលកើតមានឡើងនៅក្នុងតំបន់ដែលស្ថិតក្រោមអធិបតេយ្យរបស់ខ្លួន។ ឧទាហរណ៍៖ ក្នុងករណីរឿងឃាតកម្មមួយ ដែលកើតមានឡើងនៅលើនាវាបរទេសដែលចតនៅក្នុងតំបន់ដែនទឹកផ្ទៃក្នុងនៃរដ្ឋជាប់ឆ្នេរ ក្នុងករណីបែបនេះ គឺរដ្ឋជាប់ឆ្នេរអាចឃាត់នាវា ឃាត់មនុស្សលើនាវា និងនាំខ្លួនទៅតុលាការ។

**១.១.៣.សមត្ថកិច្ចរដ្ឋជាប់ឆ្នេរក្នុងការអនុញ្ញាតឲ្យអនុវត្តច្បាប់ដោយរដ្ឋកំពង់ផែ**

រដ្ឋកំពង់ផែ គឺសំដៅទៅលើរដ្ឋដែលអនុញ្ញាតឲ្យនាវាបរទេសមកចូលចតនៅក្នុងកំពង់ផែនៃរដ្ឋរបស់ខ្លួន។

ការអនុវត្តច្បាប់ដោយរដ្ឋកំពង់ផែ គឺសំដៅទៅលើការគ្រប់គ្រងរបស់រដ្ឋកំពង់ផែដែលការគ្រប់គ្រងរបស់រដ្ឋកំពង់ផែមានន័យថា ជាការត្រួតពិនិត្យរបស់រដ្ឋកំពង់ផែទៅលើនាវាបរទេសដែលចតនៅកំពង់ផែរបស់ខ្លួន ដើម្បីបញ្ជាក់ពីស្ថានភាពរបស់នាវានោះ និងពិនិត្យទៅលើសម្ភារៈដែលប្រើប្រាស់លើនាវានោះ ព្រមជាមួយនឹងប្រតិបត្តិការលើនាវា ថាតើនាវានោះជានាវាដែលមានលក្ខណៈត្រឹមត្រូវ ឬក៏ស្របតាមច្បាប់អន្តរជាតិហើយឬនៅ?

ដូច្នេះនៅពេលដែលមានការហូរចេញពីនាវានូវសារធាតុកខ្វក់ ដែលកើតឡើងនៅក្នុងតំបន់ដែនទឹកផ្ទៃក្នុង ឬសមុទ្រដែនដី ឬក៏តំបន់សេដ្ឋកិច្ចផ្តាច់មុខ គឺរដ្ឋជាប់ឆ្នេរអាចស្នើសុំឲ្យរដ្ឋកំពង់ផែចាត់ការបានតាមរយៈការស៊ើបអង្កេតទៅលើនាវានោះបាន។

**១.២. សមត្ថកិច្ចរបស់នាវា**

សញ្ជាតិនាវាអាចសំគាល់បានតាមរយៈទង់ជាតិដែលដោតនៅលើនាវា។នាវាអាចធ្វើដំណើរដោយសេរីនៅតំបន់លំហសមុទ្រអន្តរជាតិដោយស្ថិតនៅក្រោមច្បាប់នៃសញ្ជាតិនាវា។ នាវាមិនអាចផ្លាស់ប្តូរទង់ជាតិរបស់ខ្លួនបានឡើយក្នុងអំឡុងពេលធ្វើដំណើរ ឬ ក្នុងខណៈពេលស្ថិតនៅកំពង់ផែដែលខ្លួនចូលចត លុះត្រាតែក្នុងករណីមានការផ្ទេរកម្មសិទ្ធិពិតប្រាកដ ឬ ផ្លាស់ប្តូរការចុះបញ្ជី។[32] ផ្អែកទៅលើ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ នាវាមានសិទ្ធិក្នុងការឆ្លងកាត់តំបន់សមុទ្រដែនដីនៃរដ្ឋផ្សេងៗបានដោយការឆ្លងកាត់នេះមិនត្រូវធ្វើឲ្យប៉ះពាល់ឬក៏បង្កឲ្យមានការខូចខាតដល់តំបន់សមុទ្រដែនដីនៃរដ្ឋទាំងនោះឡើយ។ នាវាត្រូវគោរពតាមអនុសញ្ញាអន្តរជាតិនានា ដែលមានដូចជា អនុសញ្ញាស្តីពីសុវត្ថិភាពនៃជីវិតនៅសមុទ្រ(Safety of Life at Sea “SOLAS”) បទប្បញ្ញត្តិអន្តរជាតិសម្រាប់ការពារការប្រយុទ្ធគ្នានៅសមុទ្រ(International Regulations for Preventing Collisions at Sea “COLREGS”) ។ល។

បន្ទាប់ពីបានដឹងនូវសមត្ថកិច្ចយុត្តាធិការរបស់រដ្ឋជាប់ឆ្នេរ និងសមត្ថកិច្ចយុត្តាធិការរបស់នាវារួចហើយ សូមយើងបង្វែរចំណាប់អារម្មណ៍ មកចាប់អារម្មណ៍លើការដោះស្រាយវិវាទនៅលើដែនសមុទ្រវិញម្តង ថាតើការដោះស្រាយវិវាទនៅលើដែនសមុទ្រមានដំណើរការយ៉ាងដូចម្តេចទៅ?

**កថាខណ្ឌទី២ ការដោះស្រាយដោយការចរចាទ្វេភាគី**

ការដោះស្រាយវិវាទដោយការចរចាទ្វេភាគី គឺជាវិធីដោះស្រាយវិវាទដោយមានការចូលរួមរបស់ភាគីវិវាទទាំងពីរ។ ការដោះស្រាយវិវាទដោយការចរចាទ្វេភាគីទាមទារឲ្យភាគីវិវាទទាំងពីរមានឆន្ទៈក្នុងការសហការជាមួយគ្នាដើម្បីស្វែងរកនូវដំណោះស្រាយលើបញ្ហាដែលកើតមានឡើង។

ជាទូទៅក្នុងការដោះស្រាយវិវាទដោយការចរចាទ្វេភាគី ត្រូវបានចាប់ផ្តើមឡើងតាមរយៈមធ្យោបាយការទូត ដូចជាមានការចរចារវាងរដ្ឋមន្ត្រីទទួលបន្ទុកគណៈរដ្ឋមន្ត្រី ឬ អាចរហូតដល់ប្រមុខរដ្ឋាភិបាលដើម្បីបន្ថែមលើកិច្ចប្រឹងប្រែងខាងការទូតក៏មាន។

**កថាខណ្ឌទី៣ ការដោះស្រាយដោយមានការចូលរួមពីភាគីទីបី**

នៅពេលដែលការចរចាទ្វេភាគីនៅតែគ្មានដំណោះស្រាយ ភាគីនៃវិវាទក៏អាចអនុញ្ញាតឲ្យមានការចូលរួមរបស់ភាគីទីបីបានដែរ។ ការចូលរួមរបស់ភាគីទីបីអាចធ្វើឡើងតាមវិធីនានាដែល

[32] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ឆ្នាំ ១៩៨២, មាត្រា៩២ កថាខណ្ឌទី១។

មានដូចជា ការផ្តល់កន្លែងចរចា(Good Offices) ការផ្សះផ្សា(Conciliation) ការសម្រុះសម្រួល (Mediation)។

### ៣.១. ការផ្តល់កន្លែងចរចា (Good Offices)

ការផ្តល់កន្លែងចរចា គឺសំដៅទៅលើការជួយសម្រួលលើការចរចាពីសំណាក់ភាគីទីបី ដែលភាគីទីបីផ្តល់នូវសេវាកម្មនានាដល់ភាគីវិវាទដែលមានដូចជា៖ ផ្តល់អ្នកបកប្រែ ទីកន្លែងសម្រាប់ចរចា ការបញ្ជូនសារទៅមករវាងភាគីវិវាទ ធ្វើការស្រាវជ្រាវនិងផ្តល់នូវអង្គហេតុឲ្យភាគីវិវាទជាដើម។ កន្លែងរបស់ភាគីទីបីត្រូវតែជាកន្លែងអព្យាក្រឹត ហើយអាចបង្កើតនិងរក្សាបាននូវបរិយាកាសធូរស្រាលសម្រាប់ការចរចា។

### ៣.២. ការផ្សះផ្សា (Conciliation)

ការផ្សះផ្សា គឺជាវិធីមួយដើម្បីស្វែងរកដំណោះស្រាយវិវាទ ដែលមានការចូលរួមរបស់ភាគីទីបី។ ភាគីទីបីដែលជាអ្នកផ្សះផ្សាមិនអាចចូលរួមក្នុងការចរចា ព្រមទាំងមិនអាចសិក្សាឲ្យបានលម្អិតទៅលើវិវាទ ឬក៏ផ្តល់ការវិនិច្ឆ័យអ្វីនោះទេ។ អ្នកផ្សះផ្សាត្រូវតែអព្យាក្រឹត ឯករាជ្យ ពោលគឺអ្នកផ្សះផ្សាអាចធ្វើការពិចារណាលើជំហររបស់ភាគីវិវាទ ហើយជួយសម្របសម្រួលលើវិវាទដោយផ្តល់នូវដំណោះស្រាយសះជាដើម្បីបញ្ចប់បញ្ហាវិវាទ។

ការផ្សះផ្សា ជាវិធីក្រៅផ្លូវការហើយត្រូវមានការស្ម័គ្រចិត្តពីភាគីវិវាទទាំងសងខាង។ ការផ្សះផ្សាគ្មានការស៊ើបអង្កេតព្រមទាំងរក្សាជាសម្ងាត់។ ការផ្សះផ្សា មិនមានដំណើរការដូចនៅតុលាការនោះទេ គឺគ្មានពាក្យបណ្តឹង គ្មានសេចក្តីសម្រេចចំពោះមុខ ហើយភាគីវិវាទទាំងពីរមានឱកាសបញ្ចេញមតិដើម្បីស្វែងរកដំណោះស្រាយ។[33]

### ៣.៣. ការសម្រុះសម្រួល (Mediation)

ការសម្រុះសម្រួល ជាវិធីមួយដែលមានលក្ខណៈប្រហាក់ប្រហែលនឹងការផ្សះផ្សាដែរ ប៉ុន្តែការសម្រុះសម្រួល មានលក្ខណៈផ្លូវការនិងសកម្មជាងការផ្សះផ្សា។ បញ្ហាកាន់តែពិបាក ការចូលរួមរបស់ភាគីទីបីដែលជាអ្នកសម្រុះសម្រួលកាន់តែសំខាន់។ អ្នកសម្រុះសម្រួលមានតួនាទីសំខាន់ជាងអ្នកផ្សះផ្សា ត្រង់ថាអ្នកសម្រុះសម្រួលអាចធ្វើការសិក្សាឲ្យបានលំអិតទៅលើបញ្ហាវិវាទ អាចចូលរួមក្នុងការចរចា ហើយផ្តល់នូវសំណើជាដំណោះស្រាយផ្លូវការមួយទៅកាន់ភាគីវិវាទ។ ជាទូទៅភាគីវិវាទតែងតែចង់បានការសម្រុះសម្រួលច្រើនជាងការផ្សះផ្សា។

[33] www.monash.edu (ចូលទស្សនាថ្ងៃទី១៦ មិថុនា ២០១៤)។

## កថាខណ្ឌទី៤ ការដោះស្រាយតាមរយៈប្រព័ន្ធតុលាការអន្តរជាតិ

នៅពេលដែលរដ្ឋទាំងអស់បានផ្តល់សច្ចាប័ន ឬ ចុះហត្ថលេខាយល់ព្រមទទួលស្គាល់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ រដ្ឋទាំងនោះមានសេរីភាពក្នុងការជ្រើសរើសសមត្ថកិច្ចតុលាការដើម្បីដោះស្រាយជម្លោះដែលមានដូចជា សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (International Tribunal for the Law of the Sea “ITLOS”) តុលាការយុត្តិធម៌អន្តរជាតិ(International Court of Justice “ICJ”) សាលាក្តីមជ្ឈត្តវិនិច្ឆ័យ(An Arbitral Tribunal) សាលាក្តីមជ្ឈត្តវិនិច្ឆ័យពិសេស (A Special Arbitral Tribunal)។[34]

### ៤.១. សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (International Tribunal for the Law of the Sea “ITLOS”)

សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ ជាស្ថាប័នវិនិច្ឆ័យអន្តរជាតិមួយដែលរដ្ឋទាំងអស់ជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ អាចនាំយករឿងក្តីទាក់ទងនឹងបញ្ហាលើសមុទ្រមកឲ្យសាលាក្តីនេះជួយដោះស្រាយបាន។ តើសាលាក្តីនេះត្រូវបានបង្កើតឡើងដោយរបៀបណា? ហើយមានសមត្ថកិច្ចយុត្តាធិការបែបណាខ្លះ?

#### ៤.១.១. អំពីស្ថាប័ន

សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (International Tribunal for the Law of the Sea “ITLOS”) គឺជាស្ថាប័នតុលាការឯករាជ្យមួយដែលត្រូវបានបង្កើតឡើង ដោយអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រឆ្នាំ១៩៨២។ សាលាក្តីនេះមានទីតាំងនៅទីក្រុងហ៊ែមប៊ើក (Hamburg) ប្រទេសអាល្លឺម៉ង់ (Germany) ។

##### ៤.១.១.១. សមាសភាព

សមាសភាពដែលលើកយកមកបកស្រាយនៅទីនេះ គឺសំដៅទៅលើចៅក្រមនៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ និង ប្រធានចៅក្រម ព្រមទាំងអនុប្រធានចៅក្រម។ តើចៅក្រមនៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រមានចំនួនប៉ុន្មាននាក់? ហើយត្រូវបានជ្រើសរើសដោយរបៀបណា? ចំណែកឯ ប្រធាននិងអនុប្រធានចៅក្រមវិញត្រូវបានជ្រើសរើសរបៀបណាដែរ?

##### ក. ចៅក្រម

សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រមានចៅក្រមចំនួន២១រូប ដែលបានបោះឆ្នោតជ្រើសរើសដោយរដ្ឋជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។ ការបោះឆ្នោតជ្រើសរើសចៅក្រមត្រូវធ្វើឡើងសម្រាប់រយៈពេល៩ឆ្នាំ។ ចៅក្រមទាំងនេះជាជនដែលមានកិត្តិយស

[34] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ឆ្នាំ ១៩៨២, មាត្រា ២៨៧។

ខ្ពង់ខ្ពស់ ហើយជាជនដែលមានយុត្តិធម៌ និងសុចរិត ព្រមទាំងយល់ដឹងច្បាស់លាស់ពីនីតិសមុទ្រ។ ចៅក្រម ត្រូវជ្រើសរើសចេញពីអ្នកតំណាងនៃប្រទេសដែលជាសមាជិក ហើយប្រទេសជាសមាជិក នោះត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិបែងចែកចេញជា៥ភូមិភាគមានដូចជា៖

- បណ្តារដ្ឋនៅភូមិភាគអាហ្វ្រិក (African States)
- បណ្តារដ្ឋនៅភូមិភាគអាស៊ី (Asian States)
- បណ្តារដ្ឋនៅភូមិភាគអឺរ៉ុបខាងកើត (Eastern European States)
- បណ្តារដ្ឋនៅភូមិភាគអាមេរិកឡាទីន និង ការីបៀន (Latin American and Caribbean States)
- បណ្តារដ្ឋនៅភូមិភាគអឺរ៉ុបខាងលិច និង រដ្ឋផ្សេងៗទៀត។

ចៅក្រម ដែលបានជ្រើសរើសមិនអាចជ្រើសចេញពីរដ្ឋដូចគ្នានោះទេ ហើយក្នុងករណីដែលភាគីវិវាទជារដ្ឋរបស់ចៅក្រមណាម្នាក់ ដូច្នេះភាគីវិវាទម្ខាងទៀតអាចធ្វើការជ្រើសរើសចៅក្រមផ្សេងមកជំនួសបាន។[35]

**ខ. ប្រធានចៅក្រម និង អនុប្រធានចៅក្រម (President and Vice-President)**

ប្រធានចៅក្រម និងអនុប្រធានចៅក្រមត្រូវជ្រើសរើសដោយការបោះឆ្នោតជាសម្ងាត់ដោយចៅក្រមរបស់សាលាក្តី។ ប្រធាន និងអនុប្រធានចៅក្រមមានអាណត្តិ៣ឆ្នាំ ហើយអាចឈរឈ្មោះបោះឆ្នោតឡើងវិញបាន។[36] ប្រធានចៅក្រមដឹកនាំកិច្ចការវិនិច្ឆ័យ ចាត់ការលើកិច្ចការរដ្ឋបាល និងជាអ្នកតំណាងក្នុងការទាក់ទងជាមួយរដ្ឋ ឬអង្គភាពផ្សេងៗ ហើយធ្វើជាអធិបតីនៅរាល់កិច្ចប្រជុំទាំងអស់របស់សាលាក្តី។ ក្នុងការបោះឆ្នោត ប្រធានចៅក្រមមានសម្លេងស្មើនឹងសមាជិកដទៃៗទៀតដែរ។[37]

អនុប្រធានចៅក្រម អាចប្រើប្រាស់មុខងាររបស់ខ្លួនធ្វើការជំនួសប្រធានចៅក្រមបាននៅពេលដែលតួនាទីជាប្រធានចៅក្រមនៅទំនេរ ឬអវត្តមានប្រធានចៅក្រម ប៉ុន្តែមានករណីខ្លះអនុប្រធានចៅក្រមក៏មិនអាចជំនួសប្រធានចៅក្រមបានដែរ។[38]

**៤.១.១.២. អង្គជុំនំជម្រះ**

គ្រប់វិវាទទាំងអស់ក៏អាចប្រគល់ទៅឲ្យអង្គជុំនំជម្រះបានដែរ បើសិនជាភាគីវិវាទយល់ព្រម។ អង្គជុំនំជម្រះត្រូវបង្កើតចេញជាប្រភេទផ្សេងៗទៀតដូចជា៖

[35]Compact Media GmbH, *International Tribunal for the Law of the Sea* [សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ] (Hamburg, 2011) , 5។
[36]លក្ខន្តិកៈនៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (Statute of the International Tribunal for the Law of the Sea) មាត្រា ១២។
[37]Compact Media GmbH, *International Tribunal for the Law of the Sea* [សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ] (Hamburg, 2011) , 5។
[38]Compact Media GmbH, *International Tribunal for the Law of the Sea* [សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ] (Hamburg, 2011) , 5។

**ក. អង្គជំនុំជម្រះវិវាទបាតសមុទ្រ (the Seabed Disputes Chamber)**

សាលាក្ដីអន្តរជាតិសម្រាប់នីតិសមុទ្រ មានអង្គជំនុំជម្រះវិវាទបាតសមុទ្រ (the Seabed Disputes Chamber)មួយ មានសមាជិក១១រូប ដែលត្រូវជ្រើសរើសចេញពីសាលាក្ដីអន្តរជាតិសម្រាប់នីតិសមុទ្រ។[39] អង្គជំនុំជម្រះនេះមានយុត្តាធិការផ្ដាច់មុខទៅលើបណ្ដឹងនៃវិវាទ(contentious proceedings) ឬ បណ្ដឹងទាក់ទងនឹងការបកស្រាយច្បាប់(advisory proceedings) ហើយនិងមានយុត្តាធិការទៅលើវិវាទដែលទាក់ទងនឹងការរុករក និង ការធ្វើអាជីវកម្មនៅក្នុងតំបន់បាតសមុទ្រ (exploration and exploitation of the Area)។[40]

**ខ. អង្គជំនុំជម្រះនៃនីតិវិធីសង្ខេប (Chamber of Summary Procedure)**

អង្គជំនុំជម្រះនេះបង្កើតឡើងដោយមានសមាជិក៥រូប និងធ្វើការផ្លាស់ប្ដូរម្ដង២រូប។ ប្រធានចៅក្រម និងអនុប្រធានចៅក្រមនៃសាលាក្ដីអន្តរជាតិសម្រាប់នីតិសមុទ្រក៏ជាសមាជិកនៃអង្គជំនុំជម្រះនេះដែរ។[41]

**គ. អង្គជំនុំជម្រះពិសេសផ្សេងៗទៀត (Other Special Chambers)**

សាលាក្ដីអន្តរជាតិសម្រាប់នីតិសមុទ្រ អាចបង្កើតឲ្យមានអង្គជំនុំជម្រះពិសេសផ្សេងៗទៀតបានផងដែរ ដែលមានដូចជា អង្គជំនុំជម្រះសម្រាប់វិវាទទាក់ទងនឹងការនេសាទ(the Chamber for Fisheries Disputes) អង្គជំនុំជម្រះសម្រាប់វិវាទបរិស្ថានសមុទ្រ(the Chamber for Marine Environment Disputes) និង អង្គជំនុំជម្រះសម្រាប់វិវាទទាក់ទងនឹងការកំណត់ព្រំដែន(the Chamber for Maritime Delimitation Disputes) ជាដើម។[42]

### ៤.១.២. សមត្ថកិច្ចនៃសាលាក្ដីអន្តរជាតិសម្រាប់នីតិសមុទ្រ

សមត្ថកិច្ចនៃសាលាក្ដីអន្តរជាតិសម្រាប់នីតិសមុទ្រ ដែលលើកយកមកបកស្រាយនៅត្រង់នេះ គឺនឹងបកស្រាយពីសមត្ថកិច្ចទទួលពាក្យបណ្ដឹង និងសមត្ថកិច្ចយុត្តាធិការនៃសាលាក្ដីអន្តរជាតិសម្រាប់នីតិសមុទ្រ។

#### ៤.១.២.១. ការទទួលពាក្យបណ្ដឹង

ស្ថាប័នតុលាការនេះមានយុត្តាធិការទៅលើរឿងវិវាទដែលទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញា[43] ហើយតុលាការក៏មានយុត្តាធិការទៅលើសំនុំរឿងទាក់ទងនឹងការទាញយករ៉ែ

[39] សាស្ត្រាចារ្យ សំរ៉ង រិទ្ធីរង្គ, *នីតិសមុទ្រ* (រោងពុម្ពអង្គរ, បោះពុម្ពឆ្នាំ ២០១០), ២៦៩។

[40] Compact Media GmbH, *International Tribunal for the Law of the Sea* [សាលាក្ដីអន្តរជាតិសម្រាប់នីតិសមុទ្រ] (Hamburg, 2011), 7។

[41] Compact Media GmbH, *International Tribunal for the Law of the Sea* [សាលាក្ដីអន្តរជាតិសម្រាប់នីតិសមុទ្រ] (Hamburg, 2011), 7។

[42] Compact Media GmbH, *International Tribunal for the Law of the Sea* [សាលាក្ដីអន្តរជាតិសម្រាប់នីតិសមុទ្រ] (Hamburg, 2011), 7។

[43] Compact Media GmbH, *International Tribunal for the Law of the Sea* [សាលាក្ដីអន្តរជាតិសម្រាប់នីតិសមុទ្រ] (Hamburg, 2011), 1។

នៅបាតសមុទ្រ។[44] រដ្ឋ និងអង្គការអន្តរជាតិដែលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS) មានសិទ្ធិនាំរឿងក្តីទៅដោះស្រាយនៅសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រនេះ។ ចំណែកឯរដ្ឋ ឬ អង្គការអន្តររដ្ឋាភិបាល ឬក៏អង្គភាពឯកជនដែលពុំមែនជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ក៏អាចនាំយករឿងក្តីទៅកាន់សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្របានដែរ ក្នុងករណីដែលភាគីនៃវិវាទនោះព្រមព្រៀងគ្នា។[45]

### ៤.១.២.២. យុត្តាធិការសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ

អនុលោមទៅតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រមានយុត្តាធិការទៅលើវិវាទទាំងអស់ និងពាក្យស្នើសុំទាំងអស់ដែលបានដាក់មកកាន់សាលាក្តី។ ពោលគឺសាលាក្តីមានយុត្តាធិការទាក់ទងនឹងវិវាទ (contentious jurisdiction) និងយុត្តាធិការទាក់ទងនឹងការបកស្រាយច្បាប់ (advisory jurisdiction)។[46]

#### ក. យុត្តាធិការទាក់ទងនឹងវិវាទ (Contentious Jurisdiction)

សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ មានយុត្តាធិការទៅលើវិវាទទាំងអស់ដែលទាក់ទងទៅនឹងការបកស្រាយ ឬក៏ការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ដោយអនុលោមទៅតាមមាត្រា២៩៧ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ និង សេចក្តីថ្លែងការណ៍ដែលកើតចេញពីមាត្រា២៩៨នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។

យោងលើមាត្រា២៩៧ និង សេចក្តីថ្លែងការណ៍ដែលកើតចេញពីមាត្រា២៩៨នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ មិនរារាំងភាគីវិវាទក្នុងការដាក់ពាក្យបណ្តឹងទៅកាន់សាលាក្តីឡើយ។ ហើយលើសពីនេះទៅទៀត ក៏មិនបដិសេធចំពោះយុត្តាធិការរបស់សាលាក្តីដោយផ្អែកលើបញ្ញត្តិទាំងនេះដែរ។

ក្នុងករណីដែលកិច្ចព្រមព្រៀងផ្សេងទៀតបានកំណត់ថា សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រមានយុត្តាធិការដោះស្រាយវិវាទ នោះសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រក៏អាចទទួលវិវាទនោះមកដោះស្រាយបានដែរ។[47]

---

[44] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ឆ្នាំ១៩៨២, មាត្រា ១៨៧។

[45] Compact Media GmbH, *International Tribunal for the Law of the Sea* [សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ] (Hamburg, 2011) , 1។

[46] www.itlos.org (ចូលទស្សនាថ្ងៃទី២២ មិថុនា ២០១៤)។

[47] www.itlos.org (ចូលទស្សនាថ្ងៃទី២២ មិថុនា ២០១៤)។

### ខ. យុត្តាធិការទាក់ទងនឹងការបកស្រាយច្បាប់ (Advisory Jurisdiction)

អង្គជុំនំជម្រះវិវាទបាតសមុទ្រ(the Seabed Dispute Chamber) មានសមត្ថកិច្ចផ្តល់យោបល់ផ្នែកច្បាប់ ដែលទាក់ទងទៅនឹងសកម្មភាពរបស់មហាសន្និបាត ឬ ក្រុមប្រឹក្សានៃអាជ្ញាធរបាតសមុទ្រអន្តរជាតិ។[48]

ចំណែកឯសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រវិញ ក៏អាចផ្តល់យោបល់ផ្នែកច្បាប់បានផងដែរ ប្រសិនបើកិច្ចព្រមព្រៀងអន្តរជាតិណាមួយ ទាក់ទងនឹងគោលបំណងនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។[49]

### ៤.១.៣. នីតិវិធីនៅសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ

នីតិវិធីនៅសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រមានចែងនៅក្នុង អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ(United Nations Convention on the Law of the Sea) លក្ខន្តិកៈនៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ(the Statute of the Tribunal) ច្បាប់របស់សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ(Rule of the Tribunal) ដំណោះស្រាយនៃការអនុវត្តចំពោះការវិនិច្ឆ័យផ្ទៃក្នុងរបស់សាលាក្តី (the Resolution on the Internal Judicial Practice of the Tribunal) គោលការណ៍ណែនាំស្តីពីការរៀបចំ និងការបង្ហាញរឿងក្តីនៅមុខសាលាក្តី (the Guidelines concerning the Preparation and Presentation of Cases before the Tribunal)។

ជាទូទៅ នៅពេលដាក់ពាក្យបណ្តឹងទៅកាន់សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រត្រូវឆ្លងកាត់ពីរដំណាក់កាល គឺដំណាក់កាលសរសេរ (written) និង ដំណាក់កាលសម្ភាសន៍ផ្ទាល់មាត់ (oral)។ [50] លើសពីនេះទៅទៀត ការដាក់ពាក្យបណ្តឹងអាចដាក់នៅពេលណាក៏បាន ហើយមិនចាំបាច់ចំណាយថវិកានោះទេ។[51]

ក្នុងករណីដែលភាគីវិវាទមានសំណើទាក់ទងនឹងការកែប្រែ ឬក៏ចង់បន្ថែមទៅលើច្បាប់ស្តីពីនីតិវិធីនោះ ភាគីវិវាទអាចធ្វើការស្នើសុំទៅកាន់សាលាក្តី ឬអង្គជុំនំជម្រះវិវាទបាតសមុទ្របាន ប្រសិនបើសាលាក្តីឬអង្គជុំនំជម្រះវិវាទបាតសមុទ្រយល់ថាការស្នើសុំសមស្របទៅនឹងកាលៈទេសៈនៃរឿងក្តី។[52]

[48]អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ឆ្នាំ ១៩៨២, មាត្រា១៩១។

[49]ច្បាប់នៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (Rules of the Tribunal), ២០០៩, មាត្រា ១៣៨។

[50]ច្បាប់នៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (Rules of the Tribunal), ២០០៩, មាត្រា ៤៤ កថាខណ្ឌ១។

[51]ច្បាប់នៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (Rules of the Tribunal), ២០០៩, មាត្រា ៤៩។

[52] ច្បាប់នៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (Rules of the Tribunal), ២០០៩, មាត្រា ៤៨។

ភាសាចំនួន២ ត្រូវបានប្រើប្រាស់ជាផ្លូវការនៅសាលាក្តី គឺភាសាអង់គ្លេសនិងភាសាបារាំង។ ភាគីវិវាទក៏អាចប្រើប្រាស់ភាសាផ្សេងក្រៅពីភាសាអង់គ្លេស និងភាសាបារាំងបានដែរ នៅពេលឆ្លើយ(pleading) ក្នុងសវនាការ ឬក៏មានឯកសារបន្ថែមផ្សេងទៀត (documents annexed) ប៉ុន្តែក៏ត្រូវមានការបកប្រែបញ្ជាក់ជាភាសាអង់គ្លេស ឬភាសាបារាំងភ្ជាប់ជាមួយដែរ។[53]

បណ្តឹងផ្ទាល់មាត់(oral proceedings) ក៏ត្រូវប្រើប្រាស់ជាភាសាអង់គ្លេស និងភាសាបារាំងដែរ ប៉ុន្តែក៏អាចប្រើប្រាស់ភាសាផ្សេងទៀតក្រៅពីភាសាទាំង២នេះ ឲ្យតែភាគីនៃវិវាទរៀបចំឲ្យមានការបកប្រែទៅកាន់ភាសាអង់គ្លេស ឬភាសាបារាំង។[54]

រាល់ព័ត៌មានទាំងឡាយដែលទាក់ទងនឹងរឿងក្តី ហើយបញ្ជូនទៅឲ្យសាលាក្តីត្រូវផ្ញើទៅឲ្យអ្នកកាន់កាប់បញ្ជី(Registrar)។

### ៤.២. តុលាការយុត្តិធម៌អន្តរជាតិ (International Court of Justice "ICJ")

តុលាការយុត្តិធម៌អន្តរជាតិ(International Court of Justice "ICJ") ជាស្ថាប័នតុលាការអន្តរជាតិមួយ ដែលមានចៅក្រមឯករាជ្យពីប្រទេសកំណើតរបស់ខ្លួន ហើយចៅក្រមទាំងនោះជាជនដែលមានសមត្ថភាព សីលធម៌ អាកប្បកិរិយាខ្ពង់ខ្ពស់។ ម្យ៉ាងវិញទៀត យើងក៏អាចនិយាយបានថា តុលាការអន្តរជាតិមួយនេះ ជាស្ថាប័នជុំនំជម្រះក្តីដ៏សំខាន់មួយនៃអង្គការសហប្រជាជាតិ។ ចំពោះដំណើរការ និងការប្រព្រឹត្តទៅនៃស្ថាប័នតុលាការមួយនេះ គឺអនុលោមទៅតាមលក្ខន្តិកៈ (លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ "Statute of the International Court of Justice")។[55]

#### ៤.២.១. អំពីស្ថាប័ន

តុលាការយុត្តិធម៌អន្តរជាតិ(International Court of Justice "ICJ") បង្កើតឡើងនៅខែមីនា ឆ្នាំ១៩៤៥ ដោយធម្មនុញ្ញអង្គការសហប្រជាជាតិ(Charter of the United Nations) ហើយចាប់ផ្តើមបំពេញការងារនៅខែមេសា ឆ្នាំ១៩៤៦។ តុលាការមានទីតាំងស្ថិតនៅវិមានសន្តិភាព (the Peace Palace) ទីក្រុងឡាអេ(The Hague) ប្រទេសហូឡង់(Netherlands)។

តុលាការយុត្តិធម៌អន្តរជាតិ ជាស្ថាប័នដ៏សំខាន់មួយក្នុងចំណោមស្ថាប័នទាំង៦របស់អង្គការសហប្រជាជាតិ ហើយជាស្ថាប័នតែមួយគត់ដែលមិនមានទីតាំងនៅទីក្រុងញូយ៉ក (New York) សហរដ្ឋអាមេរិក។ តុលាការមានចៅក្រមចំនួន ១៥រូប និងមានស្ថាប័នរដ្ឋបាល ជាជំនួយការផងដែរ ។ ភាសាដែលប្រើប្រាស់ជាផ្លូវការនៅតុលាការគឺ ភាសាបារាំង និងភាសាអង់គ្លេស។

[53] ច្បាប់នៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (Rules of the Tribunal), ២០០៩, មាត្រា ៦៤ កថាខណ្ឌ ២ និង ៣។

[54] ច្បាប់នៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (Rules of the Tribunal), ២០០៩, មាត្រា ៨៥។

[55] លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ, មាត្រា ១។

**៤.២.១.១ សមាសភាព**

សមាសភាពនៃតុលាការយុត្តិធម៌អន្តរជាតិ គឺយើងគ្រាន់តែបកស្រាយពីចៅក្រម និងប្រធាន និងអនុប្រធានចៅក្រមតែប៉ុណ្ណោះ។ តើចៅក្រមនៅតុលាការយុត្តិធម៌អន្តរជាតិមានចំនួនប៉ុន្មាននាក់ ហើយជ្រើសរើសដោយរបៀបណា? ចំណែកប្រធានចៅក្រម និងអនុប្រធានចៅក្រមវិញត្រូវជ្រើសរើសដោយរបៀបណាដែរ?

**ក. ចៅក្រម**

ចៅក្រមនៅតុលាការយុត្តិធម៌អន្តរជាតិមានចំនួន ១៥រូប ដែលត្រូវបោះឆ្នោតជ្រើសរើសសំរាប់រយៈពេល៩ឆ្នាំ ហើយចៅក្រមទាំងនេះអាចឈរឈ្មោះបោះឆ្នោតសារជាថ្មីបានផងដែរ។ ចៅក្រម ត្រូវបោះឆ្នោតជ្រើសរើសដោយមហាសន្និបាតអង្គការសហប្រជាជាតិ (the General Assembly) និង ក្រុមប្រឹក្សាសន្តិសុខ (the Security Council)។ ការបោះឆ្នោតដោយមហាសន្និបាតអង្គការសហប្រជាជាតិ និង ក្រុមប្រឹក្សាសន្តិសុខអាចធ្វើឡើងក្នុងពេលជំណាលគ្នាក៏បាន ពេលខុសគ្នាក៏បាន។[56] ក្នុងករណីដែលមានចៅក្រមណាម្នាក់ទទួលមរណភាព ឬក៏ប្តូរការងារថ្មីក្នុងកំឡុងពេលដែលចៅក្រមរូបនោះមិនទាន់ផុតអាណត្តិរបស់គាត់នៅឡើយ ត្រូវតែមានការរៀបចំឲ្យមានការបោះឆ្នោតពិសេសមួយឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ដើម្បីជ្រើសរើសចៅក្រមថ្មីមកជំនួសអាណត្តិដែលមិនទាន់ចប់នៅឡើយនោះ។[57]

ក្នុងចំណោមចៅក្រមទាំងអស់ មិនអាចមានចៅក្រមពីរនាក់ដែលមកពីរដ្ឋដូចគ្នានោះទេ។ ការបោះឆ្នោតជ្រើសរើសចៅក្រមត្រូវបានគេជ្រើសរើសចេញពីអ្នកតំណាងរដ្ឋនានា ដែលជាសមាជិកតាមភូមិភាគនីមួយៗដូចជា ទ្វីបអាហ្វ្រិកចំនួន៣រូប ទ្វីបអាមេរិកឡាទីនចំនួន២រូប ទ្វីបអាស៊ីចំនួន៣រូប ទ្វីបអឺរ៉ុបខាងលិចចំនួន៥រូប ហើយនិងបណ្តារដ្ឋផ្សេងទៀតដូចជា ប្រទេសកាណាដា (Canada) សហរដ្ឋអាមេរិក(the United States) អូស្ត្រាលី(Australia) និងញូហ្សឺឡែន(New Zealand) និងអឺរ៉ុបខាងកើត ដែលរួមមានទាំងប្រទេសរ៉ូស្ស៊ី។

---

[56] The UN Department of Public Information, *The International Court of Justice, Questions and answers about the principal judicial organ of the United Nations* [តុលាការយុត្តិធម៌អន្តរជាតិ, សំនួរនិងចម្លើយអំពីគោលការណ៍វិនិច្ឆ័យនៃអង្គការសហប្រជាជាតិ] (New York, 2000), 12។

[57] The UN Department of Public Information, *The International Court of Justice, Questions and answers about the principal judicial organ of the United Nations* [តុលាការយុត្តិធម៌អន្តរជាតិ, សំនួរនិងចម្លើយអំពីគោលការណ៍វិនិច្ឆ័យនៃអង្គការសហប្រជាជាតិ] (New York, 2000), 13។

សមាជិកនៃតុលាការយុត្តិធម៌អន្តរជាតិទទួលបានប្រាក់ខែប្រចាំឆ្នាំចំនួន ១៦០ ០០០ដុល្លារសហរដ្ឋអាមេរិក(នៅឆ្នាំ២០០០)។ [58] ប្រាក់ខែរបស់សមាជិកតុលាការត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ហើយសមាជិកតុលាការត្រូវបានរួចពន្ធ។

**ខ. ប្រធាន និងអនុប្រធានចៅក្រម (President and Vice-President)**

ប្រធាន និង អនុប្រធានចៅក្រមនៃតុលាការយុត្តិធម៌អន្តរជាតិ ត្រូវបោះឆ្នោតជ្រើសរើសដោយសមាជិកចៅក្រមជារៀងរាល់៣ឆ្នាំម្តង ដែលការបោះឆ្នោតជ្រើសរើសនេះត្រូវធ្វើឡើងជាសម្ងាត់និងជ្រើសរើសដោយសម្លេងភាគច្រើនដាច់ខាត ហើយមួយវិញទៀតការជ្រើសរើសនេះមិនរើសអើងសញ្ជាតិនោះទេ។[59]

ប្រធានចៅក្រម ជាអ្នកដឹកនាំការងាររបស់តុលាការ និងជាអ្នកគ្រប់គ្រងផ្នែករដ្ឋបាល ហើយលោកធ្វើការទាំងអស់នេះជាមួយនឹងជំនួយការ និងគណៈកម្មាធិការផ្សេងទៀត។ ចំណែកឯអនុប្រធានចៅក្រមវិញត្រូវធ្វើការជំនួសប្រធានចៅក្រម នៅពេលដែលប្រធានចៅក្រមអវត្តមាន ឬក៏តំណែងប្រធានចៅក្រមនៅទំនេរ។

**៤.២.១.២. អង្គជំនុំជម្រះ**

តុលាការយុត្តិធម៌អន្តរជាតិ មានអង្គជំនុំជម្រះអចិន្ត្រៃយ៍ និងបណ្តោះអាសន្ន។ តាមរយៈលក្ខន្តិកៈរបស់តុលាការ បានបង្កើតឲ្យមានអង្គជំនុំជម្រះនីតិវិធីសង្ខេប (Chamber of Summary Procedure) ដែលមានចៅក្រមចំនួន៥រូប សំរាប់ដោះស្រាយបញ្ហាពាណិជ្ជកម្មឲ្យបានលឿន។ សមាជិកនៃអង្គជំនុំជម្រះនេះរួមមានប្រធាន និងអនុប្រធានចៅក្រមចូលរួមផងដែរ។ ចៅក្រមអាចបង្កើតឲ្យមានអង្គជំនុំជម្រះមួយ រឺអាចលើសពីមួយ។ យ៉ាងហោចណាស់ក៏មានអង្គជំនុំជម្រះចំនួន៣ដែរ ដែលអង្គជំនុំជម្រះទាំងនោះបង្កើតឡើងសម្រាប់ដោះស្រាយវិវាទទៅតាមប្រភេទនៃរឿងក្តី។ ចាប់តាំងពីឆ្នាំ១៩៩៣មក តុលាការធ្លាប់បានបង្កើតអង្គជំនុំជម្រះមួយដែលមានសមាជិក៧រូប ដើម្បីដោះស្រាយបញ្ហាបរិស្ថាន ហើយអង្គជំនុំជម្រះនោះជាអង្គជំនុំជម្រះអចិន្ត្រៃយ៍។[60]

[58] The UN Department of Public Information, *The International Court of Justice, Questions and answers about the principal judicial organ of the United Nations* [តុលាការយុត្តិធម៌អន្តរជាតិ, សំនួរនិងចម្លើយអំពីគោលការណ៍វិនិច្ឆ័យនៃអង្គការសហប្រជាជាតិ] (New York, 2000), 16។

[59] The UN Department of Public Information, *The International Court of Justice, Questions and answers about the principal judicial organ of the United Nations* [តុលាការយុត្តិធម៌អន្តរជាតិ, សំនួរនិងចម្លើយអំពីគោលការណ៍វិនិច្ឆ័យនៃអង្គការសហប្រជាជាតិ] (New York, 2000), 14។

[60] The UN Department of Public Information, *The International Court of Justice, Questions and answers about the principal judicial organ of the United Nations* [តុលាការយុត្តិធម៌អន្តរជាតិ, សំនួរនិងចម្លើយអំពីគោលការណ៍វិនិច្ឆ័យនៃអង្គការសហប្រជាជាតិ] (New York, 2000), 22។

### ៤.២.២. យុត្តាធិការ

រឿងក្តីដែលប្រគល់ទៅឲ្យតុលាការយុត្តិធម៌អន្តរជាតិ ត្រូវបញ្ចូលទៅក្នុងបញ្ជីទូទៅ (General List) មួយរបស់តុលាការ។ នៅក្នុងបញ្ជីទូទៅ(General List)នេះមានសរសេរនូវចំណងជើងនៃរឿងក្តី ឈ្មោះនៃភាគីវិវាទ ថ្ងៃដែលប្រគល់រឿងក្តីមកកាន់តុលាការ កាលបរិច្ឆេទនៃសវនាការ ។ល។[61] នៅតុលាការយុត្តិធម៌អន្តរជាតិមានយុត្តាធិការពីរប្រភេទគឺ យុត្តាធិការដោះស្រាយវិវាទ (contentious jurisdiction) និងយុត្តាធិការបកស្រាយច្បាប់ (advisory jurisdiction)។

#### ៤.២.២.១. យុត្តាធិការដោះស្រាយវិវាទ (Contentious Jurisdiction)

យុត្តាធិការដោះស្រាយវិវាទ សំដៅលើការដោះស្រាយវិវាទច្បាប់(disputes of a legal) ដែលរដ្ឋជាភាគីនៃវិវាទប្រគល់មកឲ្យតុលាការ ហើយតុលាការដោះស្រាយវិវាទនេះដោយអនុលោមទៅតាមច្បាប់អន្តរជាតិ។ វិវាទច្បាប់អាចកំណត់អត្ថន័យបានថាជាការប្រឈមមុខ ឬជាការមិនយល់ព្រមទៅលើបញ្ហាច្បាប់ ឬជាជម្លោះ ឬជាការប៉ះទង្គិចគ្នាទៅលើយោបល់ច្បាប់ ឬក៏ជាការប៉ះទង្គិចគ្នាទៅលើផលប្រយោជន៍។[62]

យោងតាមមាត្រា៣៤ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ(Statute of the International Court of Justice) រដ្ឋដែលអាចប្រគល់រឿងក្តីវិវាទទៅកាន់តុលាការ គឺមានតែរដ្ឋដែលជាភាគីនៃវិវាទប៉ុណ្ណោះ។ ចំណែកឯអង្គភាពផ្សេងទៀត ឬក៏បុគ្គលឯកជន ពុំអាចដាក់ពាក្យបណ្តឹងមកកាន់តុលាការបាននោះទេ។ យោងតាមមាត្រា៣៥ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិបានកំណត់ពីលក្ខខណ្ឌសំរាប់រដ្ឋក្នុងការដាក់រឿងក្តីទៅកាន់តុលាការ ។

#### ៤.២.២.២. យុត្តាធិការបកស្រាយច្បាប់ (Advisory Jurisdiction)

យុត្តាធិការបកស្រាយច្បាប់(Advisory Jurisdiction) សំដៅទៅលើការផ្តល់គំនិតយោបល់ ឬក៏បកស្រាយលើសំណួរផ្នែកច្បាប់ទាំងឡាយណាដែលដាក់មកកាន់តុលាការ។

បណ្តឹងទាក់ទងនឹងការបកស្រាយច្បាប់ ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ហើយផ្ញើរទៅកាន់អ្នកកាន់កាប់បញ្ជី(Registrar)។ ក្នុងករណីរឿងក្តីបន្ទាន់ តុលាការត្រូវចាត់វិធានការណ៍ចាំបាច់ណាមួយដើម្បីពន្លឿនបណ្តឹង។

រយៈពេលប្រហែលជា២ ឬ៣ថ្ងៃក្រោយពីបានដាក់បណ្តឹងទៅតុលាការរួចមក តុលាការនឹងធ្វើបញ្ជីព្រាងមួយដែលកត់ពីឈ្មោះរបស់រដ្ឋ ឬ អង្គការអន្តរជាតិដែលបានដាក់ពាក្យបណ្តឹងមកកាន់

[61] The UN Department of Public Information, *The International Court of Justice, Questions and answers about the principal judicial organ of the United Nations* [តុលាការយុត្តិធម៌អន្តរជាតិ, សំនួរនិងចម្លើយអំពីគោលការណ៍វិនិច្ឆ័យនៃអង្គការសហប្រជាជាតិ] (New York, 2000), 24។

[62] www.icj-cij.org (ចូលទស្សនាថ្ងៃទី២២ មិថុនា ២០១៤)។

តុលាការ ហើយតុលាការនឹងចាត់ចែងរកព័ត៌មានទៅលើសំនួរដែលដាក់ដោយរដ្ឋឬអង្គការអន្តរជាតិទាំងនោះ។ រដ្ឋ ឬ អង្គការអន្តរជាតិជាភាគីវិវាទត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងដំណើរការនៃបណ្តឹងប្រសិនបើតុលាការយល់ឃើញថាចាំបាច់។

គំនិតយោបល់របស់តុលាការ គ្មានប្រសិទ្ធភាពចាប់បង្ខំនោះទេ។ ទោះជាគំនិតយោបល់របស់តុលាការគ្មានប្រសិទ្ធភាពចាប់បង្ខំយ៉ាងណាក៏ដោយ ក៏គំនិតយោបល់នេះនៅតែមានតំលៃស្របច្បាប់ ហើយរដ្ឋនិងអង្គការអន្តរជាតិបានចាត់ទុកគំនិតយោបល់នេះជាឧបករណ៍ការពារ ឬរក្សាសន្តិភាព។ ថែមទាំងចាត់ទុកគំនិតយោបល់នេះជាមធ្យោបាយដើម្បីអភិវឌ្ឍនូវច្បាប់អន្តរជាតិ និងធ្វើឲ្យទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋកាន់តែប្រសើរឡើង។

**៤.២.៣. នីតិវិធី**

នៅតុលាការយុត្តិធម៌អន្តរជាតិប្រើប្រាស់ភាសាពីរជាផ្លូវការគឺ ភាសាអង់គ្លេស និងភាសាបារាំង។ ប្រសិនបើគូភាគីព្រមព្រៀងគ្នាប្រើប្រាស់ភាសាណាមួយ ការវិនិច្ឆ័យនឹងប្រើប្រាស់ភាសានោះ។ ប្រសិនបើគ្មានការព្រមព្រៀងគ្នាទេនោះ តុលាការនឹងសម្រេចប្រើប្រាស់ភាសាណាមួយក្នុងចំណោមភាសាទាំងពីរ។[63]

រដ្ឋដែលជាភាគីនៃវិវាទត្រូវមានការព្រមព្រៀងគ្នា ដើម្បីនាំបណ្តឹងទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ។ មូលដ្ឋានគ្រឹះនៃការព្រមព្រៀងនេះមានបីយ៉ាងគឺ (ទី១) ប្រទេសទាំងនោះអាចយល់ព្រមនាំវិវាទទៅតុលាការ។ (ទី២) សន្ធិសញ្ញាដែលប្រទេសទាំងពីរចូលជាភាគីមានចែងអំពីការប្រគល់វិវាទឲ្យតុលាការ។ (ទី៣) រដ្ឋមួយអាចប្រកាសស្របតាមមាត្រា៣៦ កថាខណ្ឌទី២នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ (សេចក្តីថែងអំពីជំរើស "optional clause")។[64]

**៤.៣. សាលាក្តីមជ្ឈត្តវិនិច្ឆ័យ**

**(An Arbitral Tribunal)**

សាលាក្តីមជ្ឈត្តវិនិច្ឆ័យ បានបង្កើតឡើងដោយអនុលោមទៅតាមមាត្រា៣នៃឧបសម្ព័ន្ធទី៧នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។ សាលាក្តីមជ្ឈត្តវិនិច្ឆ័យ មានសមាជិក៥រូបដែលសមាជិកទាំងនេះសុទ្ធតែជាជនដែលមានសមត្ថភាព មានចំណេះដឹងផ្នែកនីតិសមុទ្រអព្យាក្រិត និងសុចរិត។

[63] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ឆ្នាំ ១៩៨២, មាត្រា ៣៩។

[64] សាស្ត្រាចារ្យ សំរ៉ង រិទ្ធីវង្ស, *នីតិសមុទ្រ* (រោងពុម្ពអង្គរ, បោះពុម្ពឆ្នាំ ២០១០), ២៧១។

**៤.៣.១. សមត្ថកិច្ចនៃសាលាក្តីមជ្ឈត្តវិនិច្ឆ័យ**

សាលាក្តីមជ្ឈត្តវិនិច្ឆ័យមានបញ្ជីឈ្មោះមជ្ឈត្តករមួយ ដែលបញ្ជីឈ្មោះនៃមជ្ឈត្តករនោះត្រូវបានរក្សាទុកដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ (the Secretary-General of the United Nations)។ គ្រប់រដ្ឋជាភាគីទាំងអស់ អាចដាក់ឈ្មោះមជ្ឈត្តករចំនួន៤រូប ដែលមជ្ឈត្តករទាំងនោះជាជនដែលមានបទពិសោធន៍ក្នុងវិស័យនីតិសមុទ្រ និង ជាជនដែលអព្យាក្រឹត មានសមត្ថភាពព្រមទាំងសុចរិត។ ឈ្មោះរបស់មជ្ឈត្តករ ដែលបានដាក់នោះនឹងត្រូវបញ្ចូលទៅក្នុងបញ្ជីឈ្មោះមជ្ឈត្តករ។ ប្រសិនបើមជ្ឈត្តករដែលបានដាក់ទៅនោះ មិនគ្រប់ចំនួន៤រូបទេនោះរដ្ឋជាភាគីត្រូវជ្រើសរើសបន្ថែម ។

សាលាក្តីមជ្ឈត្តវិនិច្ឆ័យអាចធ្វើការដោះស្រាយវិវាទដែលភាគីវិវាទប្រគល់មកឲ្យ តាមនីតិវិធីរបស់ខ្លួន ប្រសិនបើភាគីវិវាទគ្មានការព្រមព្រៀងផ្សេងទៀតទេនោះ។[65]សេចក្តីសម្រេចរបស់សាលាក្តីត្រូវធ្វើឡើងតាមសម្លេងភាគច្រើន និងជាសាលក្រមស្ថាពរ ហើយត្រូវតែគោរព។

**៤.៣.២. ភាតព្វកិច្ចនៃភាគីវិវាទ**

ភាគីនៃវិវាទ អាចជ្រើសរើសយកយុត្តាធិការនៃសាលាក្តីមជ្ឈត្តវិនិច្ឆ័យ(arbitral tribunal)ដើម្បីដោះស្រាយវិវាទ ហើយផ្ញើសេចក្តីជូនដំណឹងទៅកាន់គ្រប់ភាគីវិវាទផ្សេងទៀត។[66] លើសពីនេះទៀតសោត ភាគីវិវាទត្រូវរៀបចំឯកសារ ឬព័ត៌មានពាក់ព័ន្ធនានា ដើម្បីជួយសម្រួលដល់កិច្ចការរបស់សាលាក្តី។ រាល់ការចំណាយទៅលើដំណើរការក្តីជាបន្ទុករបស់ភាគីវិវាទ ហើយការចំណាយនោះ ភាគីវិវាទត្រូវចំណាយស្មើៗគ្នា។

**៤.៤. សាលាក្តីមជ្ឈត្តវិនិច្ឆ័យពិសេស**

**(A Special Arbitral Tribunal)**

សាលាក្តីមជ្ឈត្តវិនិច្ឆ័យពិសេសត្រូវបានបង្កើតឡើង ដោយអនុលោមទៅតាមឧបសម្ព័ន្ធទី៨នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។ សាលាក្តីនេះមានសមាជិកចំនួន៥រូប។[67]

**៤.៤.១. សមត្ថកិច្ចនៃសាលាក្តីមជ្ឈត្តវិនិច្ឆ័យពិសេស**

សាលាក្តីមជ្ឈត្តវិនិច្ឆ័យពិសេសមានយុត្តាធិការលើវិវាទទាក់ទងនឹងការបកស្រាយនិងអនុវត្តមាត្រាក្នុងអនុសញ្ញានីតិសមុទ្រដែលទាក់ទងនឹងវិស័យនីមួយៗដូចជាៈ ការនេសាទ ការទប់ស្កាត់ និង អភិរក្សបរិស្ថានសមុទ្រ ការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ ឬនាវាចរណ៍ដោយរាប់បញ្ចូលទាំងសារធាតុកខ្វក់ចេញពីនាវា និងសារធាតុកខ្វក់កើតចេញពីការចាក់ចោល។ សារធាតុកខ្វក់ចេញពី

[65] ឧបសម្ព័ន្ធ៧នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ឆ្នាំ ១៩៨២, មាត្រា ៥។

[66] ឧបសម្ព័ន្ធ៧នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ឆ្នាំ ១៩៨២, មាត្រា ១។

[67] ឧបសម្ព័ន្ធទី៨នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ឆ្នាំ១៩៨២, មាត្រា៣។

នាវារាប់បញ្ចូលទាំងសារធាតុកខ្វក់ដែលបង្កដោយនាវាលិចផងដែរ។ យោងតាមមាត្រា២ នៃឧបសម្ព័ន្ធទី៨ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្របានចែងអំពីបញ្ជីឈ្មោះអ្នកជំនាញការ (Lists of experts)តាមវិស័យនីមួយៗ។ បញ្ជីឈ្មោះអ្នកជំនាញការតាមវិស័យទាំងនេះត្រូវរក្សាទុកទៅតាមស្ថាប័ននីមួយៗដូចជា បញ្ជីឈ្មោះអ្នកជំនាញការខាងវិស័យនេសាទ ត្រូវរក្សាទុកដោយអង្គការស្បៀងអាហារ និង កសិកម្មនៃអង្គការសហប្រជាជាតិ (Food and Agriculture Organization of the United Nations)។ បញ្ជីឈ្មោះអ្នកជំនាញការខាងវិស័យទប់ស្កាត់ និងអភិរក្សបរិស្ថានសមុទ្រត្រូវរក្សាទុកដោយ កម្មវិធីបរិស្ថាននៃអង្គការសហប្រជាជាតិ(United Nations Environment Programme)។ បញ្ជីឈ្មោះអ្នកជំនាញការខាងវិស័យស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រត្រូវរក្សាទុកដោយគណៈកម្មការអន្តររដ្ឋាភិបាលនៃវិទ្យាសាស្ត្រខាងសមុទ្រ (Intergovernmental Oceanographic Commission)។ បញ្ជីឈ្មោះអ្នកជំនាញការខាងវិស័យនាវាចរណ៍ ដោយរាប់បញ្ចូលទាំងសារធាតុកខ្វក់ចេញពីនាវា និង សារធាតុកខ្វក់កើតចេញពីការចាក់ចោលត្រូវបានរក្សាទុកដោយអង្គការមហាសមុទ្រអន្តរជាតិ(International Maritime Organization)។ ចំពោះរឿងក្តីដែលទាក់ទងទៅនឹងវិស័យផ្សេងៗទៀត គឺត្រូវបែងចែកទៅតាមស្ថាប័ននីមួយៗបន្តទៀតតាមមុខជំនាញដ៏សមគួរ។

### ៤.៤.២. ភាតព្វកិច្ចនៃភាគីវិវាទ

ទាក់ទងនឹងបញ្ជីឈ្មោះអ្នកជំនាញការខាងលើ រដ្ឋជាភាគីក៏មានកាតព្វកិច្ចក្នុងការដាក់ឈ្មោះអ្នកជំនាញការរបស់ខ្លួនទៅតាមវិស័យដែរ។ គ្រប់រដ្ឋ ជាភាគីទាំងអស់អាចដាក់ឈ្មោះអ្នកជំនាញការរបស់ខ្លួនចំនួន២រូបតាមវិស័យណាមួយក៏បាន ។ អ្នកជំនាញការដែលរដ្ឋបានដាក់ឈ្មោះនោះត្រូវតែជាជនដែលមានសមត្ថភាពផ្នែកច្បាប់ឬ បច្ចេកវិទ្យា ឬក៏វិទ្យាសាស្ត្រ ហើយជាជនដែលអព្យាក្រិត មានកិត្តិយសខ្ពង់ខ្ពស់ និងសុចរិត។ ឈ្មោះដែលរដ្ឋបានដាក់នោះនឹងត្រូវបង្កើតជាបញ្ជីឈ្មោះមួយយ៉ាងត្រឹមត្រូវ។[68]

ភាគីវិវាទដែលទាក់ទងនឹងការបកស្រាយ ឬអនុវត្តមាត្រាក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ក៏អាចស្នើសុំឲ្យសាលាក្តីមជ្ឈត្តវិនិច្ឆ័យពិសេសធ្វើការស៊ើបអង្កេតស្វែងរកការពិតក្នុងរឿងវិវាទបានដែរ។ ប៉ុន្តែបើសិនជាភាគីវិវាទមានការព្រមព្រៀងផ្សេងពីនេះ សាលាក្តីមជ្ឈត្តវិនិច្ឆ័យមិនធ្វើការស៊ើបអង្កេតឲ្យនោះទេ។ ភាគីនៃវិវាទអាចស្នើសុំឲ្យសាលាក្តីផ្តល់ជា

[68] ឧបសម្ព័ន្ធទី៨នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ឆ្នាំ១៩៨២, មាត្រា២។

អនុសាសន៍ ប៉ុន្តែអនុសាសន៍នេះគ្មានតំលៃចាប់បង្ខំទេ គ្រាន់តែវាជាសេចក្តីរំលឹកដល់ភាគីវិវាទប៉ុណ្ណោះ។[69]

តាមរយៈអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ចែងថាសាលាក្តីអន្តរជាតិចំនួន៤ ដែលមានសមត្ថកិច្ចដោះស្រាយវិវាទដែនសមុទ្រ។ ហើយចាប់តាំងពីការកកើតមានឡើងនូវអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ក៏ដូចជាការកកើតមានឡើងនូវសាលាក្តីទាំង៤ ដូចដែលរៀបរាប់ខាងលើ រហូតមកដល់ពេលនេះ យើងឃើញថាការដោះស្រាយវិវាទនៅលើដែនសមុទ្រមានការប្រសើរឡើងគួរឲ្យកត់សំគាល់។ ដូច្នេះ នៅជំពូកទី៣ខាងក្រោមនេះ យើងនឹងធ្វើការបង្ហាញពីសមិទ្ធផលនៃការដោះស្រាយវិវាទនៅលើដែនសមុទ្រ។ ថាតើមកដល់ពេលនេះសាលាក្តីទាំងនេះបានដោះស្រាយវិវាទនៅលើដែនសមុទ្របានប៉ុន្មានរឿងក្តីហើយ? ហើយការវិនិច្ឆ័យរបស់សាលាក្តីមានលក្ខណៈយ៉ាងដូចម្តេចដែរ?

[69] ឧបសម្ព័ន្ធទី៨នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ឆ្នាំ១៩៨២, មាត្រា៥។

# ជំពូកទី៣
# សមិទ្ធផលនៃការដោះស្រាយលើវិវាទដែនសមុទ្រ

វិវាទដែនសមុទ្រកើតមានឡើងស្ទើរគ្រប់តំបន់នៅជុំវិញពិភពលោកយើងនេះ។ តាមការដកស្រង់រឿងក្តីទាក់ទងនឹងវិវាទដែនសមុទ្រក្នុងគេហទំព័ររបស់តុលាការយុត្តិធម៌អន្តរជាតិ(ICJ) ដោយគិតតាំងពីឆ្នាំ១៩៤៧ រហូតដល់ខែកុម្ភៈ ឆ្នាំ២០១៤ មានចំនួនប្រមាណជា៣០ រឿងក្តីរាប់បញ្ចូលទាំងរឿងក្តីដែលដោះស្រាយរួចរាល់ និងរឿងក្តីដែលកំពុងដំណើរការ។ ចំណែកឯរឿងក្តីនៅសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ(ITLOS)វិញ ដោយគិតចាប់ពីឆ្នាំ១៩៩៧រហូតដល់ខែកុម្ភៈ ឆ្នាំ២០១៤ មានរឿងក្តីប្រមាណជា២២រឿងក្តី។ ដូច្នេះ បើយើងគិតពីចំនួនរឿងក្តីទាក់ទងនឹងវិវាទដែនសមុទ្រនៅតុលាការយុត្តិធម៌អន្តរជាតិ និង នៅសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្ររហូតមកដល់ខែកុម្ភៈ ឆ្នាំ២០១៤នេះ មានប្រមាណជា៥២រឿងក្តី ដោយមិនរាប់បញ្ចូលនូវរឿងក្តីនៅសាលាក្តីមជ្ឈត្តវិនិច្ឆ័យ និងសាលាក្តីមជ្ឈត្តវិនិច្ឆ័យពិសេសឡើយ។

ជាបន្តទៅទៀតនេះ យើងនឹងលើកយករឿងក្តីទាក់ទងនឹងវិវាទដែនសមុទ្រចំនួន៣រឿងក្តីដែលមានបញ្ហាផ្សេងៗពីគ្នាមកធ្វើការបកស្រាយដូចខាងក្រោមនេះ៖

ផ្នែកទី១ វិវាទទាក់ទងនឹងការកំណត់ព្រំដែននៅសមុទ្រខ្មៅរវាងប្រទេសរ៉ូម៉ានី និងអ៊ុយក្រែន

ផ្នែកទី២ វិវាទដែនសមុទ្ររវាងប្រទេសNicaragua និងប្រទេសColombia

ផ្នែកទី៣ បញ្ហាប្រឈមនៃវិវាទសមុទ្រចិនខាងត្បូង

## ផ្នែកទី១ វិវាទទាក់ទងនឹងការកំណត់ព្រំដែននៅសមុទ្រខ្មៅ រវាងប្រទេសរ៉ូម៉ានី (Romania) និង អ៊ុយក្រែន(Ukraine) ឆ្នាំ ២០០៤ (ដោះស្រាយរួចរាល់)[70]

វិវាទរវាងប្រទេសរ៉ូម៉ានី(Romania) និងអ៊ុយក្រែន(Ukraine) ដែលទាក់ទងទៅនឹងការកំណត់ព្រំដែនសមុទ្រគឺស្ថិតនៅប៉ែកពាយព្យ (North-Western)នៃសមុទ្រខ្មៅ(Black Sea)។ វិវាទនេះទាក់ទងនឹងការកំណត់ព្រំដែនសមុទ្រក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់ខ្ពង់រាបបាតសមុទ្រ។

### កថាខណ្ឌទី១ អង្គហេតុ

នៅពេលដែលប្រទេសរ៉ូម៉ានី(Romania) និង អ៊ុយក្រែន(Ukraine)បានព្រមព្រៀងគ្នាទៅលើសន្ធិសញ្ញាស្តីពីកិច្ចសហប្រតិបត្តិការនិងភាពជាអ្នកជិតខាងដ៏ល្អ(Treaty on Good Neighbourliness and Co-operation)នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៩៧នោះ ប្រទេសទាំងពីរក៏បានព្រមព្រៀងគ្នាធ្វើនូវកិច្ចព្រមព្រៀងបន្ថែមមួយដែរ ដែលកិច្ចព្រមព្រៀងបន្ថែមនោះបានតម្រូវឲ្យប្រទេសទាំងពីរធ្វើការចរចា

[70] រឿងក្តីនៃការកំណត់ព្រំដែនសមុទ្រក្នុងសមុទ្រខ្មៅរវាងប្រទេសរ៉ូម៉ានី និង អ៊ុយក្រែន (Maritime Delimitation in the Black Sea (Romania *v.* Ukraine)), 2004។

គ្នាទៅលើការកំណត់ព្រំដែនសមុទ្រក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និង តំបន់ខ្ពង់រាបបាតសមុទ្រនៅសមុទ្រខ្មៅ(Black Sea)។ ការចរចាទាក់ទងនឹងការកំណត់ព្រំដែនសមុទ្រនេះនឹងត្រូវធ្វើឡើងបន្ទាប់ពីពេលដែលសន្ធិសញ្ញាស្តីពីកិច្ចសហប្រតិបត្តិការនិងភាពជាអ្នកជិតខាងដ៏ល្អ ចូលជាធរមានបានរយៈពេល៣ខែ។ សន្ធិសញ្ញាស្តីពីកិច្ចសហប្រតិបត្តិការនិងភាពជាអ្នកជិតខាងដ៏ល្អ បានចូលជាធរមាននៅថ្ងៃទី២២ តុលា ១៩៩៧ ហើយការចរចាទាក់ទងនឹងការកំណត់ព្រំដែនសមុទ្រក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់ខ្ពង់រាបបាតសមុទ្រត្រូវបានធ្វើឡើងនៅខែមករា ឆ្នាំ១៩៩៨។ ការចរចារវាងប្រទេសទាំងពីរបានធ្វើឡើងជាច្រើនលើកជាច្រើនសា ប៉ុន្តែនៅតែមិនអាចឈានដល់ការកំណត់ព្រំដែនសមុទ្រមួយដ៏ល្អប្រសើរឡើយ។

ការទាមទារតំបន់សមុទ្ររវាងរដ្ឋទាំងពីរ គឺមានការខ្វែងគំនិតគ្នាត្រង់ថាតំបន់សមុទ្រដែលប្រទេសរ៉ូម៉ានីទាមទារនោះហាក់ដូចជាចូលចំណែកដែនសមុទ្ររបស់ប្រទេសអ៊ុយក្រែន ចំណែកឯតំបន់សមុទ្រដែលប្រទេសអ៊ុយក្រែនទាមទារវិញ ក៏ដូចជាចូលចំណែកដែនសមុទ្ររបស់ប្រទេសរ៉ូម៉ានីវិញដែរ។[71]

ឆ្នេរដែលនៅក្បែរគ្នានៃប្រទេសរ៉ូម៉ានី និង ប្រទេសអ៊ុយក្រែនត្រូវខ័ណ្ឌដោយទន្លេមួយមានឈ្មោះថា Danube Delta។ ចម្ងាយពីចុងទន្លេDanube Deltaទៅកាន់កោះSerpentsរបស់អ៊ុយក្រែនមានចម្ងាយប្រហែល១២ម៉ៃល៍សមុទ្រ។

តាមរូបភាពក្នុងឧបសម្ព័ន្ធទី២ នៃសារណាបញ្ចប់ការសិក្សានេះបានបង្ហាញថាប្រទេសរ៉ូម៉ានីបានទាមទារតំបន់សមុទ្រពីចំណុចFដល់ចំណុចX ដែលពីចំណុចFដល់ចំណុចXនេះមានចម្ងាយ១២ម៉ៃល៍សមុទ្រ។ នៅចំណុចXនេះ គឺស្ថិតនៅតំបន់សមុទ្រដែនដីនៃកោះSerpents។ លើសពីនេះទៅទៀតប្រទេសរ៉ូម៉ានីក៏បានទាមទារបន្ថែម ដោយគិតចាប់ចំណុចX រហូតដល់ចំណុចT។បន្ទាប់ពីចំណុចTហើយត្រលប់មកខាងត្បូងចំណុចTហើយបញ្ចប់ត្រឹមចំណុចZ។ គួរបញ្ជាក់ថាតំបន់សមុទ្រដែលរ៉ូម៉ានីទាមទារនោះគឺស្ថិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្រ។[72] ចំណែកឯប្រទេសអ៊ុយក្រែនវិញ ការកំណត់ព្រំដែនសមុទ្រ គឺបានបែងចែកជាបីចំណុច ដែលចំណុចទី១នៅចន្លោះជ្រោយSacalin Peninsulaរបស់ប្រទេសរ៉ូម៉ានី និងកោះSerpents ហើយចំណុចទី១នេះបានវាស់កាត់ទៅចំណុចទី២ដែលនៅលើផ្ទៃសមុទ្រហើយវាស់ត្រង់ទៅបញ្ចប់ត្រង់ចំណុចទី៣។[73]

[71] សូមមើលឧបសម្ព័ន្ធទី២។

[72] សូមមើលឧបសម្ព័ន្ធទី២។

[73] សូមមើលឧបសម្ព័ន្ធទី២។

ប្រទេសរ៉ូម៉ានីបាននាំរឿងនេះទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ(ICJ) ឲ្យជួយដោះស្រាយនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤។

**កថាខណ្ឌទី២ អង្គច្បាប់**

តុលាការយុត្តិធម៌អន្តរជាតិ(ICJ)បានធ្វើការដោះស្រាយទៅលើវិវាទរវាងប្រទេសរ៉ូម៉ានី និងប្រទេសអ៊ុយក្រែនដោយធ្វើការពិចារណាតាម៣ដំណាក់កាល។ ដំណាក់កាលទីមួយ បង្កើតបន្ទាត់ចម្ងាយស្មើជាបណ្តោះអាសន្ន(provisional equidistance line) តាមវិធីសាស្ត្របង្ហាញខ្នាតតាមមាត្រសាស្ត្រ(methods that are geometrically objective) ។ ដំណាក់កាលទីពីរ គឺតុលាការពិចារណាទៅលើការថ្លឹងថ្លែង ឬពិចារណាទៅលើការផ្លាស់ប្តូរបន្ទាត់ចម្ងាយស្មើជាបណ្តោះអាសន្ន(provisional equidistance line)ក្នុងគោលបំណងចង់បានការសម្រេចមួយប្រកបដោយសមភាព។ ដំណាក់កាលទីបី គឺត្រួតពិនិត្យបន្ថែមទៀតទៅលើបន្ទាត់ចម្ងាយស្មើជាបណ្តោះអាសន្ន(provisional equidistance line) ថាតើបន្ទាត់នេះមានលក្ខណៈសមរម្យត្រឹមត្រូវ ឬក៏ត្រូវធ្វើការកែតម្រូវឡើងវិញ។

**កថាខណ្ឌទី៣ សេចក្តីសម្រេច**

តុលាការយុត្តិធម៌អន្តរជាតិបានចេញសេចក្តីសម្រេចនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៩ ដោយសម្រេចកំណត់ព្រំដែននៃប្រទេសទាំងពីរ(រ៉ូម៉ានី និងអ៊ុយក្រែន)តាមរយៈ៥ចំណុច។ ចំណុចទី១ គឺបែងចែកព្រំដែនក្រៅ(outer limits)នៃតំបន់សមុទ្រដែនដីរបស់ប្រទេសរ៉ូម៉ានី និង ប្រទេសអ៊ុយក្រែន ដែលការបែងចែកនេះត្រូវបានយល់ព្រមដោយប្រទេសទាំងពីរ(ប្រទេសរ៉ូម៉ានី និង អ៊ុយក្រែន) តាមរយៈសន្ធិសញ្ញាស្តីពីរបបព្រំដែនរបស់រដ្ឋឆ្នាំ២០០៣(State Border Regime Treaty)។ ចន្លោះរវាងចំណុចទី១ ទៅដល់ចំណុចទី២ ព្រំដែននៃតំបន់សមុទ្រដែនដីមានចំងាយ១២ម៉ៃល៍សមុទ្រ។ចំណុចទី២និងទី៣ព្រំដែនសមុទ្រជាបន្ទាត់ចម្ងាយស្មើ(equidistance line) ដែលវាស់ចេញពីតំបន់ឆ្នេរជិតគ្នា(adjacent mainland coats)រវាងប្រទេសរ៉ូម៉ានីនិងប្រទេសអ៊ុយក្រែន។[74] ចំណុចទី៤ និងចំណុចទី៥នោះគឺស្ថិតនៅលើផ្ទៃសមុទ្រដែលនៅចន្លោះឆ្នេររបស់រ៉ូម៉ានី និងតំបន់គ្រីមាន(Crimean Peninsula) របស់ប្រទេសអ៊ុយក្រែន។[75]

[74] សូមមើលឧបសម្ព័ន្ធទី២។

[75] សូមមើលឧបសម្ព័ន្ធទី២។

## ផ្នែកទី២ ទិវាទដែនសមុទ្ររវាងប្រទេសNicaragua និង ប្រទេសColombia ឆ្នាំ២០១៣ (កំពុងដំណើរការដោះស្រាយ)[76]

វិវាទដែនសមុទ្ររវាងប្រទេសNicaragua និងប្រទេសColombia ដែលប្រទេសNicaraguaបានដាក់ពាក្យបណ្ដឹងទៅតុលាការយុត្តិធម៌អន្តរជាតិ(ICJ) នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣។

### កថាខណ្ឌទី១ អង្គហេតុ

នៅក្នុងពាក្យបណ្ដឹងរបស់ប្រទេសNicaragua គឺបានស្នើសុំឲ្យតុលាការវិនិច្ឆ័យនិងប្រកាសឲ្យប្រទេសColombia មិនត្រូវប្រព្រឹត្តអំពើល្មើសដូចជា៖ មិនត្រូវធ្វើការឈ្លានពាន មិនត្រូវបំពានអធិបតេយ្យភាព និងយុត្តាធិការក្នុងតំបន់សមុទ្ររបស់Nicaraguaដែលបានកំណត់រួចរាល់នៅក្នុងសេចក្ដីសម្រេចរបស់ICJ ឆ្នាំ២០១២ និងមិនត្រូវបំពានលើសិទ្ធិរបស់Nicaraguaនោះទេ។ លើសពីនេះទៀតប្រទេសNicaragua បានធ្វើការដកស្រង់នូវសេចក្ដីថ្លែងការណ៍នានារបស់ប្រធានាធិបតី អនុប្រធានាធិបតី មេបញ្ជាការនាវារបស់ប្រទេសColombiaដើម្បីធ្វើឲ្យការទាមទាររបស់ខ្លួនកាន់តែមានលក្ខណៈរឹងមាំ។ ការដកស្រង់សេចក្ដីថ្លែងការណ៍ទាំងនោះ គឺសំដៅដល់ការដកស្រង់សេចក្ដីថ្លែងការណ៍ដែលនិយាយថា ប្រទេសColombiaមិនគោរពតាមសេចក្ដីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ។ ប្រទេសNicaraguaអះអាងថា ដោយសារតែសេចក្ដីថ្លែងការណ៍របស់អាជ្ញាធរជាន់ខ្ពស់នៃប្រទេសColombiaនេះហើយ ទើបធ្វើឲ្យមានការបំពានមកលើអធិបតេយ្យភាពក្នុងសមុទ្រCaribbean។ សេចក្ដីថ្លែងការណ៍ ដែលប្រទេសNicaraguaលើកមកអះអាងនោះ គឺសំដៅទៅដល់បទប្បញ្ញត្តិឆ្នាំ១៩៤៦(Decree 1946)របស់Colombia។ លើសពីនេះទៅទៀត ប្រទេសNicaraguaក៏បានអះអាងបន្ថែមថាសេចក្ដីថ្លែងការណ៍របស់ប្រធានាធិបតីនៃប្រទេសColombia គឺនិយាយទាក់ទងនឹងបទប្បញ្ញត្តិឆ្នាំ១៩៤៦ ដែលបទប្បញ្ញត្តិនេះទាក់ទងនឹងភាពបរិបូរនៃតំបន់តភ្ជាប់(Integral Contiguous Zone) ដែលពណ៌នាអំពីការគ្របដណ្ដប់លើលំហាសមុទ្រដែលធ្វើការពង្រីកពីទីខាងត្បូងទៅទិសខាងជើង។ ការអនុម័តទៅលើបទប្បញ្ញត្តិឆ្នាំ១៩៤៦នេះ ត្រូវបានប្រទេសNicaraguaចាត់ទុកថាជាការបង្កឲ្យមានការប្រព្រឹត្តបទល្មើស និងបង្កើតឲ្យមានទំនាស់រវាងនាវារបស់ប្រទេសColombia និងប្រទេសNicaragua ក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្រនៃសមុទ្រCaribbean។

### កថាខណ្ឌទី២ អង្គច្បាប់

ការជ្រើសរើសយកសមត្ថកិច្ចយុត្តាធិការ គឺប្រទេសNicaraguaអនុលោមទៅតាមមាត្រា៣១ (XXXI)នៃសន្ធិសញ្ញាអាមេរិកកាំងលើការដោះស្រាយវិវាទនៅសមុទ្រប៉ាស៊ីហ្វិក(American Treaty on

[76] រឿងក្ដីរវាងប្រទេសNicaragua និងប្រទេសColombia (Alleged Violations of Sovereign Rights and Maritime Spaces in the Caribbean Sea (Nicaragua v. Colombia), 2013។

Pacific Settlement) ដែលប្រទេសNicaraguaបានចុះហត្ថលេខានៅថ្ងៃទី៣០ មេសា ១៩៤៨ ហើយប្រទេសColombia ក៏ជាភាគីនៃសន្ធិសញ្ញានេះដែរ។

## ផ្នែកទី៣ បញ្ហាប្រឈមនៃវិវាទសមុទ្រចិនខាងត្បូង

សមុទ្រចិនខាងត្បូងមានទំហំប្រមាណជា៣.៥០០.០០០គម² ជាតំបន់សមុទ្រមួយដែលមានទំហំធំលំដាប់ទី៤ និងជាចំណែកមួយរបស់មហាសមុទ្រប៉ាស៊ីហ្វិក។ សមុទ្រចិនខាងត្បូងលាតសន្ធឹងពីទិសនិរតីរហូតដល់ទិសឦសាន ដោយមានព្រំប្រទល់ខាងត្បូងជាប់ឈូងសមុទ្រការីម៉ាតា(Karimata) ខាងជើងជាប់ឈូងសមុទ្រតៃវ៉ាន់ និងចាប់ពីភាគខាងជើងប្រទេសតៃវ៉ាន់លាតសន្ធឹងរហូតដល់ឈូងសមុទ្រភូគៀនរបស់ប្រទេសចិន។[77]

សមុទ្រចិនខាងត្បូង ជាតំបន់សមុទ្រដែលសំបូរទៅដោយសម្បត្តិធម្មជាតិ ដែលត្រូវបានគេអះអាងថាមានរ៉ែប្រេងប្រហែល៤.៥លានគម³ (២៨កោដិបារ៉ែល)។[78] ចំណែកឯឧស្ម័នធម្មជាតិ(gaz) វិញមានប្រមាណជា៧.៥០០លានម³។មួយវិញទៀត សមុទ្រចិនខាងត្បូងក៏ជាតំបន់មួយដែលសំបូរបែបទៅដោយសត្វសមុទ្រ និងជីវចម្រុះគ្រប់ប្រភេទរស់នៅបាតសមុទ្រ។ សមុទ្រចិនខាងត្បូង ក៏ជាតំបន់សមុទ្រមួយដែលមានការធ្វើនាវាចរណ៍យ៉ាងច្រើន ហើយជាប់លំដាប់ថ្នាក់លេខពីរលើពិភពលោក។ បើគិតពីបរិមាណទំនិញពាណិជ្ជកម្មដែលបានដឹកជញ្ជូនតាមតំបន់សមុទ្រចិនខាងត្បូងនេះមានចំនួនច្រើនជាង ៥,០០០,០០០,០០០,០០០ដុល្លារក្នុងមួយឆ្នាំ($5 trillion per year)។[79]

### កថាខណ្ឌទី១ ភាគីនៃវិវាទ

បច្ចុប្បន្ន តំបន់សមុទ្រចិនខាងត្បូង ជាតំបន់ដែលពោរពេញទៅដោយការប្រកួតប្រជែងដណ្តើមផលប្រយោជន៍ និង មានការប៉ះទង្គិចគ្នារវាងសក្តានុពលយោធាជាញឹកញយនៃបណ្តាប្រទេសមួយចំនួនដែលមានដូចជា ចិន តៃវ៉ាន់(កោះតៃវ៉ាន់) វៀតណាម ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ីនិងប្រ៊ុយណេ។[80]

ប្រទេសដែលជាភាគីវិវាទសំខាន់ៗ ឬ លេចធ្លោក្នុងវិវាទនៅសមុទ្រចិនខាងត្បូងមានប្រទេសចិន ដែលត្រូវបានគេចាត់ទុកថាជាប្រទេសបងធំ ឬប្រទេសដែលដើរបង្ករហេតុជាមួយនឹង

[77] ហើស សិរីធន, *សមុទ្រចិនខាងត្បូង ក្នុងចក្ខុនយោបាយរបស់ពួកអ្នកវិភាគយុទ្ធសាស្ត្រអន្តរជាតិ* (ភ្នំពេញ៖ ពន្លឺខ្មែរ, ២០១៣), ១។

[78] ហើស សិរីធន, *សមុទ្រចិនខាងត្បូង ក្នុងចក្ខុនយោបាយរបស់ពួកអ្នកវិភាគយុទ្ធសាស្ត្រអន្តរជាតិ* (ភ្នំពេញ៖ ពន្លឺខ្មែរ, ២០១៣), ៣។

[79] http://www.nbr.org/downloads/pdfs/psa/SouthChinaSea_Roundtable_report.pdf (ចូលទស្សនាថ្ងៃទី៣០ មិថុនា ២០១៤)។

[80] http://www.eu-asiacentre.eu/documents/uploads/pub_112_south_china_sea_background_note.pdf (ចូលទស្សនាថ្ងៃទី២៧ មិថុនា ២០១៤)។

បណ្តាប្រទេសជាសមាជិកអាស៊ានដែលមានដូចជាប្រទេសវៀតណាម ប្រទេសហ្វីលីពីន ប្រទេសម៉ាឡេស៊ី និងប្រទេសប្រ៊ុយណេ។[81]

### ១.១. ប្រទេសចិន

ប្រទេសចិនបានធ្វើការទាមទារអធិបតេយ្យលើសមុទ្រចិនខាងត្បូង ដែលមានវិសាលភាពប្រមាណជា៨០%នៃផ្ទៃសមុទ្រទាំងមូល ដែលការទាមទាររបស់ចិននេះ គឺផ្អែកទៅតាមការកំណត់ក្នុងផែនទីរាងអក្សរ យូ(U) របស់ចិន ឬក៏ហៅម្យ៉ាងទៀតថា nine-dash line ។ ផែនទីរាងអក្សរយូ(U) នេះមាននៅក្នុងរបាយការណ៍ផ្ទៃក្នុងរបស់រដ្ឋាភិបាល ស្តីពីការរៀបចំព្រំប្រទល់របស់ប្រទេសចិនក្នុងឆ្នាំ១៩៣៥។[82] ប្រទេសចិនបានរឹបអូសយកទីប្រជុំកោះប៉ារ៉ាសែល(Paracels)ពីវៀតណាមនៅឆ្នាំ១៩៧៤ ដោយបានសំលាប់ទាហ៊ានរបស់វៀតណាមប្រមាណជាច្រើនជាង៧០នាក់។[83] ក្នុងឆ្នាំ១៩៩២ ចិនបានអនុម័តច្បាប់ស្តីពីតំបន់សមុទ្រដែនដី និង តំបន់តភ្ជាប់ ដែលបង្ហាញពីគោលជំហររបស់ចិនកាន់តែរឹងមាំក្នុងការទាមទារទីប្រជុំកោះទាំងប៉ុន្មាន ដោយផ្អែកទៅតាមផែនទីអក្សរយូ(U)របស់ខ្លួន ដែលទីប្រជុំកោះទាំងនោះរួមមានដូចជា ទីប្រជុំកោះប្រាតាស(Pratas Islands) ទីប្រជុំកោះប៉ារ៉ាសែល (Paracels Islands) ទីប្រជុំកោះMacclesfield Bank និងទីប្រជុំកោះស្ព្រែតលី(Spratly Islands)។[84] ដូច្នេះ ហើយទីប្រជុំកោះស្ព្រែតលី(Spratlys) និងទីប្រជុំកោះប៉ារ៉ាសែល(Paracels) គឺស្ថិតនៅក្រោមអធិបតេយ្យភាពរបស់ប្រទេសចិន។

ប្រទេសចិនបានផ្ញើផែនទីអក្សរយូ(U) ឬក៏ nine-dash line ទៅកាន់អង្គការសហប្រជាជាតិនៅខែឧសភា ឆ្នាំ២០០៩។ ទាក់ទងនឹងផែនទីអក្សរយូ(U)នេះ មន្ត្រីចិនទាំងអស់ហាក់បីដូចជាមានការស្ទាក់ស្ទើរមិនប្រកាសជាចំហរអំពីអធិបតេយ្យភាពរបស់ខ្លួន លើសមុទ្រចិនខាងត្បូងឲ្យមានភាពច្បាស់លាស់ត្រង់កន្លែងណា ឬត្រឹមណាឡើយ ក៏ប៉ុន្តបើមាននរណាប៉ះពាល់មកលើតំបន់នេះគឺចិនប្រតិកម្មជំទាស់យ៉ាងខ្លាំងជាដាច់ខាត។

### ១.២. ប្រទេសចិន និងវៀតណាម

ប្រទេសវៀតណាមតែងតែប៉ះទង្គិចជាមួយនឹងប្រទេសចិនជាញឹកញាប់ ក្នុងបញ្ហាសមុទ្រចិនខាងត្បូង។ ក្នុងឆ្នាំ១៩៥៦ ចិនបានចូលកាន់កាប់ទីប្រជុំកោះប៉ារ៉ាសែលខាងកើត(Eastern Paracels) ហើយថែមទាំងបណ្តេញវៀតណាមចេញទីប្រជុំកោះប៉ារ៉ាសែលខាងលិច (Western Paracels) ទៀត

[81] http://www.nbr.org/downloads/pdfs/psa/SouthChinaSea_Roundtable_report.pdf (ចូលទស្សនាថ្ងៃទី៣០ មិថុនា ២០១៤)។

[82] http://home.comcast.net/-lionelingram/592_DisputesandThreeObjectivesChina.pdf(ចូលទស្សនាថ្ងៃទី៣០ មិថុនា២០១៤)។

[83] http://www.bbc.com/news/world-asia-pacific-13748349 (ចូលទស្សនាថ្ងៃទី១ កក្កដា ២០១៤)។

[84] http://home.comcast.net/-lionelingram/592_DisputesandThreeObjectivesChina.pdf(ចូលទស្សនាថ្ងៃទី៣០ មិថុនា២០១៤)។

ផង ដែលជាហេតុធ្វើឲ្យមានការប៉ះទង្គិចគ្នារវាងកងនាវានៃប្រទេសទាំងពីរនៅខែមករា ឆ្នាំ១៩៧៤។[85]នៅពេលក្រោយមកនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៨៨ក៏កើតមានការប៉ះទង្គិចគ្នាមួយទៀតទាក់ទងនឹងការដណ្ដើមកោះគ្នាបានធ្វើឲ្យនាវាវៀតណាមបានលិច ហើយមនុស្សលើនាវា៧៣អ្នកបានបាត់ខ្លួន។[86]

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសចិនកាន់តែមានភាពរីកធំធាត់ឡើងៗធ្វើឲ្យប្រទេសសមាជិកអាស៊ាន ទាំងអស់ដែលរួមមានទាំងវៀតណាមដែរនោះតែងតែព្យាយាមចៀសវាងពីចិនដោយមិនចង់ប៉ះទង្គិចជាមួយចិនឡើយ។ ទោះជាក្នុងកាលៈទេសៈបែបណាក៏ដោយ វៀតណាមដាច់ខាតមិនចេញមុខបង្ហាញខ្លួនប្រឈមដោយផ្ទាល់ជាមួយចិនឡើយ តែវៀតណាមស្វែងរកគ្រប់មធ្យោបាយក្នុងការទប់ទល់ជាមួយចិនតាមវិធានការផ្សេងៗ ដែលអាចប្រព្រឹត្តទៅបានទាំងការងារការទូត ទាំងសកម្មភាពយោធាក្នុងការដោះស្រាយលើសំណុំរឿងសមុទ្រចិនខាងត្បូងដើម្បីប្រទេសខ្លួន។

ទាក់ទងនឹងផែនទីអក្សរយូ(U)របស់ចិន ប្រទេសវៀតណាមមានប្រតិកម្មយ៉ាងរហ័សដោយវៀតណាមបានធ្វើការបដិសេធមិនទទួលស្គាល់ផែនទីអក្សរយូ(U)នោះ ហើយព្រមទាំងផ្ញើកំណត់ទូតមួយទៅកាន់អង្គការសហប្រជាជាតិ ដើម្បីជំទាស់នឹងផែនទីអក្សរយូ(U)របស់ចិននៅខែឧសភា ឆ្នាំ២០០៩ មួយថ្ងៃបន្ទាប់ពីចិនដាក់ផែនទីអក្សរយូ(U)ទៅកាន់អង្គការសហប្រជាជាតិ។

វិវាទរវាងប្រទេសវៀតណាម និង ចិនបានកើតមានឡើងយ៉ាងខ្លាំងក្រោយពីចិនបានបញ្ជូននាវា និង គ្រឿងចក្រចូលទៅខួងរកប្រេងក្រោមបាតសមុទ្រនៅក្បែរទីប្រជុំកោះប៉ារ៉ាស៊ែល(Paracels) កាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៤។ តាមរយៈសេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសចិនដែលចេញនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៤នេះបានអះអាងថា តំបន់ប្រជុំកោះប៉ារ៉ាស៊ែល(Paracels) ដែលចិនខួងរកប្រេងក្រោមបាតសមុទ្រ គឺស្ថិតនៅក្នុងដែនអធិបតេយ្យភាពរបស់ចិន ហើយទូករបស់វៀតណាមដែលបានចូលមកធ្វើការរំខាន ចំពោះប្រតិបត្តិការខួងរកប្រេងក្រោមបាតសមុទ្រគឺជាសកម្មភាពដោយកម្រោល និងខុសច្បាប់។[87] រដ្ឋាភិបាលវៀតណាមបានជំទាស់នឹងទង្វើរបស់ចិនដោយបានលើកឡើងថា ទីតាំងដែលចិនចូលទៅខួងរកប្រេងនេះស្ថិតនៅក្នុងរង្វង់២០០ម៉ែល៍ពី

---

[85] Leszek Buszynski, *The development of the South China Sea maritime dispute* [វឌ្ឍនភាពនៃវិវាទនៅសមុទ្រចិនខាងត្បូង], (Australia, Australian National University), 6។

[86] Leszek Buszynski, *The development of the South China Sea maritime dispute* [វឌ្ឍនភាពនៃវិវាទនៅសមុទ្រចិនខាងត្បូង], (Australia, Australian National University), 7។

[87] http://www.khmer.rfi.fr/china-says-vietnamese-boats-rammed-its-ships-1400-times (ចូលទស្សនាថ្ងៃទី១ កក្កដា ២០១៤)។

ឆ្នេរសមុទ្ររបស់វៀតណាម និយាយរួម គឺស្ថិតក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ប្រទេសវៀតណាម ដោយអនុលោមតាមនីតិសមុទ្រ។ ការចូលទៅខួងរុករកប្រេងរបស់ចិននៅទីប្រជុំកោះប៉ារ៉ាសែល នេះបានធ្វើឲ្យទំនាក់ទំនងចិន និង វៀតណាមកាន់តែមានភាពតានតឹងឡើងរហូតដល់កើតមាននូវកុប្បកម្មដុតបំផ្លាញរោងចក្រចិន នៅក្នុងប្រទេសវៀតណាមដែលបណ្ដាលឲ្យមានពលរដ្ឋជនជាតិចិនជាច្រើននាក់បានស្លាប់និងរបួស។[88]

ចិនបានផ្ញើកំណត់ទូតមួយទៅកាន់អង្គការសហប្រជាជាតិនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៤ ដោយចោទប្រកាន់ថាសកម្មភាពរបស់វៀតណាមដែលបញ្ជូនទូកឲ្យមករំខាន ចំពោះប្រតិបត្តិការរុករកប្រេងរបស់ចិន គឺជាសកម្មភាពរំលោភបំពានមកលើអធិបតេយ្យភាពរបស់ចិន និង ធ្វើឲ្យមានការរង្គោះរង្គើដល់សេរីភាព និង សុវត្ថិភាពនាវាចរណ៍ ព្រមទាំងធ្វើឲ្យប៉ះពាល់ដល់សន្តិភាពនិងស្ថិរភាពក្នុងតំបន់។[89]

ទំនាក់ទំនងរវាងចិននិងវៀតណាមមានការធ្លាក់ចុះ បន្ទាប់ពីចិនបានប្រតិបត្តិការខួងរកប្រេងនៅតំបន់វិវាទហើយមានការប៉ះទង្គិចគ្នារវាងកងនាវានៃប្រទេសទាំងពីរជាច្រើនលើកច្រើនសា។[90]

### ១.៣. ប្រទេសចិន និងហ្វីលីពីន

រយៈពេល១៧ឆ្នាំដែលប្រទេសហ្វីលីពីន និង ចិនខិតខំស្វះស្វែងរកដំណោះស្រាយទៅលើវិវាទក្នុងតំបន់សមុទ្រភាគខាងលិចនៃប្រទេសហ្វីលីពីនតាមរយៈមធ្យោបាយនានាដូចជា ការចរចាជាទ្វេភាគី ការផ្លាស់ប្ដូរទំនាក់ទំនងការទូត ការផ្លាស់ប្ដូរគំនិតយោបល់ ប៉ុន្តែពុំមានដំណោះស្រាយសមស្របណាមួយកើតឡើងឡើយ។[91]

ហ្វីលីពីនបានធ្វើការបដិសេធនូវផែនទីអក្សរយូ(U) របស់ចិនតាមរយៈកំណត់ទូតមួយដែលបានផ្ញើជូនអង្គការសហប្រជាជាតិនាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១។[92] ហ្វីលីពីនបានបដិសេធចំពោះផែនទីអក្សរយូ(U)របស់ចិនដោយអះអាងថា ការប្រកាសអធិបតេយ្យភាពលើតំបន់សមុទ្រចិនខាងត្បូងរបស់អាជ្ញាធរចិន ពុំមានមូលដ្ឋានច្បាប់អន្តរជាតិ។

---

[88] http://www.khmer.rfi.fr/china-top-diplomat-meets-vietnamese-fm-over-sea-disputes (ចូលទស្សនាថ្ងៃទី១ កក្កដា ២០១៤)។

[89] http://zeenews.india.com/news/world/china-takes-vietnam-over-south-china-sea-to-un_938487.html (ចូលទស្សនាថ្ងៃទី១ កក្កដា ២០១៤)។

[90] http://zeenews.india.com/news/world/china-takes-vietnam-over-south-china-sea-to-un_938487.html (ចូលទស្សនាថ្ងៃទី១ កក្កដា ២០១៤)។

[91] http://www.cnas.org/sites/default/files/SolGen%20Speech%20CNAS.pdf (ចូលទស្សនាថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៤)។

[92] ហើស សិរីធន, *សមុទ្រចិនខាងត្បូង ក្នុងចក្ខុនយោបាយរបស់ពួកអ្នកវិភាគយុទ្ធសាស្ត្រអន្តរជាតិ* (ភ្នំពេញ៖ ពន្លឺខ្មែរ, ២០១៣), ១៩៧។

ហ្វីលីពីនបានធ្វើការទាមទារតំបន់សមុទ្រដែលមានចម្ងាយលើសពី៥០០ម៉ៃល៍សមុទ្រពីដែនដីគោករបស់ចិន និង ១២៥ម៉ៃល៍សមុទ្រពីប្រទេសហ្វីលីពីនដែលហៅថាតំបន់ Scarborough Shoal ហើយតំបន់នោះ គឺស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ប្រទេសហ្វីលីពីន។[93] កងនាវារបស់ចិនបានធ្វើឲ្យអាក់ខានដល់ប្រទេសហ្វីលីពីនក្នុងការនេសាទ ក៏ដូចជាការខ្វងរកប្រេងនៅតំបន់Recto Bank ដែលមានចម្ងាយ៨០ម៉ៃល៍ សមុទ្រពីឆ្នេររបស់ប្រទេសហ្វីលីពីន។[94] ប្រទេសចិន និងហ្វីលីពីនសុទ្ធតែបានប្រកាសអះអាងអធិបតេយ្យភាពរបស់ខ្លួនមកលើតំបន់Scarborough Shoal ព្រមទាំងចាត់ទុកតំបន់នេះជាចំណែកមួយដ៏សំខាន់ និង មិនអាចកាត់ផ្តាច់ចេញពីបូរណភាពទឹកដីរបស់ខ្លួនបានឡើយ។ ចិនបានប្រកាសអធិបតេយ្យភាពលើតំបន់ទាំងនេះដោយផ្អែកទៅលើកត្តាប្រវត្តិសាស្ត្រដែលចិនបានរុករកតំបន់ទាំងនេះមុនគេ ប៉ុន្តែហ្វីលីពីនវិញបានប្រកាសអធិបតេយ្យភាពរបស់ខ្លួនមកលើតំបន់នេះចាប់តាំងពីហ្វីលីពីនទទួលបានឯករាជ្យមកម្ល៉េះ (ប្រទេសហ្វីលីពីនទទួលឯករាជ្យនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៨៩៨)។

ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ហ្វីលីពីនបានធ្វើកំណត់ទូតមួយទៅកាន់មជ្ឈត្តវិនិច្ឆ័យ (Arbitration) អមជាមួយសេចក្តីថ្លែងការណ៍ស្តីពីការទាមទារផងដែរ។ ប៉ុន្តែប្រទេសចិនធ្វើការច្រានចោលចំពោះការធ្វើកំណត់ទូតនេះនិងបដិសេធចំពោះការដោះស្រាយតាមមជ្ឈត្តវិនិច្ឆ័យ។[95]

បញ្ហាវិវាទរវាងចិននិងហ្វីលីពីនអាចដោះស្រាយបានតាមរូបមន្តពីរយ៉ាង ទីមួយ គឺតាមរូបភាពទ្វេភាគី និងទីពីរ គឺប្រទេសទាំងពីរត្រូវឯកភាពគ្នាក្នុងការពឹងពាក់តុលាការអន្តរជាតិឲ្យជួយដោះស្រាយវិវាទ។ ប៉ុន្តែរូបមន្តទាំងពីរនេះមិនអាចធ្វើទៅបានឡើយ ព្រោះថាប្រទេសហ្វីលីពីនបដិសេធដាច់ខាតមិនទទួលយករូបភាពចរចាទ្វេភាគី ចំណែកឯចិនវិញបដិសេធមិនទទួលយកការពឹងពាក់តុលាការអន្តរជាតិដើម្បីដោះស្រាយវិវាទ។ [96]

### ១.៤. ប្រទេសចិន និងម៉ាឡេស៊ី

ប្រទេសម៉ាឡេស៊ីក៏បានទាមទារអធិបតេយ្យភាពនៅក្នុងសមុទ្រចិនខាងត្បូងដែរ ដោយប្រទេសម៉ាឡេស៊ីបានទាមទារកោះមួយចំនួនតូចនៅក្នុងទីប្រជុំកោះស្ព្រែតលី(Spratlys)។ ម៉ាឡេស៊ី

[93] http://www.bbc.com/news/world-asia-pacific-13748349 (ចូលទស្សនាថ្ងៃទី១ កក្កដា ២០១៤)។

[94] http://www.cnas.org/sites/default/files/SolGen%20Speech%20CNAS.pdf(ចូលទស្សនាថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៤)។

[95] http://www.cnas.org/sites/default/files/SolGen%20Speech%20CNAS.pdf (ចូលទស្សនាថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៤)។

[96] ហើស សិរីធន, *សមុទ្រចិនខាងត្បូង ក្នុងចក្ខុនយោបាយរបស់ពួកអ្នកវិភាគយុទ្ធសាស្ត្រអន្តរជាតិ* (ភ្នំពេញ៖ ពន្លឺខ្មែរ, ២០១៣), ៥២៥។

ទាមទារកោះទាំងនេះដោយសំអាងថា កោះទាំងនោះស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន ដោយអនុលោមទៅតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។[97]

ប្រទេសម៉ាឡេស៊ីក៏មិនខុសអ្វីពីប្រទេសវៀតណាមដែរ គឺម៉ាឡេស៊ីក៏មានប្រតិកម្មយ៉ាងរហ័សជំទាស់ទៅនឹងផែនទីអក្សរយូ(U)របស់ចិនដែរ ហើយម៉ាឡេស៊ីក៏បានផ្ញើកំណត់ទូតជំទាស់នឹងផែនទីអក្សរយូ(U)របស់ចិន ទៅកាន់អង្គការសហប្រជាជាតិក្នុងថ្ងៃជាមួយវៀតណាមផងដែរ។

ទោះជាម៉ាឡេស៊ីទាមទារតំបន់កោះមួយចំនួន ដែលដូចនឹងការទាមទាររបស់ចិនក៏ពិតមែន ប៉ុន្តែម៉ាឡេស៊ីមិនបង្កហេតុណាមួយឲ្យកើតឡើងនៅក្នុងតំបន់វិវាទនោះជាមួយនឹងចិនឡើយ។ ផ្ទុយទៅវិញម៉ាឡេស៊ីបែរជាព្យាយាមបង្កើនទំនាក់ទំនងជាមួយចិនឲ្យកាន់តែប្រសើរឡើងបន្ថែមទៀត។[98]

### ១.៥. ប្រទេសចិន និងប្រ៊ុយណេ

ប្រទេសប្រ៊ុយណេមិនមានវិវាទ នៅលើតំបន់សមុទ្រចិនខាងត្បូងជាមួយប្រទេសចិននោះទេ ព្រោះថាប្រ៊ុយណេមិនបានទាមទារកោះដែលស្ថិតនៅក្នុងតំបន់ជម្លោះនោះឡើយ។ ប្រ៊ុយណេគ្រាន់តែទាមទារតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន ដោយអនុលោមទៅតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS) តែប៉ុណ្ណោះ។[99]

## កថាខណ្ឌទី២ មូលហេតុនៃវិវាទ

តំបន់វិវាទនៅក្នុងសមុទ្រចិនខាងត្បូងដែលមានភាពក្តៅគគុក ហើយតានតឹងជាងគេគឺនៅទីប្រជុំកោះប៉ារ៉ាសែល(Paracels) និង ស្រ្តែតលី(Spratlys)។ សម្បត្តិធម្មជាតិដូចជា ត្រី ប្រេងកាត និងឧស្ម័នធម្មជាតិដែលមាននៅតំបន់ប្រជុំកោះទាំងពីរនេះគិតជាទឹកប្រាក់ អាចកើនទៅដល់១០០ម៉ឺនលានដុល្លារ។[100] លើសពីនេះទៅទៀត ទីតាំងយុទ្ធសាស្ត្រនៃទីប្រជុំកោះទាំងពីរនេះ គឺត្រង់ថាទីប្រជុំកោះទាំងពីរនេះ ឋិតនៅចំកណ្តាលផ្លូវទឹកតែម្តងរបស់នាវាដឹកប្រេងកាតមកពីភូមិភាគដើមបូព៌ាឆ្ពោះទៅកាន់ប្រទេសចិន និង ប្រទេសជប៉ុន ដោយឆ្លងពីសមុទ្រឥណ្ឌាមកសមុទ្រចិនកាត់តាមដៃសមុទ្រម៉ាឡាកា(Malacca)។

ទីប្រជុំកោះប៉ារ៉ាសែល(Paracels)ជាកម្រងកោះតូចៗដែលមានចំនួន១៣០កោះ នៅចន្លោះប្រទេសវៀតណាម និងប្រទេសហ្វីលីពីនហើយឋិតនៅប្រហែល២០០គ.មពីកោះហៃណាន់(Hainan)

---

[97] http://www.bbc.com/news/world-asia-pacific-13748349 (ចូលទស្សនាថ្ងៃទី១ កក្កដា ២០១៤)។

[98] John M. Finkbeiner, *Malaysia's Great Power Balance and the South China Sea Disputes* [តុល្យភាពអំណាចរបស់ម៉ាឡេស៊ី និងវិវាទសមុទ្រចិនខាងត្បូង], (U.S. Army War College, 2013), 1។

[99] http://www.bbc.com/news/world-asia-pacific-13748349 (ចូលទស្សនាថ្ងៃទី១ កក្កដា ២០១៤)។

[100] http://www.khmer.rfi.fr/south-china-sea-conflicts-two-archipelagos-for-six-tigers (ចូលទស្សនាថ្ងៃទី២៨ មិថុនា២០១៤)។

ប្រទេសចិន។ទីប្រជុំកោះនេះ គឺមានតែប្រទេសចិន វៀតណាម និង តៃវ៉ាន់ប៉ុណ្ណោះដែលដណ្តើមគ្នាចង់បាន។[101]បើយោងតាមឯកសាររបស់ យុន អ៊ី ជី (Yun Hee Ji) បានសរសេរថា បច្ចុប្បន្ននេះទីប្រជុំកោះប៉ារ៉ាសែល(Paracels) ត្រូវបានប្រទេសចិនកាន់កាប់ទាំងអស់។[102]

រីឯទីប្រជុំកោះស្ព្រែតលី(Spratlys)វិញ ជាកម្រងកោះដែលមានជាង៤០០កោះហើយឋិតនៅប្រមាណ១៦០០គ.មពីប្រទេសចិន។ ប៉ុន្តែទីប្រជុំកោះនេះឋិតនៅជិតប្រទេសវៀតណាម ហ្វីលីពីន ម៉ាឡេស៊ី ប្រ៊ុយណេ និងតៃវ៉ាន់ជាងប្រទេសចិន។ ប្រទេសចិន និងវៀតណាមទាមទារទីប្រជុំកោះស្ព្រែតលី(Spratly)នេះទាំងស្រុង។ នារយៈពេលជាង៣០ឆ្នាំចុងក្រោយនេះ គ្រប់ភាគីជម្លោះសុទ្ធតែបានចូលទៅកាន់កាប់ទីប្រជុំកោះអស់ទាំងនោះរៀងខ្លួន លើកលែងតែប្រទេសប្រ៊ុយណេតែប៉ុណ្ណោះ។ បើយោងតាមគេហទំព័រ RFIខេមរភាសា បានចុះផ្សាយថាទីប្រជុំកោះស្ព្រែតលី(Spratly)នេះ ត្រូវបានប្រទេសចិនកាន់កាប់ចំនួន៩កោះ ប្រទេសវៀតណាមកាន់កាប់២១កោះ ប្រទេសហ្វីលីពីនកាន់កាប់៨កោះ ប្រទេសម៉ាលេស៊ីកាន់កាប់៣កោះ និង ប្រទេសតៃវ៉ាន់កាន់កាប់កោះតែ១គត់ហើយជាកោះដែលធំជាងគេក្នុងចំណោមកោះដទៃទៀតនៅទីប្រជុំកោះស្ព្រែតលី(Spratly)។[103] ប៉ុន្តែបើយោងតាមឯកសាររបស់ យុន អ៊ី ជី(Yun Hee Ji) វិញបានសរសេរថា ប្រទេសចិនកាន់កាប់៨កោះ ប្រទេសវៀតណាម២៩កោះ ប្រទេសហ្វីលីពីនកាន់កាប់៨កោះ ប្រទេសម៉ាឡេស៊ីកាន់កាប់៥កោះ ប្រទេសប្រ៊ុយណេកាន់កាប់២កោះ និងតៃវ៉ាន់កាន់កាប់តែ១កោះប៉ុណ្ណោះ។[104]

មូលហេតុនៃវិវាទនៅតំបន់ប្រជុំកោះទាំងពីរនេះមានច្រើន ប៉ុន្តែយើងអាចនិយាយជារួមបានថាមានកត្តាបីធំៗដែលបង្កឲ្យមានវិវាទគឺ៖ ទីមួយ ទាក់ទងនឹងសិទ្ធិនេសាទត្រីនៅក្នុងដែនទឹកជុំវិញទីប្រជុំកោះទាំងពីរ ។ ទីពីរ ទាក់ទងនឹងសិទ្ធិរុករកប្រេងកាតនិងឧស្ម័នធម្មជាតិ ជាពិសេសនៅម្តុំប្រជុំកោះស្ព្រែតលី(Spratly)។ រីឯទីបី ទាក់ទងនឹងការក្តោបក្តាប់នូវតំបន់យុទ្ធសាស្ត្រដ៏សំខាន់មួយ។[105]

**កថាខណ្ឌទី៣ ដំណោះស្រាយកន្លងមក**

ការស្វះស្វែងរកដំណោះស្រាយចំពោះវិវាទនៅតំបន់សមុទ្រចិនខាងត្បូង ត្រូវបានធ្វើឡើងដោយការខិតខំប្រឹងប្រែងរវាងប្រទេសជាសមាជិកអាស៊ាន និងប្រទេសចិនតាមរយៈការប្រជុំចរចានានាដោយភាគីនៃវិវាទចៀសវាងការប្រើប្រាស់កំលាំងទ័ព ហើយខិតខំរក្សាសន្តិសុខ សុវត្ថិភាព

[101]http://www.khmer.rfi.fr/south-china-sea-conflicts-two-archipelagos-for-six-tigers (ចូលទស្សនាថ្ងៃទី២៨ មិថុនា២០១៨)។

[102]http://westlakemun.wikispaces.com/file/view/ASEAN-South+China+Sea+Dispute.pdf (ចូលទស្សនាថ្ងៃទី២៩ មិថុនា២០១៨)។

[103]http://www.khmer.rfi.fr/south-china-sea-conflicts-two-archipelagos-for-six-tigers (ចូលទស្សនាថ្ងៃទី២៨ មិថុនា ២០១៨)។

[104]http://westlakemun.wikispaces.com/file/view/ASEAN-South+China+Sea+Dispute.pdf (ចូលទស្សនាថ្ងៃទី២៩ មិថុនា២០១៨)។

[105]http://www.khmer.rfi.fr/south-china-sea-conflicts-two-archipelagos-for-six-tigers (ចូលទស្សនាថ្ងៃទី២៨ មិថុនា២០១៨)។

ស្ថិរភាពក្នុងតំបន់។ ក្នុងឆ្នាំ២០០២ ប្រទេសចិននិងប្រទេសដែលជាសមាជិកអាស៊ានបានជួបប្រជុំគ្នា ហើយសម្រេចបាននូវក្រមប្រតិបត្តិ(DOC "Declaration on the Conduct") មួយ ហើយព្រមទាំងសន្យាថានឹងឈានទៅដល់ការកសាងក្រមប្រតិបត្តិមួយទៀត ដែលចងទៅដោយច្បាប់នោះគឺ COC (Code of Conduct)។ មុននឹងនិយាយដល់COC យើងគួរតែដឹងពីDOC ដែលDOCនេះត្រូវបានបង្កើតឡើងសំដៅធ្វើយ៉ាងណា ដើម្បីកាត់បន្ថយជាអតិបរមានូវហានិភ័យដែលអាចនាំទៅកាន់ការប្រទូស្តរាយដោយកំលាំងទ័ព។ យើងអាចចាត់ទុកថាការបង្កើតDOC គឺជាជំហានមួយដ៏ធំរបស់អាស៊ាន ក្នុងការស្វះស្វែងរកដំណោះស្រាយនៅតំបន់សមុទ្រចិនខាងត្បូង។ នៅក្នុងDOCបានចែងថា ភាគីទាំងអស់បោះបង់ចោលនូវការប្រឈមមុខដាក់គ្នា ដោយរួមគ្នាដោះស្រាយបញ្ហាសមុទ្រចិនខាងត្បូងដោយសន្តិវិធីតាមរយៈការទូត ហើយរួមគ្នាប្រែក្លាយតំបន់នេះទៅជាតំបន់សន្តិភាព និងសហប្រតិបត្តិការ។ ប៉ុន្តែ DOCគ្រាន់តែជាសេចក្តីថ្លែងការណ៍មួយ ដែលមានខ្លឹមសារឆ្លុះបញ្ចាំងឡើងនូវឆន្ទៈនយោបាយរបស់ពួកប្រទេសពាក់ព័ន្ធប៉ុណ្ណោះ ដោយDOCគ្មានភាពចងដោយច្បាប់នោះទេ។[106] អាស្រ័យហេតុនេះហើយទើបក្នុងស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ន ចិនហាក់ដូចជាគ្មានឆន្ទៈក្នុងការគោរពតាមស្មារតីរបស់DOCនោះឡើយ ដែលជាហេតុធ្វើឲ្យDOCបរាជ័យ។

នៅពេលដែលបង្កើតDOCក្នុងឆ្នាំ២០០២ ប្រទេសជាសមាជិកអាស៊ាននិងចិនបានសន្យាថានឹងគោរពអនុវត្តតាមឲ្យបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាព ព្រមទាំងឆ្ពោះទៅការអនុម័តក្រមប្រតិបត្តិ COCទៀត។ ប៉ុន្តែមកដល់បច្ចុប្បន្ន (ឆ្នាំ២០១៣) ការបង្កើតCOCនៅតែពុំទាន់មានការរីកចម្រើនទៅមុខនៅឡើយ។ មូលហេតុដែលធ្វើឲ្យCOCមិនអាចកើតឡើងបានដោយសារតែចិនមានឥរិយាបថស្ទាក់ស្ទើរមិនចង់ប្រឈមមុខជាមួយបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់។[107]

តាមទស្សនរបស់លោក Rizal Sukuma លោកថាការកសាងឡើងនូវCOC នេះមិនសំដៅដោះស្រាយបញ្ហាអធិបតេយ្យភាពនោះទេ តែCOCនេះមានមុខងារជាអ្នកផ្តល់ការព្រមព្រៀងក្នុងក្របខ័ណ្ឌមួយធ្វើយ៉ាងណា ដើម្បីបញ្ចៀសកុំឲ្យមានភាពតានតឹងប្រឈមមុខដាក់គ្នានៅក្នុងតំបន់ ដែលខ្លឹមសាររបស់COC រួមមានដូចជា បណ្តាគោលការណ៍នីតិវិធីដោះស្រាយមកលើឧបទ្ទវហេតុដែលកើតមានឡើងនៅសមុទ្រ យន្តការបង្ការរឿងហេតុដែលកើតមានឡើងដោយការអុកឡុករំខានពីភាគីវិវាទមួយបង្កឡើង និងយន្តការសម្រួលដោះស្រាយវិវាទនេះ។

[106]ហើស សិរីធន, *សមុទ្រចិនខាងត្បូង ក្នុងចក្ខុនយោបាយរបស់ពួកអ្នកវិភាគយុទ្ធសាស្ត្រអន្តរជាតិ* (ភ្នំពេញ៖ ពន្លឺខ្មែរ, ២០១៣), ៧៨។
[107]ហើស សិរីធន, *សមុទ្រចិនខាងត្បូង ក្នុងចក្ខុនយោបាយរបស់ពួកអ្នកវិភាគយុទ្ធសាស្ត្រអន្តរជាតិ* (ភ្នំពេញ៖ ពន្លឺខ្មែរ, ២០១៣), ៩២។

# សេចក្តីសន្និដ្ឋាន

វិវាទដែនសមុទ្រកើតមានឡើងស្ទើរតែគ្រប់តំបន់ជុំវិញសាកលលោក ដោយសារតែសង្គមមនុស្សអាចស្វែងរកផលប្រយោជន៍ជាច្រើនពីសមុទ្រដែលមានដូចជា ការធ្វើអាជីវកម្ម ការរុករកប្រេង ឧស្ម័នធម្មជាតិ ការនេសាទ។ល។ ដោយសារតែការចង់បាននូវផលប្រយោជន៍ទាំងនេះហើយទើបធ្វើឲ្យមនុស្សត្រូវប្រកួតប្រជែងដណ្តើមគ្នា ដែលបង្កឲ្យក្លាយទៅជាវិវាទ។ ដើម្បីបង្ការកុំឲ្យមាននូវវិវាទដែលកើតឡើងដោយសារតែមានការខ្វែងគំនិតគ្នា គេក៏បង្កើតឲ្យមានច្បាប់ មានទំនៀមទំលាប់ ដែលជាមធ្យោបាយដ៏ល្អសម្រាប់ដោះស្រាយទៅលើបញ្ហាវិវាទដែលកើតឡើងនោះ។ តាំងពីបុរាណមក បណ្តារដ្ឋដែលនិយមដើរសមុទ្រដើម្បីស្វែងរកដែនដីថ្មីតែងតែមានច្បាប់ ឬទំនៀមទំលាប់ ឬក៏បង្កើតជាលទ្ធិ(doctrine) ក្នុងការដើរសមុទ្រ ដែលច្បាប់ទាំងនោះមានដូចជា ច្បាប់សមុទ្ររ៉ូឌាន (Rhodian Sea Law) ច្បាប់នៃអូឡឺរ៉ែន (Rules of Oleron) ច្បាប់ខនសូឡាតូ ឌែលម៉ារេ (Consolato del Mare) ជាដើម។ លុះក្រោយមកទៀត នៅសតវត្សទី១៥ យើងឃើញមានសន្ធិសញ្ញាមួយបានកើតឡើង។នោះគឺ សន្ធិសញ្ញាថ័រដេស៊ីឡា(Treaty of Tordesillas) ដែលសន្ធិសញ្ញានេះបង្កើតឡើងដើម្បីធ្វើការបែងចែកព្រំដែនសមុទ្ររវាងប្រទេសអេស្ប៉ាញ និង ប្រទេសព័រទុយហ្គាល់ដែលជាប្រទេសមហាអំណាចនាសម័យកាលនោះ។ លុះមកដល់ឆ្នាំ១៧៩៥ ការបង្កើតឲ្យមានការវាស់ទំហំតំបន់សមុទ្រដែនដីតាមរយៈការបាញ់ចេញពីកាំភ្លើងធ្លោងក៏កើតមានឡើង ដែលរូបមន្តនៃការវាស់នេះត្រូវបានបណ្តារដ្ឋនានាបានប្រើប្រាស់ជាទូទៅ។ ក្នុងសម័យកាលដែលប្រើប្រាស់កាំភ្លើងធំដើម្បីវាស់តំបន់សមុទ្រដែនដីនេះ គឺមានរដ្ឋខ្លះកំណត់តំបន់សមុទ្រដែនដីមានទំហំ៣ម៉ៃល៍ ហើយរដ្ឋខ្លះទៀតកំណត់ទំហំ៤ម៉ៃល៍ ហើយមានរដ្ឋខ្លះទៀតនោះកំណត់ដល់ទៅ៦ម៉ៃល៍ក៏មាន។ នៅក្រោយសង្គ្រាមលោកលើកទី១ គឺក្នុងឆ្នាំ១៩៣០មានសន្និសីទអន្តរជាតិមួយបានកើតឡើងនៅទីក្រុងឡាអេ ដែលក្នុងសន្និសីទនេះគេបានពិភាក្សាលើបញ្ហាជាច្រើន ក្នុងនោះក៏មានទាក់ទងនឹងនីតិសមុទ្រផងដែរ។ ការពិភាក្សាលើនីតិសមុទ្រនេះគេសម្រេចបានជាលទ្ធផលមួយចំនួនដូចជា គេបានកំណត់តំបន់សមុទ្រដែនដីក្នុងទំហំ៣ម៉ៃល៍ បង្កើតឲ្យមានតំបន់តភ្ជាប់ និងបញ្ហាផ្សេងៗទៀត ប៉ុន្តែក៏មានបញ្ហាជាច្រើនទៀត នៅតែមិនអាចដោះស្រាយរួចរាល់ផងដែរ។ ក្នុងឆ្នាំ១៩៤៥ លោកហារី ទ្រូមែន ដែលជាប្រធានាធិបតីទី៣៣ របស់សហរដ្ឋអាមេរិក។ លោកបានចេញសេចក្តីប្រកាសពីរ ដែលសេចក្តីប្រកាសទី១ ប្រកាសថាសហរដ្ឋអាមេរិកដាក់បទប្បញ្ញត្តិលើការនេសាទនៅតំបន់លំហសមុទ្រ ហើយសេចក្តីប្រកាសទី២ ប្រកាសថាសហរដ្ឋអាមេរិកមានយុត្តាធិការទៅលើធនធាននៅខ្ពង់រាបបាតសមុទ្រ និងដីក្រោមខ្ពង់រាបបាតសមុទ្រ។ នៅឆ្នាំ១៩៨២ អនុសញ្ញាមួយបានកើតឡើងនោះគឺ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS)។ អនុសញ្ញានេះធ្លាប់បានបង្កើត

ឡើងក្នុងឆ្នាំ១៩៥៨ ជាលើកទី១(UNCLOSI) ហើយនៅឆ្នាំ១៩៦០ម្តងទៀតដែលជាលើកទី២ (UNCLOS II) និងនៅឆ្នាំ១៩៨២ជាលើកទី៣ (UNCLOSIII)។ អនុសញ្ញានេះបង្កើតឡើងតាមរយៈសន្និសីទអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។ តាមរយៈអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រទី៣(UNCLOSIII) គឺមានចែងពីការកំណត់តំបន់សមុទ្រ និងសមត្ថកិច្ចយុត្តាធិការក្នុងការដោះស្រាយវិវាទនៅលើសមុទ្រ។ ការកំណត់តំបន់សមុទ្រនោះមានដូចជា តំបន់ដែនទឹកផ្ទៃក្នុង តំបន់សមុទ្រដែនដី តំបន់តភ្ជាប់ តំបន់ខ្ពង់រាបបាតសមុទ្រ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់លំហសមុទ្រអន្តរជាតិ។ ចំណែកឯការដោះស្រាយវិវាទដែនសមុទ្រវិញ មានស្ថាប័នយុត្តិធម៌អន្តរជាតិចំនួន៤ដែលមានសមត្ថកិច្ចយុត្តាធិការលើវិវាទនោះដែលមានដូចជា តុលាការយុត្តិធម៌អន្តរជាតិ(the International Court of Justice) សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ(International Tribunal for the Law of the Sea) សាលាក្តីមជ្ឈត្តវិនិច្ឆ័យ(Arbitral Tribunal) សាលាក្តីមជ្ឈត្តវិនិច្ឆ័យពិសេស(Special Arbitral Tribunal)។ ជារួមមកទាក់ទងនឹងការដោះស្រាយវិវាទដែនសមុទ្រ យើងអាចចែកចេញជានីតិវិធី២យ៉ាងគឺ ការចរចាជាទ្វេភាគី និងការចូលរួមនៃភាគីទី៣។ នៅក្នុងការចូលរួមនៃភាគីទី៣ យើងអាចចែកចេញជានីតិវិធី៥យ៉ាងទៀតគឺ (១)ការផ្តល់កន្លែងចរចា (២)ការផ្សះផ្សា (៣)ការសម្រុះសម្រួល (៤)មជ្ឈត្តកម្មឬ មជ្ឈត្តវិនិច្ឆ័យ (៥)ចំណាត់ការតុលាការ។

អមជាមួយនឹងការបកស្រាយទាក់ទងនឹងដំណើរនៃការអភិវឌ្ឍទៅលើនីតិសមុទ្រ ក៏ដូចជាការកំណត់ព្រំដែនសមុទ្រ និងសមត្ថកិច្ចយុត្តាធិការក្នុងការដោះស្រាយវិវាទលើដែនសមុទ្រ យើងក៏បានភ្ជាប់មកជាមួយនូវរឿងក្តីចំនួន៣ ដែលរឿងក្តីទីមួយ ទាក់ទងនឹងបញ្ហាកំណត់ព្រំដែនសមុទ្ររវាងប្រទេសរ៉ូម៉ានី និងប្រទេសអ៊ុយក្រែន ហើយរឿងក្តីទីពីរ ទាក់ទងនឹងបញ្ហារំលោភបំពានអធិបតេយ្យភាពលើដែនសមុទ្ររវាងប្រទេសColombia និងប្រទេសNicaragua ។ ចំណែកឯរឿងក្តីទីបី គឺទាក់ទងនឹងបញ្ហាសមុទ្រចិនខាងត្បូងដែលជាបញ្ហាក្តៅគគុកក្នុងសតវត្សទី២១។ ទាក់ទងនឹងបញ្ហាសមុទ្រចិនខាងត្បូងនេះ យើងឃើញថាពិតជាមានការលំបាកខ្លាំងណាស់ក្នុងការដោះស្រាយព្រោះដោយសារតែភាគីវិវាទមានចំណុចមិនចុះសម្រុងគ្នាច្រើន ហើយមួយវិញទៀតគឺការយកប្រយោជន៍ផ្ទាល់ខ្លួនជាធំ។ ជាក់ស្តែង ប្រទេសចិនដែលជាប្រទេសមហាអំណាចសេដ្ឋកិច្ចមួយក្នុងពិភពលោកនាពេលបច្ចុប្បន្ន ហើយពេលនេះក៏ជាប្រទេសមួយដែលត្រូវបានគេចាត់ទុកថាជាប្រទេសបងធំក្នុងការដើរបង្ករឿងជាមួយបណ្តាប្រទេសជាសមាជិកអាស៊ានដូចជា វៀតណាម ហ្វីលីពីន ម៉ាឡេស៊ី និងប្រ៊ុយណេ។ម្យ៉ាងទៀតនោះ នៅពេលដែលបណ្តាប្រទេសអាស៊ានចង់នាំវិវាទនេះទៅដោះស្រាយនៅតុលាការនោះ ចិនបែរជាមិនយល់ព្រម ហើយពេលដែលចិនចង់ចរចាជាទ្វេភាគី ក៏បណ្តាប្រទេសអាស៊ានមិនយល់ព្រមផងដែរ ដែលជាហេតុមួយពិបាករកដំណោះ

ស្រាយក្នុងបញ្ហាសមុទ្រចិនខាងត្បូងនេះ។ ការដោះស្រាយវិវាទនៅលើសមុទ្រចិនខាងត្បូងជួបបញ្ហាក៏ដោយសារមូលហេតុបីយ៉ាងគឺ ទី១ រាល់ការវិវាទអំពីបូរណភាពដែនសមុទ្រ លើសមុទ្រចិនខាងត្បូងសុទ្ធតែមានភាពស្មុគស្មាញពិបាកដោះស្រាយ ដោយការវិវត្តន៍នោះពាក់ព័ន្ធទៅនឹងដែនអធិបតេយ្យភាព។ ទី២ បញ្ហាសមុទ្រចិនខាងត្បូងនេះ កាន់តែមានភាពស្មុគស្មាញពិបាកដោះស្រាយទៅៗដោយសារតំបន់សមុទ្រនេះមានតំលៃខ្ពស់ខាងយុទ្ធសាស្ត្រយោធា សេដ្ឋកិច្ច និងសន្តិសុខ។ និងទី៣ ចិនជាមហាអំណាចមួយ ដែលកំពុងងើបឡើង ដូច្នេះការត្រួតត្រាកាន់កាប់មកលើសមុទ្រចិនខាងត្បូង ដោយឆ្លងតាមរយៈវត្តមានយោធានៅលើតំបន់សមុទ្រនេះ កាន់តែជាការពង្រឹងបន្ថែមទៀត នូវឧត្តមភាពខាងយុទ្ធសាស្ត្ររបស់ចិននៅតំបន់សមុទ្រនេះ។

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវទាក់ទងនឹងការកំណត់ព្រំដែនសមុទ្រ សមត្ថកិច្ចយុត្តាធិការអន្តរជាតិ និងអមជាមួយរឿងក្តីនៅខាងលើរួចមក ខ្ញុំយល់ឃើញថាការកំណត់ព្រំដែនសមុទ្រ និងសមត្ថកិច្ចយុត្តាធិការអន្តរជាតិ ដែលមានចែងនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOSIII)នៅមានចន្លោះខ្វះខាតខ្លះ។ មូលហេតុដែលនាំឲ្យខ្ញុំយល់ថាខ្វះចន្លោះនោះត្រង់ថា អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOSIII) គឺជាច្បាប់អន្តរជាតិមួយដែលបង្កើតឡើងដោយមានរដ្ឋនានានៅជុំវិញសកលលោកចូលរួមជាសមាជិកប្រមាណជា១៦៥រដ្ឋ។[108] ដូច្នេះមានន័យថា អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រនេះ ជាច្បាប់អន្តរជាតិមួយដែលមានការទទួលស្គាល់ជាសាកលហើយមានតំលៃគតិយុត្តខ្ពស់ ដែលបណ្តារដ្ឋនានានៅជុំវិញសកលលោកត្រូវគោរពតាម។ ផ្ទុយទៅវិញបែរជាមានរដ្ឋខ្លះដែលជាសមាជិកនៃអនុសញ្ញានេះ មិនអនុវត្តតាមការកំណត់ព្រំដែនសមុទ្រដែលមានចែងនៅក្នុងអនុសញ្ញា ដែលជាបច្ច័យមួយនាំឲ្យខ្ញុំយល់ឃើញថា ការកំណត់ព្រំដែនសមុទ្រដែលមាននៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រមានចន្លោះខ្វះខាត ហើយហាក់ដូចជាគ្មានតំលៃគតិយុត្តគួរឲ្យគោរពតាមទៅវិញ។ មួយវិញទៀតទាក់ទងនឹងសមត្ថកិច្ចយុត្តាធិការអន្តរជាតិនៅលើដែនសមុទ្រ ក៏មានចំណុចមួយដែលនាំឲ្យខ្ញុំយល់ឃើញថា សមត្ថកិច្ចយុត្តាធិការអន្តរជាតិនៅខ្វះសិទ្ធិអំណាច ដើម្បីធ្វើឲ្យការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិកាន់តែមានប្រសិទ្ធភាពខ្ពស់។ ជាក់ស្តែង ដើម្បីដោះស្រាយវិវាទដែលកើតឡើងនៅលើដែនសមុទ្របាន គឺតម្រូវឲ្យភាគីនៃវិវាទមានការព្រមព្រៀងគ្នាក្នុងការកំណត់សមត្ថកិច្ចយុត្តាធិការដើម្បីដោះស្រាយបញ្ហាវិវាទជាមុនសិន ទើបយុត្តាធិការអន្តរជាតិនោះមានសមត្ថកិច្ចដោះស្រាយវិវាទបាន។ យ៉ាងណាមិញ ដូចក្នុងបញ្ហាប្រឈមដែលកើតមានឡើងនៅសមុទ្រចិនខាងត្បូងអញ្ចឹង គឺភាគីចិនមិនព្រមនាំរឿងក្តីជាមួយប្រទេសដែលជាសមាជិកអាស៊ាន ទៅឲ្យយុត្តាធិការអន្តរជាតិជួយដោះស្រាយនោះទេ ហើយចង់ដោះស្រាយបញ្ហាដោយគ្រាន់តែធ្វើការចរចាជាទ្វេភាគី ទោះជាការចរចាជាទ្វេភាគីនោះគ្មានប្រសិទ្ធភាពក៏ដោយ។ ដោយហេតុនេះហើយ នាំឲ្យខ្ញុំមានចម្ងល់មួយថា បើសិនជាភាគីវិវាទទាំងពីរ នៅតែចរចាជាទ្វេភាគីមិនបានសម្រេច ហើយភាគីទាំងពីរនៅតែមិនព្រមនាំរឿងក្តីទៅឲ្យយុត្តាធិការអន្តរជាតិជួយដោះស្រាយទៀត តើត្រូវទុកឲ្យបញ្ហាវិវាទនេះមានការប្រឈមមុខដល់ពេលណាទៀត? ឬមួយក៏ត្រូវទុកឲ្យបញ្ហាវិវាទនេះកើតមានឡើងយ៉ាងរ៉ាំរ៉ៃបែបនេះឬ?

---

[108] Chronological Lists of Ratifications of , Accessions and Successions to the Convention and the Related Agreements as at 23 January 2013[បញ្ជីនៃរដ្ឋភាគីអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រឆ្នាំ១៩៨២], ២០១៣។

ដើម្បីឆ្លើយតបទៅនឹងភាពខ្វះចន្លោះនៃតំលៃគតិយុត្តរបស់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ និង ភាពខ្វះចន្លោះនៃសមត្ថកិច្ចយុត្តាធិការអន្តរជាតិដែលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទដែនសមុទ្រ ខ្ញុំមានមតិយោបល់ខ្លះចង់ចូលរួមចំណែក។ ខ្ញុំយល់ឃើញថា គួរតែបង្កើតឲ្យមានគោលការណ៍មួយ ឬក៏ក្រមប្រតិបត្តិមួយដែលមានសិទ្ធិអំណាច មានតំលៃគតិយុត្តខ្ពស់ ហើយអាចចាប់បង្ខំឲ្យរដ្ឋត្រូវតែគោរពតាម និងអាចធ្វើការអន្តរាគមន៍ដោះស្រាយទៅលើបញ្ហាវិវាទដែនសមុទ្រទាំងឡាយណាដែលមានលក្ខណៈពុំរ៉ែដូចជាបញ្ហាសមុទ្រចិនខាងត្បូង៕

᪬ ឯកសារយោង

❖ ច្បាប់និង លិខិតបទដ្ឋានអន្តរជាតិ

១. អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ឆ្នាំ១៩៨២។

២. ច្បាប់នៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (Rule of the Tribunal) ឆ្នាំ ២០០៩។

៣. លក្ខន្តិកៈនៃសាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ (Statute of the International Tribunal for the Law of the Sea) ឆ្នាំ១៩៨២។

៤. លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ១៩៤៥។

៥. ឧបសម្ព័ន្ធទី៧ និងទី៨ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ឆ្នាំ១៩៨២។

❖ សាលដីកា/សាលក្រម

៦. រឿងក្តីនៃការកំណត់ព្រំដែនសមុទ្រក្នុងសមុទ្រខ្មៅរវាងប្រទេសរ៉ូម៉ានី និង អ៊ុយក្រែន (Maritime Delimitation in the Black Sea (Romania *v.* Ukraine)), ២០០៩។

៧. រឿងក្តីរវាងប្រទេសNicaragua និងប្រទេសColombia (Alleged Violations of Sovereign Rights and Maritime Spaces in the Caribbean Sea (Nicaragua *v.* Colombia), ២០១៣។

❖ សៀវភៅ

៨. សំរ៉ង រិទ្ធីវង្ក, ២០១០, *នីតិសមុទ្រ*, ភ្នំពេញ៖ រោងពុម្ពអង្គរ។

៩. ហើស សិរីធន, ២០១៣, *សមុទ្រចិនខាងត្បូងក្នុងចក្ខុនយោបាយរបស់ពួកអ្នកវិភាគយុទ្ធសាស្ត្រអន្តរជាតិ*, ភ្នំពេញ៖ ពន្លឺខ្មែរ។

១០. 河野真理子、森田章夫 និង 山本良、២០០៧、*国際法* [នីតិអន្តរជាតិ]、បោះពុម្ពលើកទី៤、有斐閣 ។

❖ ឯកសារពិភាក្សា

១១. សម្តេចសង្ឃរាជ ជួន ណាត, *វចនានុក្រមខ្មែរ ភាគទី១ និងទី២*, ១៩៦៧, ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ។

១២. Campact MediaGmbH, 2011, *International Tribunal for the Law of the Sea* [សាលាក្តីអន្តរជាតិសម្រាប់នីតិសមុទ្រ], Hamburg។

១៣. Joseph Guvendiren, 2012, *Background Guide 2012 Treaty of Tordesillas* [សេចក្តីណែនាំពីប្រវត្តិនៃសន្ធិសញ្ញាថរដេស៊ីឡា], Five College Model United Nations។

១៤. Mark W. Janis, 1993, *An Introduction to International Law* [សេចក្តីផ្តើមនីតិអន្តរជាតិ], U.S: Little, brown and Company។

១៥. Leszek Buszynski, *The Development of the South China Sea Maritime Dispute* [វឌ្ឍនភាពនៃវិវាទនៅសមុទ្រចិនខាងត្បូង], Australian National University។
១៦. Ivan Vansertima, 1976, *They Came Before Columbus* [ពួកគេមកដល់មុនលោក Columbus], Rutgers University។

❖ **របាយការណ៍**

១៧. John M. Finkbeiner, 2013, *Malaysia's Great Power Balance and the South China Sea Disputes* [តុល្យភាពអំណាចរបស់ម៉ាឡេស៊ីនិងវិវាទសមុទ្រចិនខាងត្បូង], U.S Army War College។
១៨. The UN Department of Public Information, 2000, *the International Court of Justice, Questions and Answers about the Principal Judicial Organ of the United Nations* [តុលាការយុត្តិធម៌អន្តរជាតិ, សំនួរ និងចម្លើយអំពីគោលការណ៍វិនិច្ឆ័យនៃអង្គការសហប្រជាជាតិ], New York។

❖ **គេហទំព័រ**

១៩. http://www.bbc.com (ថតចម្លងថ្ងៃទី១ កក្កដា ២០១៤)។
២០. http://www.cnas.org/sites/default/files/SolGen%20Speech%20CNAS.pdf (ចូលទស្សនាថ្ងៃទី២ កក្កដា ២០១៤)។
២១. http://www.eu-asiacentre.eu (ថតចម្លងថ្ងៃទី ២៧ មិថុនា ២០១៤) ។
២២. http://home.comcast.net (ថតចម្លងថ្ងៃទី៣០ មិថុនា ២០១៤) ។
២៣. http://www.icj-cij.org (ថតចម្លងថ្ងៃទី២២ មិថុនា ២០១៤) ។
២៤ http://www.itlos.org (ថតចម្លងថ្ងៃទី២២ មិថុនា ២០១៤) ។
២៥. http://www.khmer.rfi.fr (ថតចម្លងថ្ងៃទី១ កក្កដា ២០១៤) ។
២៦. http://www.monash.edu (ថតចម្លងថ្ងៃទី១៦ មិថុនា ២០១៤) ។
២៧. http://www.nbr.org (ថតចម្លងថ្ងៃទី៣០ មិថុនា ២០១៤) ។
២៨. http://oceanslaw.blogspot.com/2011/05/brief-outline-of-history-development-of.html (ចូលទស្សនា ថ្ងៃទី៤ កក្កដា ២០១៤)។
២៩. http://oceanservice.noaa.gov/facts/howmanyoceans.html (ចូលទស្សនាថ្ងៃទី៦ កក្កដា ២០១៤) ។
៣០. http://westlakemun.wikispaces.com (ថតចម្លងថ្ងៃទី២៩ មិថុនា ២០១៤) ។
៣១. http://zeenews.india.com (ថតចម្លងថ្ងៃទី១ កក្កដា ២០១៤) ។